ក

# មាតិកា

## I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


០៤-០២-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០២១២/០៥៦ ស្តីពី ការតែងតាំង ឯកឧត្តម ជា អួន ជា អនុរដ្ឋលេខាធិការ នៃ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ១៣៦៩

០៦-០២-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០២១២/០៥៧ ស្តីពី ការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ចំនួន ០២ រូប នៃ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ១៣៧០

១៩-០២-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០២១២/០៩៣ ស្តីពីការតែងតាំង ឯកឧត្តម តែ មូរ ជា ទីប្រឹក្សាក្រសួងផែនការ មានឋានៈស្មើ អគ្គនាយក ១៣៧១

២០-០២-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០២១២/០៩៤ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា តាមលំដាប់ថ្នាក់ ចំពោះ ថ្នាក់ដឹកនាំ នៃ ក្រុមហ៊ុនធានារ៉ាប់រងបន្តកម្ពុជា ចំនួន ០៧ រូប ១៣៧២

២០-០២-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០២១២/០៩៦ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេរីវឌ្ឍន៍ ចំពោះ សប្បុរសជន ចំនួន ០២ រូប ១៣៧៣

២០-០២-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០២១២/០៩៨ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា ចំពោះ ថ្នាក់ដឹកនាំ និង មន្ត្រីរាជការ នៃក្រុមការងារក្រសួងយុត្តិធម៌ ចំនួន ០៦ រូប ១៣៧៤

២០-០២-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០២១២/០៩៩ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេរីវឌ្ឍន៍ ចំពោះ ប្រធានក្រុមហ៊ុន មេគង្គណិត និង ក្រុមហ៊ុនអាណាណាកុំព្យូទ័រ ចំនួន ០២ រូប ១៣៧៥

២០-០២-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០២១២/១០០ ស្តីពី ការតែងតាំង ឯកឧត្តម តេម សុខុន ជា ទីប្រឹក្សាអមទីស្តីការគណៈរដ្ឋមន្ត្រី មានឋានៈស្មើ រដ្ឋលេខាធិការ ១៣៧៦

២០-០២-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០២១២/១០១ ស្តីពី ការបញ្ចប់មុខតំណែងឯកឧត្តម ចំនួន ០៣ រូប ពីសមាជិកអចិន្ត្រៃយ៍ នៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ និង តែងតាំង ឯកឧត្តម ចំនួន ០៤ រូប ជាសមាជិកអចិន្ត្រៃយ៍ នៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ ១៣៧៧

២០-០២-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០២១២/១០៣ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា ចំពោះ សប្បុរសជន ចំនួន ០៣ រូប ១៣៧៩

២០-០២-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០២១២/១០៤ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា ចំពោះ លោកវរសេនីយ៍ឯក ទេព សុខវណ្ណដារ៉ា ១៣៨០
២០-០២-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០២១២/១០៥ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ នាយទាហាន អគ្គនាយកដ្ឋានភស្តុភារហិរញ្ញវត្ថុ ក្រសួងការពារជាតិ ចំនួន ៦៩ រូប ១៣៨១
២២-០២-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០២១២/១០៦ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេរីវឌ្ឍន៍ ចំពោះ លោក គឹម រតនា ១៣៨៥
២២-០២-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០២១២/១០៧ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា ប្រគេន ចំពោះ ព្រះគ្រូ មឿន ខឿន ១៣៨៦
២២-០២-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០២១២/១០៨ ស្តីពី ការដំឡើងឋានន្តរស័ក្តិ ជូនឯកឧត្តម សួត ដា ពីវរមន្ត្រីការបរទេស ថ្នាក់លេខ ៦ ទៅឧត្តមមន្ត្រីការបរទេស ថ្នាក់លេខ ៦ នៃក្របខណ្ឌមន្ត្រីការទូតជាន់ខ្ពស់ ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ១៣៨៧
២២-០២-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០២១២/១០៩ ស្តីពី ការដំឡើងឋានន្តរស័ក្តិ មន្ត្រីរាជការពីវរមន្ត្រី ទៅ ឧត្តមមន្ត្រី នៃ ក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅ ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ ចំនួន ០២ រូប ១៣៨៨
២២-០២-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០២១២/១១០ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា ប្រគេន ចំពោះ ព្រះតេជគុណ អួន ឆឿន ព្រះគ្រូចៅអធិការវត្ត និង ជាអនុគណស្រុកឧដុង្គ ១៣៨៩

## II~រាជរដ្ឋាភិបាល

### ១~អនុក្រឹត្យ

០៣-០២-២០១២ -អនុក្រឹត្យលេខ ១៨ អនក្រ.បក ស្តីពី ការរៀបចំ និង ការប្រព្រឹត្តទៅ របស់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ១៣៩០
២៤-០២-២០១២ -អនុក្រឹត្យលេខ ២៩ អនក្រ.បក ស្តីពី ការកំណត់រង្វាន់សម្រាប់ការប្រឡងប្រណាំងទីក្រុងស្អាត ១៤០៨
២៤-០២-២០១២ -អនុក្រឹត្យលេខ ៣០ អនក្រ.បក ស្តីពីការធ្វើអនុបយោគផ្ទៃដីទំហំ ៥.៩៨០ ហិកតា ក្នុងតំបន់សម្បទានដីសេដ្ឋកិច្ច ស្ថិតនៅក្នុងភូមិសាស្ត្រស្រុក សង្គមថ្មី និង ស្រុករវៀង ខេត្តព្រះវិហារ ១៤១៥

០៣-០២-២០១២ -អនុក្រឹត្យលេខ ១២៩ អនក្រ.តត ស្តីពី ការតែងតាំង និង ប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ១៤១៨
១៦-០២-២០១២ -អនុក្រឹត្យលេខ ១៩៨ អនក្រ.តត ស្តីពី ការជូនមេដាយសហមេត្រី ១៤២១
២២-០២-២០១២ -អនុក្រឹត្យលេខ ២២០ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ១៤២៣
២២-០២-២០១២ -អនុក្រឹត្យលេខ ២២១ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ១៤២៥
២២-០២-២០១២ -អនុក្រឹត្យលេខ ២២២ អនក្រ.តត ស្តីពី ការជូនមេដាយសុវត្ថារា ១៤២៧
២៣-០២-២០១២-អនុក្រឹត្យលេខ ២២៦ អនក្រ.តត ស្តីពី ការដំឡើងថ្នាក់មន្ត្រីរាជការ ១៤២៩
២៤-០២-២០១២ -អនុក្រឹត្យលេខ ២២៧ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ១៤៣៣
២៤-០២-២០១២ -អនុក្រឹត្យលេខ ២២៨ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ១៤៣៥

## III~ការងារបណ្តាក្រសួង

### ១~ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

១០-០២-២០១២ -ប្រកាសលេខ ០៤២ សហវ.ប្រក ស្តីពី ការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ សម្រាប់ឆ្នាំ ២០១២ ១៤៣៧
២៣-០២-២០១២-សារាចរណែនាំលេខ ០០១ សហវ.សរណ ស្តីពី ការអនុវត្តច្បាប់ស្តីពីលទ្ធកម្មសាធារណៈ ១៤៤៣
១០-០២-២០១២ -សេចក្តីជូនដំណឹងលេខ ០០៦ សហវ.សជណ ស្តីពី ការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន និង យានជំនិះគ្រប់ប្រភេទ សម្រាប់ឆ្នាំ ២០១២ ១៤៤៦

### ២~ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

១៣-១២-២០១០-លិខិតបញ្ជាក់លេខ ៥៥៩២ ពណ.ចបព ស្តីពី ការទទួលចុះបញ្ជីនូវការកែប្រែនិងតំកល់ទុកលក្ខន្តិកៈថ្មីរបស់ក្រុមហ៊ុន **ដាត ហ័រ គ្រេឌីង (ខេមបូឌា)** ១៤៥៣
១៣-១២-២០១០-លិខិតបញ្ជាក់លេខ ៥៦០៤ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ន័រខេម និបតើរ** ១៤៥៥
១៣-១២-២០១០-លិខិតបញ្ជាក់លេខ ៥៦០៦ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់សាខាក្រុមហ៊ុន **ស៊ីឈួន រ៉ូដ & ប្រ៊ីដ (គ្រុប) ខប** ១៤៥៧
១៤-១២-២០១០-លិខិតបញ្ជាក់លេខ ៥៦៣០ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ឡុងស៊ួន ឡូជីស្ទិត & អ៊ីម-អិច** ១៤៥៨

១៤-១២-២០១០ -លិខិតបញ្ជាក់លេខ ៥៦៣៤ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **នូត ដាលីន អ៊ីមផត អិចផត** ១៤៦០

១៥-១២-២០១០ -លិខិតបញ្ជាក់លេខ ៥៦៤៥ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ខេមបូឌាន-ឆាយណា វិឈ្ងូ ត្រេដ ខូ អិលធីឌី** ១៤៦២

១៥-១២-២០១០ -លិខិតបញ្ជាក់លេខ ៥៦៤៦ ពណ.ចបព ស្តីពី ការទទួលចុះបញ្ជីនូវការកែប្រែនិង តំកល់ទុកលក្ខន្តិកៈថ្មីរបស់ក្រុមហ៊ុន **អាយ អ៊ី អាយ ថេគណូឡូជី** ១៤៦៤

១៥-១២-២០១០ -លិខិតបញ្ជាក់លេខ ៥៦៥៤ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ខណ្ណៈ ខេមអ៊ិនវេស (ខេមបូឌា) អ៊ិនវេសមេន គ្រុប** ១៤៦៦

១៥-១២-២០១០ -លិខិតបញ្ជាក់លេខ ៥៦៥៦ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **យី ហប ហ៊ីង ថាយ (ខេមបូឌា)** ១៤៦៧

១៥-១២-២០១០ -លិខិតបញ្ជាក់លេខ ៥៦៥៧ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **សំណាង សុខមាលភាព ត្រេឌីង** ១៤៦៩

១៥-១២-២០១០ -លិខិតបញ្ជាក់លេខ ៥៦៦២ ពណ.ចបព ស្តីពី ការទទួលចុះបញ្ជីនូវការកែប្រែនិង តំកល់ទុកលក្ខន្តិកៈថ្មីរបស់ក្រុមហ៊ុន **អេថើ គ្លរី ត្រេឌីង អ៊ីមផត អិចផត** ១៤៧១

១៥-១២-២០១០ -លិខិតបញ្ជាក់លេខ ៥៦៦៧ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **សម្បត្តិ ចំរើន សុខ អ៊ិនវេសមេន** ១៤៧៣

១៥-១២-២០១០ -លិខិតបញ្ជាក់លេខ ៥៦៦៨ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ជីអិមស៊ីអេស ហ័ង ហ្វាត ខេបិល (ខេមបូឌា)** ១៤៧៥

# ព្រះរាជក្រឹត្យ

នស/រកត/០២១២/០៥៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** ត្រូវបានតែងតាំងឯកឧត្តម **ជា អួន ជាអនុរដ្ឋលេខាធិការ** នៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ។

**មាត្រា២ :** បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៣ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា៤ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ២០១២*

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**
**ប្រមុខរដ្ឋស្តីទី**
**ហត្ថលេខា និងព្រះរាជលញ្ឆករ**
**សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម**

៣ ៤ស. ១២០២.០៦១

លេខៈ ៧៩ ប.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ... ឆ្នាំ២០១២
... រាជរដ្ឋាភិបាល
... សុខា

# ព្រះរាជក្រឹត្យ

នស/រកត/០២១២/០៥៧

យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/សន/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** ត្រូវបានប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ចំនួន ០២ រូប នៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ដូចមានរាយនាមខាងក្រោម :

១- ឯកឧត្តម **សេង សត្ថា** ឱ្យបំពេញមុខងារជាអគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅ

២- ឯកឧត្តម **កែវ ស៊ីវន** ឱ្យបំពេញមុខងារជាអគ្គនាយក នៃអគ្គនាយកដ្ឋានបច្ចេកទេស ។

**មាត្រា២ :** បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៣ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា៤ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ២០១២*

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**
**ប្រមុខរដ្ឋស្តីទី**

៣៧៩.១២០២.០៦២

**ហត្ថលេខា និងព្រះរាជលញ្ឆករ**
**សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម**

ដើម្បីចម្លងចែកផ្សាយ
រាជធានីភ្នំពេញ ... ខែ កុម្ភៈ ឆ្នាំ២០១២
... សុខា

# ព្រះរាជក្រឹត្យ

នស/រកត/០២១២/០៩៣

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងផែនការ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ត្រូវបានតែងតាំង ឯកឧត្តម **នៃ បូរ** ជាទីប្រឹក្សាក្រសួងផែនការមានឋានៈស្មើអគ្គនាយក ។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ពរស. ១២០២.០៩៧

ធ្វើនៅព្រះបរមរាជវាំង. ថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០១២

លេខៈ ១០៩ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ២០១២
អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល

ស៊យ សុខា

# ព្រះរាជក្រឹត្យ

នស/រកត/០២១២/០៩៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

## ប្រោសព្រះរាជទាន

ចំពោះ

ថ្នាក់ដឹកនាំនៃក្រុមហ៊ុនធានារ៉ាប់រងបន្តកម្ពុជា ចំនួន ០៧រូប ដែលមានស្នាដៃល្អ
ក្នុងការរួមចំណែករកចំណូលថវិកាជាតិ និងបំរើជាតិមាតុភូមិ តាមកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល

នូវ

**ក-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា :**

១-ឯកឧត្តម រស់ សីលវ៉ា
២-ឯកឧត្តម កើត រិទ្ធ
៣-ឯកឧត្តម អ៊ឹម ស៊ីថុល
៤-លោក ឆាយ រតនៈ
៥-លោក នេត មុន្នី

**ខ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ :**

១-លោក វ័ន្ត ឋាសនា
២-លោក ឌី អាទិត្យ

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ពរល.១២០២.០៩៩

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១២

លេខ ១០៥ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ២០១២
អគ្គលេខាធិការនៃទីស្តីការគណៈរដ្ឋមន្ត្រី និងរាជរដ្ឋាភិបាល

សយ សុខា

# ព្រះរាជក្រឹត្យ

នស/រកត/០២១២/០៩៦

## យើង

**ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ដ្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ដ្រ ព្រះចៅក្រុងកម្ពុជាធិបតី**

## ប្រោសព្រះរាជទាន

ចំពោះ

សប្បុរសជន ចំនួន ០២រូប ដែលមានស្នាដៃល្អ ក្នុងការជួយកសាង អគារសិក្សា ចំនួន ០២ខ្នង មាន១២បន្ទប់ នៅក្នុងខេត្តព្រះវិហារ សម្រេចបានលទ្ធផលល្អប្រសើរ

នូវ

**គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេរីវឌ្ឍន៍**

១- លោក ចិន ង៉ុក ធន់ (TRAN NGOC THUAN)
២- ឧកញ៉ា ឡេង ឫទ្ធី

៣៩៩.១២០២.១០១

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ៤០ ខែ កុម្ភៈ ឆ្នាំ ២០១២

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្ដម សីហមុនី**

លេខៈ ១០៧ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ២០១២
អគ្គលេខាធិការរងទី១រាជរដ្ឋាភិបាល

សយ សុខា

# ព្រះរាជក្រឹត្យ

នស/រកត/០២១២/០៩៤

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

## ប្រោសព្រះរាជទាន

**ចំពោះ**

ថ្នាក់ដឹកនាំនិងមន្ត្រីរាជការនៃក្រុមការងារក្រសួងយុត្តិធម៌ ចំនួន០៦រូប បានខិតខំប្រឹងប្រែងជាច្រើនឆ្នាំក្នុងកិច្ចសហការជាមួយអ្នកជំនាញក្រមរដ្ឋប្បវេណីប្រទេសជប៉ុន និងសម្រេចបានល្អប្រសើរលើគម្រោងកសាងក្រមរដ្ឋប្បវេណី និងច្បាប់ពាក់ព័ន្ធនៃព្រះរាជាណាចក្រកម្ពុជា

**នូវ**

**គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា**

១-ឯកឧត្តម ប៊ុន ហុន
២-ឯកឧត្តម កើត រិទ្ធ
៣-ឯកឧត្តម យាន ស៊ីណា
៤-ឯកឧត្តម ឆ្លូង សំគី
៥-លោក ម៉ុង មុន្នីចរិយា
៦-លោក យូរ ឧត្តរា

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ចាស.១២០២.១០៣

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១២

លេខៈ ១០៦ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ២០១២
**អគ្គលេខាធិការរងទី១រាជរដ្ឋាភិបាល**
**ស៊ុយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០២១២/០៩៩

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

## ប្រោសព្រះរាជទាន

**ចំពោះ**

ប្រធានក្រុមហ៊ុន មេគង្គណិត និងក្រុមហ៊ុនអាណាណាកុំព្យូទ័រ ចំនួន០២រូប ដែលបានខិតខំប្រឹងប្រែង
អស់ពីកម្លាំងកាយចិត្តនិងចំណាយថវិកា ឧបករណ៍បច្ចេកទេស ក្នុងការរៀបចំបំពាក់បន្ថែមនូវអ៊ីនធឺណិតផ្កាហ្វា
មជ្ឈមណ្ឌលបណ្តុះបណ្តាលព័ត៌មានវិទ្យា និងបង្កើតគេហទំព័រសម្រាប់វិទ្យាល័យ ប៊ុន រ៉ានី ហ៊ុន សែន មេមត់ ខេត្តកំពង់ចាម

**នូវ**

## គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេរីវឌ្ឍន៍

**១-អ្នកស្រី សុខ ចាន់ដា**
**២-លោក ស្រៀង ឌីតូ**

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

នសរកត.១២០២.១០៤

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១២

លេខៈ ១០៥ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ កុម្ភៈ ឆ្នាំ២០១២
**អគ្គ[illegible]រាជរដ្ឋាភិបាល**

**ស៊យ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០២១២/១០០

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ ៖** ត្រូវបានតែងតាំងឯកឧត្តម **តេម សុខុន** ជាទីប្រឹក្សាអមទីស្តីការគណៈរដ្ឋមន្ត្រី មានឋានៈស្មើរដ្ឋលេខាធិការ។

**មាត្រា ២៖** បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៣៖** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

**មាត្រា ៤៖** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣រេ. ១២០៤.១០៥

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១២

លេខៈ ១៦ ៤ ច.ល
ដើម្បីចម្លងចែកជូន
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០១២
អគ្គលេខាធិការរាជរដ្ឋាភិបាល
[illegible] សុខា

# ព្រះរាជក្រឹត្យ

នស/រកត/០២១២/១០១

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២០៩/១៧៣ ចុះថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០០៩ ស្តីពីការបង្កើតក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ត្រូវបានបញ្ចប់មុខតំណែងឯកឧត្តម **ឃី ឆាន់រ៉ា** និងឯកឧត្តម **សួស តិកខៀប** ពីសមាជិកអចិន្ត្រៃយ៍ នៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ តាមសំណើរបស់សាមីខ្លួន។

**មាត្រា ២:** ត្រូវបានបញ្ចប់មុខតំណែងឯកឧត្តម **ខូន តាំងលាង** ពីសមាជិកមិនអចិន្ត្រៃយ៍ នៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌។

**មាត្រា ៣:** ត្រូវបានតែងតាំងសមាជិកអចិន្ត្រៃយ៍ នៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ចំនួន ០២រូប ដូចមានរាយនាមខាងក្រោម ÷

១. ឯកឧត្តម **ឆេស អែតជា** មានឋានៈស្មើ អនុរដ្ឋលេខាធិការ
២. ឯកឧត្តម **ម៉ែន សុវណ្ណា** មានឋានៈស្មើ អនុរដ្ឋលេខាធិការ។

**មាត្រា ៤ :** ត្រូវបានតែងតាំងសមាជិកមិនអចិន្ត្រៃយ៍ នៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ចំនួន ០២រូប ដូចមានរាយនាមខាងក្រោម ÷

១. ឯកឧត្តម **អ៊ុន ខ៉ាល់ឡឺរ៉ូ** មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន
២. ឯកឧត្តម **ញិម ច័ន្ទថេត** មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន។

ROYAUME du CAMBODGE · LE MINISTRE du PALAIS ROYAL

**មាត្រា ៥ :** បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៦ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

**មាត្រា ៧ :** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

នសរកត.១២០២.១០៦

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១២

លេខ: ១០៣ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ២០១២
[illegible]រងទីរាជរដ្ឋាភិបាល

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០២១២/១០៣

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

**ប្រោសព្រះរាជទាន**

ចំពោះ

សប្បុរសជន ចំនួន ០៣ រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនជួយកសាងសមិទ្ធផលនានា
ក្នុងវិស័យព្រះពុទ្ធសាសនា នៅក្នុងខេត្តបន្ទាយមានជ័យ

នូវ

គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **មហាសេនា** :

១- ឯកឧត្តម **គ្រី ឈាងហ្គួត**
២- លោក **អ៊ឹង ម៉ិនអៀង**
៣- លោក **សេង គី**

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣រស. ១២០៧. ១០៥

*ធ្វើនៅព្រះបរមរាជវាំង . ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១២*

លេខ: ១៦០ ប.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ កុម្ភៈ ឆ្នាំ២០១២
អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល

សយ សុខា

# ព្រះរាជក្រឹត្យ

នស/រកត/០២១២/១០៤

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

**ប្រោសព្រះរាជទាន**

**នូវ**

**គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា**

ចំពោះ

លោកវរសេនីយ៍ឯក ទេព សុខណ្ណដារ៉ា

ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនជួយកសាងអគារទីចាត់ការ ០១ ខ្នង
នៅសាលាបឋមសិក្សា **ហ៊ុន សែន សូភី** ក្នុងខេត្តបន្ទាយមានជ័យ

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣រទ.១២០២.១០៩

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១២

លេខ [illegible]០១ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ [illegible] ខែ [illegible] ម្ភៈ ឆ្នាំ២០១២
[illegible] រដ្ឋាភិបាល

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០២១២/១០៥

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

ប្រោសព្រះរាជទាន

ចំពោះ

នាយទាហាន អគ្គនាយកដ្ឋានភស្តុភារ ហិរញ្ញវត្ថុ ក្រសួងការពារជាតិ ចំនួន ៦៩ រូប មានស្នាដៃល្អក្នុងការកសាងសាលារៀន មន្ទីរពេទ្យ ផ្លូវ ស្ពាន និងគបណ្តាញទឹក នៅចំណុចខ្ពស់តាម ព្រំដែន កម្ពុជា ថៃ

នូវ

**ក-គ្រឿងឥស្សរិយយស សេនាជ័យសិទ្ធ :**

| | | | |
|---|---|---|---|
| ១-ឧត្តមសេនីយ៍ទោ | **ឆ្វូ** | **ផាន់សារី** | អត្តលេខ ០០០៦១៣ |
| ២-ឧត្តមសេនីយ៍ទោ | **សិរិ** | **តាក់តើ** | អត្តលេខ ០០១១៥៨ |
| ៣-ឧត្តមសេនីយ៍ទោ | **ជា** | **សំអឿន** | អត្តលេខ ០០២១៣៧ |
| ៤-ឧត្តមសេនីយ៍ទោ | **អ៊ូ** | **ផាន់ឌី** | អត្តលេខ ០០០៦១២ |
| ៥-ឧត្តមសេនីយ៍ទោ | **សោម** | **សុដេត** | អត្តលេខ ០១០៩២៨ |
| ៦-ឧត្តមសេនីយ៍ទោ | **ខ៊ែត** | **សុវណ្ណារ័ត្ន** | អត្តលេខ ០០១៥៧៩ |
| ៧-ឧត្តមសេនីយ៍ទោ | **ប៊ូ** | **គឹមថេង** | អត្តលេខ ០០២៧៣១ |
| ៨-ឧត្តមសេនីយ៍ទោ | **សឿន** | **រឿត** | អត្តលេខ ០០១៧២១ |
| ៩-ឧត្តមសេនីយ៍ទោ | **គន់** | **គឹមប៉ែន** | អត្តលេខ ០០២១៤៤ |
| ១០-ឧត្តមសេនីយ៍ត្រី | **គឹម** | **ឌុច** | អត្តលេខ ០០១៣៧៥ |
| ១១-ឧត្តមសេនីយ៍ត្រី | **ប៉ុល** | **សុគុណា** | អត្តលេខ ០០១៧៤៨ |
| ១២-ឧត្តមសេនីយ៍ត្រី | **ជា** | **ស៊ីថន** | អត្តលេខ ០០៨៥២២ |

**ខ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ :**

| | | | |
|---|---|---|---|
| ១-វរសេនីយ៍ឯក | **សាន** | **កុសល** | អត្តលេខ ០០១៧៣៩ |

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

២-វរសេនីយ៍ឯក **ខៀម ចាន់នៅ** អត្តលេខ ០១៨១៩៩

៣-វរសេនីយ៍ឯក **គង់ ជាំ** អត្តលេខ ០១៨២១១

**គ-គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់មហាសេរីវឌ្ឍន៍** :

១-ឧត្តមសេនីយ៍ឯក **ខ៉ែត នរិន្ទ្រ** អត្តលេខ ០០០២៣៧

២-ឧត្តមសេនីយ៍ឯក **សោម សុធា** អត្តលេខ ០០០២៨៣

៣-ឧត្តមសេនីយ៍ទោ **ខឹម សុខ** អត្តលេខ ០០០៦១១

**ឃ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា** :

១-វរសេនីយ៍ឯក **ចិន ចណ្ណាះ** អត្តលេខ ០៤៣៥២០

២-វរសេនីយ៍ឯក **ជា ឧត្តី** អត្តលេខ ០១៨១៨៦

៣-វរសេនីយ៍ឯក **សោម សុធី** អត្តលេខ ០៣១៦១២

៤-វរសេនីយ៍ទោ **ហាយ ហ៊ីង** អត្តលេខ ០២៥១៨៩

៥-វរសេនីយ៍ទោ **ទង់ សំអាត** អត្តលេខ ១៩៨៦៩៣

**ង-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ** :

១-វរសេនីយ៍ឯត **អ៊ុន ប៉ូលី** អត្តលេខ ០០១៧២៣

២-វរសេនីយ៍ឯក **និត្យ សុវណ្ណតារា** អត្តលេខ ០១៨១៩៥

៣-វរសេនីយ៍ឯក **ហ៊ុយ ផលឧត្តរី** អត្តលេខ ០០១៧៣៤

៤-វរសេនីយ៍ឯក **កែវ កម្ពុជា** អត្តលេខ ០០១៧៣១

៥-វរសេនីយ៍ឯក **ខាត់ សុផល** អត្តលេខ ០០១៧២២

៦-វរសេនីយ៍ឯក **នរិន្ទ្រ រិទ្ធ** អត្តលេខ ១៩៨៧០២

៧-វរសេនីយ៍ឯក **សួស សុគុណា** អត្តលេខ ០៣១២៦៦

៨-វរសេនីយ៍ឯក **លឹម ចាន់ឫទ្ធី** អត្តលេខ ០២៥១៨២

៩-វរសេនីយ៍ទោ **តួច ផា** អត្តលេខ ០០៣៥៦៦

១០-វរសេនីយ៍ទោ **ហៀង គឹមម៉េង** អត្តលេខ ០១៨១៩៧

១១-វរសេនីយ៍ទោ **នុត ច័ន្ទតារា** អត្តលេខ ០២៥២១៤

១២-វរសេនីយ៍ទោ **គល់ ចំរើន** អត្តលេខ ០៣១៨០៦

១៣-វរសេនីយ៍ទោ **ម៉ុក សារឿន** អត្តលេខ ១៩៨៧០១

១៤-វរសេនីយ៍ទោ **ខេង សាវុធ** អត្តលេខ ០០៨៥៨៣

១៥-វរសេនីយ៍ទោ **អ៊ូច ឧត្តរី** អត្តលេខ ០៦៧៩៥១

១៦-វរសេនីយ៍ត្រី **នាន់ ប៊ូរ៉េត** អត្តលេខ ០២៩៨៨០

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**ច. គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា :**

១-វរសេនីយ៍ឯក **ថេង ដា** អត្តលេខ ០១៤២១៣

២-វរសេនីយ៍ឯក **សួស ផានី** អត្តលេខ ០១៤១៩៣

៣-វរសេនីយ៍ឯក **លី ម៉ិនឆាយ** អត្តលេខ ០០០៩៧៥

៤-វរសេនីយ៍ឯក **ហួន ចណ្ណឌី** អត្តលេខ ០១៧១៧៨

៥-វរសេនីយ៍ទោ **ឃី ហាន** អត្តលេខ ០០១៧៤១

៦-វរសេនីយ៍ទោ **ឆុយ ផារ៉ុម** អត្តលេខ ០១១២៣១

៧-វរសេនីយ៍ទោ **កែម សុផា** អត្តលេខ ០០១៧៤៩

៨-វរសេនីយ៍ទោ **ម៉ិញ សារ៉ន** អត្តលេខ ០១៤១៨៧

៩-វរសេនីយ៍ទោ **ដួង សុផាត** អត្តលេខ ០១៤១៦៥

១០-វរសេនីយ៍ទោ **អឿន ពិសិដ្ឋ** អត្តលេខ ០១២៣៥៤

១១-វរសេនីយ៍ទោ **អៀ សុខអៀង** អត្តលេខ ០៤៣៤២២

**ឆ. គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិ :**

១-វរសេនីយ៍ឯក **ហាម សុធី** អត្តលេខ ០០១៥១៨

២-វរសេនីយ៍ទោ **រស់ សុជាតិ** អត្តលេខ ០១៤១៦៧

៣-វរសេនីយ៍ទោ **ញឹម ចណ្ណថេត** អត្តលេខ ០១៣៨៤៣

៤-វរសេនីយ៍ទោ **សុខ សេរី** អត្តលេខ ០១៤១៧៤

៥-វរសេនីយ៍ទោ **ឡុក ឡេងហួន** អត្តលេខ ០៤៣៥២១

៦-វរសេនីយ៍ទោ **លឹម ធី** អត្តលេខ ០០៨៥៣៤

៧-វរសេនីយ៍ទោ **ឆន ច័ន្ទតារា** អត្តលេខ ០១៧៦៨៥

៨-វរសេនីយ៍ត្រី **សុខ ចំរើន** អត្តលេខ ០៤៣៥១៩

៩-វរសេនីយ៍ត្រី **គឹម វ៉ុង** អត្តលេខ ២២១៩១៣

១០-វរសេនីយ៍ត្រី **សារុំ រ៉ាដេត** អត្តលេខ ០៣១៣៦៤

១១-វរសេនីយ៍ត្រី **អ៊ិន សុចឡ្យណា** អត្តលេខ ១៩៨៧០០

១២-វរសេនីយ៍ត្រី **ឌិន សាន** អត្តលេខ ០២៥១៦៦

១៣-វរសេនីយ៍ត្រី **នូ សុខន** អត្តលេខ ១៥៨៤៧៥

១៤-វរសេនីយ៍ត្រី **ខាត់ ដួច** អត្តលេខ ០១៤២១៦

១៥-វរសេនីយ៍ត្រី **ស្រី គំសាន្ត** អត្តលេខ ០១៤១៩៦

១៦-វរសេនីយ៍ត្រី **អ៊ុក ពុធរស្មី** អត្តលេខ ០២៥១៥២

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

| | | | |
|---|---|---|---|
| ១៧-ស្រសេនីយ៍ត្រី | **លាច** | **លីមុន** | អត្តលេខ ០៧៨៥២៥ |
| ១៨-ស្រសេនីយ៍ត្រី | **សុខ** | **សំណាង** | អត្តលេខ ១៣៧២២៤ |
| ១៩-ស្រសេនីយ៍ត្រី | **ចាន់** | **សុខ** | អត្តលេខ ០១៩១៩០ |

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ព.ច.ល. ១២០២.១១០

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ២០១២*

លេខ: ១១០ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ២០១២
អគ្គលេខាធិការរងទី១ រាជរដ្ឋាភិបាល

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០២១២/១០៦

**យើង**

**ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ដ្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្ដិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ដ្រ ព្រះចៅក្រុងកម្ពុជាធិបតី**

**ប្រោសព្រះរាជទាន**

**នូវ**

**គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេរីវឌ្ឍន៍**

**ចំពោះ**

**លោក គឹម រតនា**

នាយកប្រតិបត្តិ អង្គការការីតាសកម្ពុជា ដែលមានស្នាដៃល្អប្រសើរ ដោយបានរួមសហការអនុវត្តការងារ ជួយប្រជាពលរដ្ឋ ដែលរងគ្រោះដោយទឹកជំនន់ នៅតាមបណ្ដាខេត្តមួយចំនួន ក្នុងព្រះរាជាណាចក្រកម្ពុជា កាលពីឆ្នាំ២០១១ កន្លងមក

**ព្រះហស្ដលេខា និងព្រះរាជលញ្ឆករ**
**នរោត្ដម សីហមុនី**

៣៦លា. ១២០២. ១១១

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១២

លេខៈ ១២៧ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ២០១២
អគ្គលេខាធិការរងទីស្តីការរាជរដ្ឋាភិបាល
ស៊ុយ សុខា

# ព្រះរាជក្រឹត្យ

នស/រកត/០២១២/១០៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

នូវ

គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា

ប្រគេន ចំពោះ

ព្រះគ្រូ មឿន មឿន

ព្រះចៅអធិការវត្តពានា ដែលមានស្នាព្រះហស្តល្អ ព្រមទាំងបរិច្ចាគធនធានផ្ទាល់ខ្លួន រួមចំណែកកសាង និងអភិវឌ្ឍន៍សមិទ្ធផលផ្សេងៗ លើវិស័យសង្គមកិច្ច និងវិស័យព្រះពុទ្ធសាសនា មានព្រះវិហារ ឧបដ្ឋានសាលា របងវត្ត កុដិ ស្ថិតនៅក្នុងវត្តពានា ឃុំអំពិលក្រៅ ស្រុកស៊ីធរកណ្តាល ខេត្តព្រៃវែង

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៩៧.១២០២.១១២

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០១២

លេខៈ ១២៥ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ... ខែ កុម្ភៈ ឆ្នាំ២០១២
... ទីស្តីការរាជរដ្ឋាភិបាល
... សុខា

# ព្រះរាជក្រឹត្យ

នស/រកត/០២១២/១០៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពោហនាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៩០៨ / ១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦ / នស / ៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៤០១/០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ត្រូវបានដំឡើងឋានន្តរស័ក្តិជូនឯកឧត្តម សុក ដា ពីរមន្ត្រីការបរទេស ថ្នាក់លេខ៦ ទៅឧត្តមមន្ត្រីការបរទេស ថ្នាក់លេខ៦ នៃក្របខណ្ឌមន្ត្រីការទូតជាន់ខ្ពស់ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។

**មាត្រា ២:** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

**មាត្រា ៣:** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

ចរល.១៤០២.១១៧

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១២

លេខៈ ១១៦ ហ.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ កុម្ភៈ ឆ្នាំ២០១២
អគ្គលេខាធិការរងរាជរដ្ឋាភិបាល
[illegible]

# ព្រះរាជក្រឹត្យ

នស/រកត/០២១២/១០៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** ត្រូវបានដំឡើងឋានន្តរស័ក្តិមន្ត្រីរាជការ ពីវរមន្ត្រី ទៅឧត្តមមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

| | | | |
|---|---|---|---|
| ១ | ឯកឧត្តម **សុខ សឿន** | ពីវរមន្ត្រី ថ្នាក់លេខ ៦ | ទៅឧត្តមមន្ត្រី ថ្នាក់លេខ ៦ |
| ២ | លោកជំទាវ **សួស ណារ៉ា** | ពីវរមន្ត្រី ថ្នាក់លេខ ៧ | ទៅឧត្តមមន្ត្រី ថ្នាក់លេខ ៦ |

**មាត្រា២ :** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា៣ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួល អនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា៤ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០១២

រាជធានីភ្នំពេញ ... ខែ ... ឆ្នាំ២០១២

... សុខា

# ព្រះរាជក្រឹត្យ

នស/រកត/០២១២/១១០

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រតនខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

**ប្រោសព្រះរាជទាន**

**នូវ**

**គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា**

ប្រគេន ចំពោះ

ព្រះតេជគុណ អួន ធឿន

ព្រះគ្រូចៅអធិការវត្ត និងជាអនុគណស្រុកឧដុង្គ មានព្រះគុណបំណាច់ និងស្នាព្រះហស្តល្អ
ដោយបានបរិច្ចាគបច្ច័យ ចូលរួមក្នុងការកសាងសមិទ្ធផលជាច្រើនលើវិស័យព្រះពុទ្ធសាសនា
នៅវត្តធ្លាចាស់ ឃុំវាលពង់ ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ចរទស.១២០២-១១៥

ធ្វើនៅព្រះបរមរាជវាំង . ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១២

លេខ ១១៨ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ [illegible] ៤ ខែ កុម្ភៈ ឆ្នាំ២០១២
[illegible]រដ្ឋាភិបាល
សយ សុខា

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ១៨ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការរៀបចំ និងការប្រព្រឹត្តទៅ

## របស់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៨/០០៣ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីអាកាសចរស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- តាមសំណើរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

## សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះ កំណត់ការរៀបចំបណ្តាអង្គភាពនៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល និងកំណត់បេសកកម្មរបស់រដ្ឋលេខាធិការដ្ឋាន និងមុខងារនៃអគ្គនាយកដ្ឋាន នាយកដ្ឋាន អង្គភាព មជ្ឈមណ្ឌលហ្វឹកហ្វឺន និងអាកាសយានដ្ឋានស៊ីវិល។

## ជំពូកទី ២
## បេសកកម្ម និងរចនាសម្ព័ន្ធ

**មាត្រា ២.-**

រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ត្រូវបាននាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ប្រគល់បេសកកម្មឲ្យដឹកនាំ និងគ្រប់គ្រងវិស័យអាកាសចរស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា ៣.-**

រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល មានមុខងារ និងភារកិច្ចដូចតទៅៈ

- រៀបចំ និងអនុវត្តគោលនយោបាយជាតិស្តីពីវិស័យអាកាសចរស៊ីវិល ដោយរៀបចំគោលការណ៍ច្បាប់ និងសហការជាមួយស្ថាប័ននានា ដើម្បីអភិវឌ្ឍវិស័យអាកាសចរស៊ីវិល
- ចងក្រង និងរៀបចំតាក់តែងច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងបទប្បញ្ញត្តិ ដែលពាក់ព័ន្ធដល់ការគ្រប់គ្រងអាកាសចរស៊ីវិលជាតិនិងអន្តរជាតិ ព្រមទាំងតាមដានលើការអនុវត្ត
- ធានាផ្តល់សេវាកម្មលើការងារត្រួតពិនិត្យចរាចរដែនអាកាស គ្រប់គ្រងការប្រើប្រាស់ដែនអាកាស ទូរគមនាគមន៍អាកាសចរណ៍ កំណត់តំបន់ហាមឃាត់ ធានាសេវាកម្មឧតុនិយមអាកាសចរស៊ីវិល និងសេវាកម្មផ្សេងៗទៀត ដែលជាសមត្ថកិច្ចរបស់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- រៀបចំបទប្បញ្ញត្តិ បទបញ្ជា និងត្រួតពិនិត្យការដឹកជញ្ជូនតាមផ្លូវអាកាសរបស់សហគ្រាសដឹកជញ្ជូនតាមផ្លូវអាកាស
- ពិនិត្យ និងផ្តល់វិញ្ញាបនបត្រប្រតិបត្តិការផ្លូវអាកាស ដល់ក្រុមហ៊ុនសេវាកម្មអាកាសចរណ៍ និងអាជ្ញាប័ណ្ណដល់ក្រុមអាកាសយានិក អ្នកបច្ចេកទេសពោងជាង អ្នកបច្ចេកទេសថែរក្សាអាកាសយាន ព្រមទាំងធ្វើការចុះបញ្ជីអាកាសយានស៊ីវិលគ្រប់ប្រភេទ
- គ្រប់គ្រងប្រព័ន្ធអេឡិចត្រូនិក ដែលបម្រើឲ្យសេវាកម្មចរាចរដែនអាកាស និងសិក្សាពីតម្រូវការរបស់ប្រព័ន្ធ
- ធានាសន្តិសុខ និងសុវត្ថិភាពហោះហើរដល់សហគ្រាសដឹកជញ្ជូនតាមផ្លូវអាកាសជាតិ និងអន្តរជាតិ ដែលធ្វើសេវាកម្មនៅក្នុង ចេញ-ចូល និងឆ្លងកាត់ព្រះរាជាណាចក្រកម្ពុជា
- គ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្សក្នុងវិស័យអាកាសចរស៊ីវិល ឲ្យស្របតាមតម្រូវការ និងស្តង់ដាររបស់អង្គការអាកាសចរស៊ីវិលអន្តរជាតិ
- រៀបចំមជ្ឈមណ្ឌលហ្វឹកហ្វឺន ផែនការហ្វឹកហ្វឺន និងធ្វើការបណ្តុះបណ្តាលជំនាញបច្ចេកទេសអាកាសចរស៊ីវិលនៅនឹងកន្លែង ឲ្យស្របតាមតម្រូវការ និងឆ្លើយតបបានតាមច្បាប់ និងបទប្បញ្ញត្តិស្តីពីអាកាសចរស៊ីវិលជាតិនិងអន្តរជាតិ
- ចេញបទប្បញ្ញត្តិស្តីពីអាកាសចរស៊ីវិល កម្រងនីតិវិធីប្រតិបត្តិ និងសេចក្តីកំណត់ ដោយយោងតាមច្បាប់ស្តីពីអាកាសចរស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា និងស្តង់ដានិងអនុសាសន៍របស់អង្គការអាកាសចរស៊ីវិលអន្តរជាតិជាមូលដ្ឋាន ព្រមទាំងផ្សព្វផ្សាយ និងអនុវត្តវិធានការសន្តិសុខ និងសុវត្ថិភាព
- គ្រប់គ្រងអាកាសយានដ្ឋានស៊ីវិល និងហេដ្ឋារចនាសម្ព័ន្ធសំណង់
- ចេញវិញ្ញាបនបត្រអាកាសយានដ្ឋាន និងត្រួតពិនិត្យការប្រតិបត្តិរបស់ប្រតិបត្តិករអាកាសយានដ្ឋាន
- គ្រប់គ្រងការងារជួសជុល ថែទាំ កែលម្អ ការធ្វើនីតិសម្បទា ការអភិវឌ្ឍ និងការសាងសង់អាកាសយានដ្ឋាន ដែលទទួលខុសត្រូវដោយរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ព្រមទាំងតាមដានគម្រោងការអភិវឌ្ឍអាកាសយានដ្ឋានមូលដ្ឋាន និងអន្តរជាតិ

- ចេញអាជ្ញាប័ណ្ណសម្រាប់ការអភិវឌ្ឍពង្រីកអាកាសយានដ្ឋាន និងការកសាងអាកាសយានដ្ឋានថ្មី បន្ទាប់ពីមានការយល់ព្រមពីរាជរដ្ឋាភិបាល
- កំណត់ភូមិសាស្ត្រ និងទីតាំងសម្រាប់ពង្រីកអាកាសយានដ្ឋានដែលមានស្រាប់ និងទីតាំងសម្រាប់កសាងអាកាសយានដ្ឋានថ្មី ព្រមទាំងកំណត់ព្រំខណ្ឌដីអាកាសយានដ្ឋាន
- រៀបចំកម្មវិធីជាតិស្តីពីសន្តិសុខអាកាសចរស៊ីវិល និងកម្មវិធីផ្សេងៗទៀត ដែលពាក់ព័ន្ធនឹងសន្តិសុខអាកាសចរស៊ីវិល ឲ្យស្របតាមស្តង់ដាជាតិនិងអន្តរជាតិ
- អនុវត្តច្បាប់ បទប្បញ្ញត្តិ លិខិតបទដ្ឋានគតិយុត្តជាតិនិងអន្តរជាតិ និងកម្មវិធីជាតិស្តីពីសន្តិសុខអាកាសចរស៊ីវិល
- ទទួលខុសត្រូវចំពោះការធ្វើសវនកម្មរបស់អង្គការអាកាសចរស៊ីវិលអន្តរជាតិ និងការធ្វើអធិការកិច្ចលើវិស័យអាកាសចរស៊ីវិល
- ស៊ើបអង្កេត និងវាយតម្លៃឧប្បត្តិហេតុ ឬគ្រោះថ្នាក់អាកាសចរណ៍ ដោយសហការជាមួយក្រសួងស្ថាប័នជាតិ និងអន្តរជាតិពាក់ព័ន្ធ
- ធ្វើផែនការ និងអនុវត្តចំណូល-ចំណាយថវិកា ឲ្យស្របតាមច្បាប់ហិរញ្ញវត្ថុ
- ផ្សព្វផ្សាយការងារបច្ចេកទេសពាក់ព័ន្ធនឹងវិស័យអាកាសចរស៊ីវិល
- ធ្វើរបាយការណ៍ពីសកម្មភាពរបស់ខ្លួនតាមកាលកំណត់ជូនរាជរដ្ឋាភិបាល
- អនុវត្តភារកិច្ចផ្សេងទៀត ដែលរាជរដ្ឋាភិបាលប្រគល់ជូន។

**មាត្រា ៤.-**

រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល មានរចនាសម្ព័ន្ធដូចតទៅ÷

- អគ្គនាយកដ្ឋានបច្ចេកទេស
- អគ្គនាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅ
- ខុទ្ទកាល័យ
- អង្គភាពស៊ើបអង្កេតគ្រោះថ្នាក់អាកាសចរណ៍ ថ្នាក់ស្មើនាយកដ្ឋាន
- នាយកដ្ឋានសេវាកម្មអាកាសចរណ៍
- អាកាសយានដ្ឋានអន្តរជាតិ ថ្នាក់ស្មើនាយកដ្ឋាន
- នាយកដ្ឋានដឹកជញ្ជូនតាមផ្លូវអាកាស
- នាយកដ្ឋានទំនាក់ទំនងអន្តរជាតិ និងនីតិកម្ម
- មជ្ឈមណ្ឌលហ្វឹកហ្វឺនអាកាសចរស៊ីវិល ថ្នាក់ស្មើនាយកដ្ឋាន
- អាកាសយានដ្ឋានមូលដ្ឋាន ថ្នាក់ស្មើការិយាល័យ

អង្គការលេខរបស់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ជាឧបសម្ព័ន្ធរបស់អនុក្រឹត្យនេះ។

## ជំពូកទី ៣
## អគ្គនាយកដ្ឋានបច្ចេកទេស

**មាត្រា ៥.-**

អគ្គនាយកដ្ឋានបច្ចេកទេសមានភារកិច្ចដឹកនាំ សម្របសម្រួល និងគ្រប់គ្រងសកម្មភាពលើការងារស្តង់ដានិងសុវត្ថិភាពហោះហើរ លទ្ធភាពហោះហើរ ស្តង់ដានិងសុវត្ថិភាពនាំផ្លូវអាកាស ស្តង់ដានិងសុវត្ថិភាពអាកាសយានដ្ឋាន ការងារសន្តិសុខអាកាសចរស៊ីវិល និងត្រួតពិនិត្យសន្តិសុខនិងសុវត្ថិភាពអាកាសចរណ៍។

**មាត្រា ៦.-**

អគ្គនាយកដ្ឋានបច្ចេកទេស ដឹកនាំដោយអគ្គនាយកមួយរូប អមដោយអគ្គនាយករងមួយចំនួនជាជំនួយការ តាមការចាំបាច់។

អគ្គនាយកដ្ឋានបច្ចេកទេសមាននាយកដ្ឋានចំណុះចំនួន០៦ (ប្រាំមួយ) ដូចខាងក្រោម÷

- នាយកដ្ឋានស្តង់ដា និងសុវត្ថិភាពហោះហើរ
- នាយកដ្ឋានលទ្ធភាពហោះហើរ
- នាយកដ្ឋានស្តង់ដា និងសុវត្ថិភាពនាំផ្លូវអាកាស
- នាយកដ្ឋានស្តង់ដា និងសុវត្ថិភាពអាកាសយានដ្ឋាន
- នាយកដ្ឋានសន្តិសុខអាកាសចរស៊ីវិល
- នាយកដ្ឋានត្រួតពិនិត្យ សន្តិសុខ និងសុវត្ថិភាពអាកាសចរណ៍។

**មាត្រា ៧.-**

នាយកដ្ឋានស្តង់ដា និងសុវត្ថិភាពហោះហើរ មានភារកិច្ចដូចតទៅ÷

- រៀបចំ និងចងក្រងបទប្បញ្ញត្តិ នីតិវិធី ស្តង់ដា តម្រូវការ សេចក្តីនិងសៀវភៅណែនាំ និងលិខិតបទដ្ឋានគតិយុត្តនានា ដែលទាក់ទងនឹងស្តង់ដានិងសុវត្ថិភាពហោះហើរ ឲ្យស្របតាមច្បាប់ និងបទប្បញ្ញត្តិអាកាសចរស៊ីវិលកម្ពុជា និងស្តង់ដានិងអនុសាសន៍របស់អង្គការអាកាសចរស៊ីវិលអន្តរជាតិ
- សហការរៀបចំបទប្បញ្ញត្តិ បទដ្ឋាន និងនីតិវិធីស្តីពីការកំណត់អាយុអាកាសយាន ដែលប្រើប្រាស់ក្នុងព្រះរាជាណាចក្រកម្ពុជា
- ពិនិត្យ និងវាយតម្លៃបច្ចេកទេសក្នុងការផ្តល់ ផ្អាក ដកហូត និងបន្តវិញ្ញាបនបត្រប្រតិបត្តិការផ្លូវអាកាស ចំពោះសហគ្រាសដឹកជញ្ជូនតាមផ្លូវអាកាសដែលកាន់វិញ្ញាបនបត្រប្រតិបត្តិការផ្លូវអាកាសរបស់កម្ពុជា
- ពិនិត្យ និងវាយតម្លៃបច្ចេកទេសក្នុងការផ្តល់ ផ្អាក ដកហូត និងបន្តលិខិតអនុញ្ញាតប្រតិបត្តិការហោះហើរនៃអាកាសយានគ្រប់ប្រភេទ ដែលហោះហើរនៅក្នុង ចេញ-ចូល និងឆ្លងកាត់ព្រះរាជាណាចក្រកម្ពុជា
- ផ្តល់វិញ្ញាបនបត្របញ្ជាក់សមត្ថភាពរបស់ក្រុមយានិក និងអ្នកបម្រើសេវាផ្សេងៗ ដែលបម្រើឲ្យប្រតិបត្តិការហោះហើរ វិភាគទិន្នន័យសុវត្ថិភាព និងត្រួតពិនិត្យប្រតិបត្តិការហោះហើរនៅក្នុង ចេញ-ចូល និងឆ្លងកាត់ព្រះរាជាណាចក្រកម្ពុជា
- ត្រួតពិនិត្យការធ្វើប្រតិបត្តិការគ្រប់អាកាសយានបរទេសដែលហោះហើរនៅក្នុង ចេញ-ចូល និងឆ្លងកាត់ព្រះរាជាណាចក្រកម្ពុជា
- សហការគ្រប់គ្រងលើការងាររុករក និងសង្គ្រោះ
- សហការស្រាវជ្រាវ និងវាយតម្លៃឧប្បត្តិហេតុ ឬគ្រោះថ្នាក់ពាក់ព័ន្ធដល់អាកាសយាននៅក្នុង និងក្រៅព្រះរាជាណាចក្រកម្ពុជា
- ទទួលខុសត្រូវចំពោះការធ្វើសវនកម្មរបស់អង្គការអាកាសចរស៊ីវិលអន្តរជាតិ

- ពិនិត្យ និងផ្តល់យោបល់លើការវាយតម្លៃបច្ចេកទេស ដែលទាក់ទងនឹងប្រតិបត្តិការ និងសុវត្ថិភាពហោះហើរ និងសុំការសម្រេចពីថ្នាក់ដឹកនាំរដ្ឋលេខាធិការដ្ឋាន
- ធ្វើរបាយការណ៍ពីសកម្មភាពការងាររបស់ខ្លួន
- អនុវត្តភារកិច្ចផ្សេងទៀត ដែលថ្នាក់ដឹកនាំរដ្ឋលេខាធិការដ្ឋានប្រគល់ជូន។

នាយកដ្ឋានស្តង់ដា និងសុវត្ថិភាពហោះហើរ ដឹកនាំដោយប្រធាននាយកដ្ឋានមួយរូប អមដោយអនុប្រធាននាយកដ្ឋានមួយចំនួនជាជំនួយការ តាមការចាំបាច់។

**មាត្រា ៨.-**

នាយកដ្ឋានលទ្ធភាពហោះហើរ មានភារកិច្ចដូចតទៅ៖

- រៀបចំ និងចងក្រងបទប្បញ្ញត្តិ នីតិវិធី ស្តង់ដា តម្រូវការ សេចក្តីនិងសៀវភៅណែនាំ និងលិខិតបទដ្ឋានគតិយុត្តនានា ដែលទាក់ទងនឹងការត្រួតពិនិត្យលទ្ធភាពហោះហើរ និងកិច្ចការពារបរិស្ថាន ឲ្យស្របតាមច្បាប់និងបទប្បញ្ញត្តិអាកាសចរស៊ីវិលកម្ពុជា និងស្តង់ដានិងអនុសាសន៍របស់អង្គការអាកាសចរស៊ីវិលអន្តរជាតិ
- រៀបចំបទប្បញ្ញត្តិ បទដ្ឋាន និងនីតិវិធីស្តីពីការកំណត់អាយុអាកាសយាន ដែលប្រើប្រាស់ក្នុងព្រះរាជាណាចក្រកម្ពុជា
- ពិនិត្យ និងវាយតម្លៃបច្ចេកទេសក្នុងការផ្តល់ ផ្អាក ដកហូត និងបន្តវិញ្ញាបនបត្រចុះបញ្ជីអាកាសយាន វិញ្ញាបនបត្រលទ្ធភាពហោះហើរ វិញ្ញាបនបត្របញ្ជាក់សមត្ថភាពវិស្វករនិងអ្នកជំនាញបច្ចេកទេសអាកាសយាន វិញ្ញាបនបត្រសំលេង អាជ្ញាប័ណ្ណវិទ្យុ វិញ្ញាបនបត្រកិច្ចសន្យាជួលអាកាសយាន ស្ថានីយ៍ប្រេងអាកាសយាន អង្គភាពជួសជុលថែរក្សាអាកាសយាន និងកម្មវិធីថែទាំអាកាសយាន
- ត្រួតពិនិត្យលទ្ធភាពហោះហើរចំពោះអាកាសយាន ដែលបានចុះបញ្ជីនៅព្រះរាជាណាចក្រកម្ពុជា
- សហការជាមួយនាយកដ្ឋានស្តង់ដា និងសុវត្ថិភាពហោះហើរ ក្នុងការផ្តល់ ផ្អាក ដកហូត និងបន្តវិញ្ញាបនបត្រប្រតិបត្តិការផ្លូវអាកាស
- សហការស្រាវជ្រាវ និងវាយតម្លៃឧប្បត្តិហេតុ ឬគ្រោះថ្នាក់ពាក់ព័ន្ធដល់អាកាសយាននៅក្នុង និងក្រៅព្រះរាជាណាចក្រកម្ពុជា
- ទទួលខុសត្រូវចំពោះការធ្វើសវនកម្មរបស់អង្គការអាកាសចរស៊ីវិលអន្តរជាតិ
- ពិនិត្យ និងផ្តល់យោបល់លើការវាយតម្លៃបច្ចេកទេស ដែលទាក់ទងនឹងការត្រួតពិនិត្យលទ្ធភាពហោះហើរ និងសុំការសម្រេចពីថ្នាក់ដឹកនាំរដ្ឋលេខាធិការដ្ឋាន
- ធ្វើរបាយការណ៍ពីសកម្មភាពការងាររបស់ខ្លួន
- អនុវត្តភារកិច្ចផ្សេងទៀត ដែលថ្នាក់ដឹកនាំរដ្ឋលេខាធិការដ្ឋានប្រគល់ជូន។

នាយកដ្ឋានលទ្ធភាពហោះហើរ ដឹកនាំដោយប្រធាននាយកដ្ឋានមួយរូប អមដោយអនុប្រធាននាយកដ្ឋានមួយចំនួនជាជំនួយការ តាមការចាំបាច់។

**មាត្រា ៩.-**

នាយកដ្ឋានស្តង់ដា និងសុវត្ថិភាពនាំផ្លូវអាកាស មានភារកិច្ចដូចតទៅ៖

- រៀបចំ និងចងក្រងបទប្បញ្ញត្តិ នីតិវិធី ស្តង់ដា តម្រូវការ សេចក្តីនិងសៀវភៅណែនាំ និងលិខិតបទដ្ឋានគតិយុត្តនានាដែលទាក់ទងនឹងស្តង់ដានិងសុវត្ថិភាពនាំផ្លូវអាកាស និងសេវាកម្មនាំផ្លូវអាកាសសម្រាប់អាកាសយានដែលធ្វើប្រតិបត្តិការហោះហើរនៅក្នុង ចេញ-ចូល និងឆ្លងកាត់ព្រះរាជាណាចក្រកម្ពុជា រួមមាន ការគ្រប់គ្រងចរាចរដែនអាកាស បទដ្ឋានហោះហើរ ការគ្រប់គ្រងព័ត៌មានឧតុនិយមនិងអាកាសចរវិទ្យា ការរុករកនិងសង្គ្រោះ ប្រព័ន្ធបរិក្ខារអេឡិចត្រូនិចនាំផ្លូវអាកាស

ប្រព័ន្ធទូរគមនាគមន៍ និងស្ថានីយ៍ផ្កាយរណប ឲ្យស្របតាមច្បាប់ និងបទប្បញ្ញត្តិអាកាសចរស៊ីវិលកម្ពុជា និងស្តង់ដានិងអនុសាសន៍របស់អង្គការអាកាសចរស៊ីវិលអន្តរជាតិ

- ពិនិត្យ និងវាយតម្លៃបច្ចេកទេសក្នុងការផ្តល់ ផ្អាក ដកហូត និងបន្តវិញ្ញាបនបត្រ ឬវិញ្ញាបនបត្របញ្ជាក់សមត្ថភាពក្រុមបញ្ជាហោះហើរ វិស្វករនិងអ្នកជំនាញនាំផ្លូវអាកាស និងមន្ត្រីផ្តល់ព័ត៌មានអាកាសចរវិទ្យា
- រៀបចំ និងបោះពុម្ពផ្សព្វផ្សាយសៀវភៅស្តីពីព័ត៌មានអាកាសចរវិទ្យា ដែលពាក់ព័ន្ធទៅនឹងលំហរអាកាសកម្ពុជា និងលំហរអាកាសដែលបានរក្សាទុកដល់កម្ពុជាក្រោមកិច្ចសហប្រតិបត្តិការ និងកិច្ចព្រមព្រៀងជាតិនិងអន្តរជាតិ ដោយមានការទទួលស្គាល់ ឬអនុញ្ញាតពីអង្គការអាកាសចរស៊ីវិលអន្តរជាតិ
- សហការសម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងការត្រួតពិនិត្យ និងគ្រប់គ្រងរលកសញ្ញាវិទ្យុអេឡិចត្រូនិច ដើម្បីជៀសវាងការរំខានដល់សេវាកម្មនាំផ្លូវអាកាស
- គ្រប់គ្រងចាត់ចែងប្រេកង់អាកាសចរណ៍ដោយទទួលសិទ្ធិពីអាជ្ញាធរទូរគមនាគមន៍ ស្របតាមការណែនាំរបស់សហភាពទូរគមនាគមន៍អន្តរជាតិ
- រៀបចំកិច្ចសន្យាជាមួយអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ ក្នុងការផ្តល់សេវាកម្មនាំផ្លូវអាកាស ដូចជាសេវាកម្មឧតុនិយម សេវាកម្មទូរគមនាគមន៍។ល។
- ទទួលខុសត្រូវចំពោះការធ្វើសវនកម្មរបស់អង្គការអាកាសចរស៊ីវិលអន្តរជាតិ
- ពិនិត្យ និងផ្តល់យោបល់លើការវាយតម្លៃបច្ចេកទេស ដែលទាក់ទងនឹងសុវត្ថិភាពសេវាកម្មនាំផ្លូវអាកាស និងសុំការសម្រេចពីថ្នាក់ដឹកនាំរដ្ឋលេខាធិការដ្ឋាន
- ធ្វើរបាយការណ៍ពីសកម្មភាពការងាររបស់ខ្លួន
- អនុវត្តភារកិច្ចផ្សេងទៀត ដែលថ្នាក់ដឹកនាំរដ្ឋលេខាធិការដ្ឋានប្រគល់ជូន។

នាយកដ្ឋានស្តង់ដា និងសុវត្ថិភាពនាំផ្លូវអាកាស ដឹកនាំដោយប្រធាននាយកដ្ឋានមួយរូប អមដោយអនុប្រធាននាយកដ្ឋានមួយចំនួនជាជំនួយការ តាមការចាំបាច់។

**មាត្រា ១០.-**

នាយកដ្ឋានស្តង់ដា និងសុវត្ថិភាពអាកាសយានដ្ឋាន មានភារកិច្ចដូចតទៅ÷

- រៀបចំ និងចងក្រងបទប្បញ្ញត្តិ នីតិវិធី ស្តង់ដា តម្រូវការ សេចក្តីនិងសៀវភៅណែនាំ និងលិខិតបទដ្ឋានគតិយុត្តនានា ដែលទាក់ទងនឹងស្តង់ដានិងសុវត្ថិភាពអាកាសយានដ្ឋាន ប្រព័ន្ធគ្រប់គ្រងសុវត្ថិភាពរបស់ប្រតិបត្តិករអាកាសយានដ្ឋាន ការផ្គត់ផ្គង់ទឹកភ្លើង អគ្គីភ័យ និងកិច្ចការពារបរិស្ថាននៅតាមអាកាសយានដ្ឋានក្នុងព្រះរាជាណាចក្រកម្ពុជា ឲ្យស្របតាមច្បាប់និងបទប្បញ្ញត្តិអាកាសចរស៊ីវិលកម្ពុជា និងស្តង់ដានិងអនុសាសន៍របស់អង្គការអាកាសចរស៊ីវិលអន្តរជាតិ
- បង្កើត និងត្រួតពិនិត្យមើលការអនុវត្ត និងស្តង់ដាសម្រាប់គម្រោងកសាងអាកាសយានដ្ឋានដែលមានស្រាប់ និងអាកាសយានដ្ឋានថ្មី សិក្សាទីតាំង កិច្ចដំណើរការ (រួមទាំងសម្ភារៈ និងបរិក្ខារ) ការងារវិស្វកម្ម និងជួសជុលថែទាំ
- សិក្សា និងវាយតម្លៃបច្ចេកទេសលើសំណើសុំអាជ្ញាប័ណ្ណសម្រាប់សាងសង់អាកាសយានដ្ឋានថ្មី
- សិក្សា និងវាយតម្លៃបច្ចេកទេសក្នុងការផ្តល់វិញ្ញាបនបត្រអាកាសយានដ្ឋាន
- សិក្សា និងវាយតម្លៃបច្ចេកទេសក្នុងការផ្តល់វិញ្ញាបនបត្រចុះបញ្ជី និងប្រតិបត្តិការអាកាសយានដ្ឋាន
- ផ្តល់យោបល់ និងណែនាំស្តីពីឧបសគ្គទាំងឡាយណាដែលរំខានទាំងនៅក្នុង និងក្រៅអាកាសយានដ្ឋាន និងការអនុវត្តឲ្យបានសមស្របតាមស្តង់ដា និងការណែនាំដូចមានចែងអំពីសញ្ញា និងភ្លើងរំខាន

- ទទួលខុសត្រូវចំពោះការធ្វើសវនកម្មរបស់អង្គការអាកាសចរស៊ីវិលអន្តរជាតិ
- ពិនិត្យ និងផ្តល់យោបល់លើការវាយតម្លៃបច្ចេកទេស ដែលទាក់ទងនឹងស្តង់ដា និងសុវត្ថិភាពអាកាសយានដ្ឋាន និងសុំការសម្រេចពីថ្នាក់ដឹកនាំរដ្ឋលេខាធិការដ្ឋាន
- ធ្វើរបាយការណ៍ពីសកម្មភាពការងាររបស់ខ្លួន
- អនុវត្តភារកិច្ចផ្សេងទៀត ដែលថ្នាក់ដឹកនាំរដ្ឋលេខាធិការដ្ឋានប្រគល់ជូន។

នាយកដ្ឋានស្តង់ដា និងសុវត្ថិភាពអាកាសយានដ្ឋាន ដឹកនាំដោយប្រធាននាយកដ្ឋានមួយរូប អមដោយអនុប្រធាននាយកដ្ឋានមួយចំនួនជាជំនួយការ តាមការចាំបាច់។

**មាត្រា ១១.-**

នាយកដ្ឋានសន្តិសុខអាកាសចរស៊ីវិល មានភារកិច្ចដូចតទៅ៖

- រៀបចំ និងចងក្រងច្បាប់ បទប្បញ្ញត្តិ នីតិវិធី ស្តង់ដា តម្រូវការ កម្មវិធី សេចក្តីនិងសៀវភៅណែនាំ និងលិខិតបទដ្ឋានគតិយុត្តនានាដែលទាក់ទងនឹងវិធានការសន្តិសុខ និងការដឹកជញ្ជូនទំនិញគ្រោះថ្នាក់តាមផ្លូវអាកាស ឲ្យស្របតាមច្បាប់និងបទប្បញ្ញត្តិអាកាសចរស៊ីវិលកម្ពុជា និងស្តង់ដា និងអនុសាសន៍របស់អង្គការអាកាសចរស៊ីវិលអន្តរជាតិ
- អនុវត្ត និងគាំពារកម្មវិធីជាតិសន្តិសុខអាកាសចរស៊ីវិល
- រៀបចំផែនការ កម្មវិធីហ្វឹកហ្វឺន និងធ្វើការហ្វឹកហ្វឺនដល់មន្ត្រីសន្តិសុខ និងមន្ត្រីនៃអង្គភាព និងស្ថាប័នពាក់ព័ន្ធ
- សិក្សា និងរៀបចំផែនការការពារ និងធានាសន្តិសុខ និងសុវត្ថិភាព ដោយសហការជាមួយនាយកដ្ឋានដទៃទៀត និងជាមួយក្រសួង ស្ថាប័ន និងអាជ្ញាធរមានសមត្ថកិច្ច ដើម្បីចាត់វិធានការទប់ស្កាត់នូវរាល់អំពើរំលោភបំពាន បំផ្លិចបំផ្លាញដោយខុសច្បាប់ដល់វិស័យអាកាសចរស៊ីវិល
- ទទួលខុសត្រូវចំពោះការធ្វើសវនកម្មរបស់អង្គការអាកាសចរស៊ីវិលអន្តរជាតិ
- ពិនិត្យ និងផ្តល់យោបល់លើការវាយតម្លៃបច្ចេកទេស ដែលទាក់ទងទៅនឹងសន្តិសុខអាកាសចរស៊ីវិល និងសុំការសម្រេចពីថ្នាក់ដឹកនាំរដ្ឋលេខាធិការដ្ឋាន
- ធ្វើរបាយការណ៍ពីសកម្មភាពការងាររបស់ខ្លួន
- អនុវត្តភារកិច្ចផ្សេងទៀត ដែលថ្នាក់ដឹកនាំរដ្ឋលេខាធិការដ្ឋានប្រគល់ជូន។

នាយកដ្ឋានសន្តិសុខអាកាសចរស៊ីវិល ដឹកនាំដោយប្រធាននាយកដ្ឋានមួយរូប អមដោយអនុប្រធាននាយកដ្ឋានមួយចំនួនជាជំនួយការ តាមការចាំបាច់។

**មាត្រា ១២.-**

នាយកដ្ឋានត្រួតពិនិត្យសន្តិសុខ និងសុវត្ថិភាពអាកាសចរណ៍ មានភារកិច្ចដូចតទៅ៖

- អនុវត្ត និងគ្រប់គ្រងប្រព័ន្ធគ្រប់គ្រងសុវត្ថិភាព
- អនុវត្ត និងគ្រប់គ្រងកម្មវិធីសុវត្ថិភាពរដ្ឋ និងកម្មវិធីជាតិសន្តិសុខអាកាសចរស៊ីវិល ដោយធ្វើការវិភាគ និងធ្វើរបាយការណ៍អំពីប្រព័ន្ធគ្រប់គ្រងសុវត្ថិភាព និងសន្តិសុខរបស់ប្រតិបត្តិករ សហគ្រាសដឹកជញ្ជូនតាមផ្លូវអាកាស និងអ្នកផ្តល់សេវាកម្មនានា
- ពិនិត្យ និងវាយតម្លៃបច្ចេកទេសក្នុងការផ្តល់ ផ្អាក ដកហូត និងបន្តវិញ្ញាបនបត្រអ្នកត្រួតពិនិត្យអាកាសចរស៊ីវិល
- ធ្វើអធិការកិច្ចលើ:
  - ក- អាកាសយាន និងឧទ្ធម្ភាគចក្រ
  - ខ- សហគ្រាសដឹកជញ្ជូនតាមផ្លូវអាកាស និងប្រតិបត្តិករ

គ- អាកាសយានដ្ឋាន

ឃ- សេវាកម្មនាំផ្លូវអាកាស

- រាល់ផ្នែកនីមួយៗខាងលើ មន្ត្រីអធិការកិច្ចត្រូវធ្វើការកែសម្រួលបច្ចុប្បន្នភាពខ្លឹមសារ ច្បាប់ បទប្បញ្ញត្តិបច្ចេកទេសអាកាសចរស៊ីវិលជាតិ ដោយធ្វើការប្រៀបធៀបឲ្យស្របទៅតាមស្តង់ដា និងអនុសាសន៍របស់អង្គការអាកាសចរស៊ីវិលអន្តរជាតិ និងធ្វើការត្រួតពិនិត្យ ការកែតម្រូវ និង ការអនុវត្តតាមរបស់សហគ្រាសដឹកជញ្ជូនតាមផ្លូវអាកាស ប្រតិបត្តិករ អ្នកផ្តល់សេវាកម្មនានា និងនាយកដ្ឋានពាក់ព័ន្ធ
- ទទួលខុសត្រូវចំពោះការធ្វើសវនកម្មរបស់អង្គការអាកាសចរស៊ីវិលអន្តរជាតិ
- ពិនិត្យ និងផ្តល់យោបល់លើការវាយតម្លៃបច្ចេកទេស ដែលទាក់ទងទៅនឹងសុវត្ថិភាព និងសន្តិសុខ អាកាសចរស៊ីវិល និងសុំការសម្រេចពីថ្នាក់ដឹកនាំរដ្ឋលេខាធិការដ្ឋាន
- ធ្វើរបាយការណ៍ពីសកម្មភាពការងាររបស់ខ្លួន
- អនុវត្តភារកិច្ចផ្សេងទៀត ដែលថ្នាក់ដឹកនាំរដ្ឋលេខាធិការដ្ឋានប្រគល់ជូន។

នាយកដ្ឋានត្រួតពិនិត្យសន្តិសុខ និងសុវត្ថិភាពអាកាសចរណ៍ ដឹកនាំដោយប្រធាននាយកដ្ឋាន មួយរូប អមដោយអនុប្រធាននាយកដ្ឋានមួយចំនួនជាជំនួយការ តាមការចាំបាច់។

## ជំពូកទី ៤
## អគ្គនាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅ

**មាត្រា ១៣.-**

អគ្គនាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅ មានភារកិច្ចដឹកនាំ សម្របសម្រួល និងគ្រប់គ្រង សកម្មភាពលើការងាររដ្ឋបាល មន្ត្រីរាជការ ការអភិវឌ្ឍនិងបណ្តុះបណ្តាលធនធានមនុស្ស ភស្តុភារ ហិរញ្ញកិច្ច ផែនការ យុទ្ធសាស្ត្រ និងគោលនយោបាយអភិវឌ្ឍន៍វិស័យអាកាសចរស៊ីវិល។

**មាត្រា ១៤.-**

អគ្គនាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅដឹកនាំដោយអគ្គនាយកមួយរូប អមដោយអគ្គនាយករង មួយចំនួនជាជំនួយការ តាមការចាំបាច់។

អគ្គនាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅមាននាយកដ្ឋានចំណុះចំនួន០៣ (បី) ដូចខាងក្រោម÷

- នាយកដ្ឋានរដ្ឋបាល និងគ្រប់គ្រងធនធានមនុស្ស
- នាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ
- នាយកដ្ឋានផែនការ យុទ្ធសាស្ត្រ និងគោលនយោបាយ។

**មាត្រា ១៥.-**

នាយកដ្ឋានរដ្ឋបាល និងគ្រប់គ្រងធនធានមនុស្ស មានភារកិច្ចដូចតទៅ÷

- សម្របសម្រួលសកម្មភាពគ្រប់ផ្នែករបស់រដ្ឋលេខាធិការដ្ឋាននៅថ្នាក់កណ្តាល និងរវាងថ្នាក់ កណ្តាលជាមួយនឹងអង្គភាពមូលដ្ឋានក្រោមឱវាទ
- គ្រប់គ្រង និងចរាចរឯកសាររដ្ឋបាលផ្សេងៗរបស់រដ្ឋលេខាធិការដ្ឋាន

- ធានាប្រសិទ្ធភាព សុវត្ថិភាពរដ្ឋបាល និងគ្រប់គ្រងការងារសង្គមរបស់រដ្ឋលេខាធិការដ្ឋាន
- ទទួលបដិសណ្ឋារកិច្ចភ្ញៀវជាតិ និងអន្តរជាតិរបស់រដ្ឋលេខាធិការដ្ឋាន និងរៀបចំតុបតែងលម្អក្នុងពិធីផ្សេងៗ
- គ្រប់គ្រងរដ្ឋបាល មន្ត្រីរាជការ និងភ្នាក់ងាររាជការរបស់រដ្ឋលេខាធិការដ្ឋាន ដោយទំនាក់ទំនងជាមួយរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និងក្រសួង ស្ថាប័នពាក់ព័ន្ធ
- រៀបចំរាល់លិខិតបទដ្ឋានរដ្ឋបាលសម្រាប់ការគ្រប់គ្រងអាជីព
- រៀបចំស្ថិតិលើការងារគ្រប់គ្រងទិន្នន័យមន្ត្រីរាជការ និងតារាងព័ត៌មានប្រតិបត្តិ
- ធ្វើតារាង និងបើកផ្តល់ប្រាក់បៀវត្ស ប្រាក់កម្រៃផ្សេងៗជូនមន្ត្រីរាជការ
- រៀបចំផែនការ និងបណ្តុះបណ្តាលធនធានមនុស្សក្នុងវិស័យអាកាសចរស៊ីវិល និងវិស័យពាក់ព័ន្ធផ្សេងៗទៀត
- រៀបចំ និងអនុវត្តផែនការបណ្តុះបណ្តាលមន្ត្រីរាជការដំបូង និងបន្ត
- រៀបចំតួនាទី និងតំណែងឯកទេសរបស់ស្ថាប័ន និងធនធានមនុស្ស
- រៀបចំបែបបទបំពេញបេសកកម្មរបស់មន្ត្រីរាជការក្នុងរដ្ឋលេខាធិការដ្ឋាន
- គ្រប់គ្រងបណ្តាញទូរគមនាគមន៍ បណ្តាញទូរសារ និងទូរស័ព្ទក្នុងរដ្ឋលេខាធិការដ្ឋាន
- រៀបចំការអភិវឌ្ឍព័ត៌មានវិទ្យា តាមកម្មវិធីរបស់អាជ្ញាធរជាតិទទួលបន្ទុកកិច្ចការអភិវឌ្ឍន៍វិស័យបច្ចេកវិទ្យាគមនាគមន៍ ព័ត៌មានវិទ្យា និងកម្មវិធីកំណែទម្រង់ផ្សេងៗរបស់រាជរដ្ឋាភិបាល
- រៀបចំព័ត៌មាន និងទិន្នន័យសម្រាប់ផ្សព្វផ្សាយក្នុងគេហទំព័ររបស់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ទទួលខុសត្រូវចំពោះការធ្វើសវនកម្មរបស់អង្គការអាកាសចរស៊ីវិលអន្តរជាតិ
- ពិនិត្យ និងផ្តល់យោបល់លើការងារ ដែលទាក់ទងនឹងកិច្ចការរដ្ឋបាល និងគ្រប់គ្រងធនធានមនុស្ស និងសុំការសម្រេចពីថ្នាក់ដឹកនាំរដ្ឋលេខាធិការដ្ឋាន
- ធ្វើរបាយការណ៍ពីសកម្មភាពការងាររបស់ខ្លួន និងរដ្ឋលេខាធិការដ្ឋាន
- អនុវត្តភារកិច្ចផ្សេងទៀត ដែលថ្នាក់ដឹកនាំរដ្ឋលេខាធិការដ្ឋានប្រគល់ជូន។

នាយកដ្ឋានរដ្ឋបាល និងគ្រប់គ្រងធនធានមនុស្សដឹកនាំដោយប្រធាននាយកដ្ឋានមួយរូប អមដោយអនុប្រធាននាយកដ្ឋានមួយចំនួនជាជំនួយការ តាមការចាំបាច់។

**មាត្រា ១៦.-**

នាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ មានភារកិច្ចដូចតទៅ៖
- លើកគម្រោងថវិការបស់រដ្ឋលេខាធិការដ្ឋាន និងតាមដានរំលឹកពីការប្រតិបត្តិ
- សហការរៀបចំផែនការ កំណត់តម្លៃសេវាកម្មនានាស្តីពីការដឹកជញ្ជូនតាមផ្លូវអាកាស
- ប្រមូលផ្តុំ និងសម្របសម្រួលជំពូកថវិកា
- គ្រប់គ្រងចំណូល និងចំណាយឲ្យសមស្របតាមច្បាប់ហិរញ្ញវត្ថុដែលបានកំណត់
- ប្រមូលផ្តុំ និងសម្របសម្រួលរាល់ការចំណាយរបស់រដ្ឋលេខាធិការដ្ឋាន
- រៀបចំផែនការចំណាយដែលតម្រូវឲ្យអនុវត្តនីតិវិធីលទ្ធកម្មសាធារណៈ
- ប្រមូលផ្តុំតម្រូវការ និងធ្វើកម្មវិធីចំណាយ
- គ្រប់គ្រងការរៀបចំជួសជុលសម្ភារៈ និងបរិក្ខាររបស់រដ្ឋលេខាធិការដ្ឋាន
- គ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យ សន្និធិសម្ភារៈ និងធ្វើបញ្ជីសារពើភ័ណ្ឌ

- គ្រប់គ្រងយានដ្ឋាន និងយានយន្តរបស់រដ្ឋ ដែលប្រគល់ជូនរដ្ឋលេខាធិការដ្ឋាន ព្រមទាំងធ្វើកម្មវិធីចំណាយ បែងចែកប្រេងឥន្ធនៈ និងគ្រឿងបន្លាស់
- ទទួល និងបែងចែកបរិក្ខារជូនដល់បណ្តាអង្គភាពក្រោមឱវាទរដ្ឋលេខាធិការដ្ឋាន
- កត់ត្រា និងគ្រប់គ្រងសកម្មភាពខាងហិរញ្ញវត្ថុ និងបន្ទុកគណនីក្នុងប្រព័ន្ធកុំព្យូទ័រ
- សហការរៀបចំធ្វើប័ណ្ណកម្មសិទ្ធិដីអាកាសយានដ្ឋាន ដីរបស់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល និងដោះស្រាយបញ្ហាដីដែលពាក់ព័ន្ធនឹងអាកាសយានដ្ឋាន
- ទទួលខុសត្រូវចំពោះការធ្វើសវនកម្មរបស់អង្គការអាកាសចរស៊ីវិលអន្តរជាតិ
- ពិនិត្យ និងផ្តល់យោបល់លើការងារដែលទាក់ទងនឹងភស្តុភារ និងហិរញ្ញវត្ថុ និងសុំការសម្រេចពីថ្នាក់ដឹកនាំរដ្ឋលេខាធិការដ្ឋាន
- ធ្វើរបាយការណ៍ពីសកម្មភាពការងាររបស់ខ្លួន
- អនុវត្តភារកិច្ចផ្សេងទៀត ដែលថ្នាក់ដឹកនាំរដ្ឋលេខាធិការដ្ឋានប្រគល់ជូន។

នាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ ដឹកនាំដោយប្រធាននាយកដ្ឋានមួយរូប អមដោយអនុប្រធាននាយកដ្ឋានមួយចំនួនជាជំនួយការ តាមការចាំបាច់។

**មាត្រា ១៧.-**

នាយកដ្ឋានផែនការ យុទ្ធសាស្ត្រ និងគោលនយោបាយ មានភារកិច្ចដូចតទៅ៖

- រៀបចំផែនការ គោលនយោបាយ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យអាកាសចរស៊ីវិល
- សហការសិក្សា ស្រាវជ្រាវ និងវិភាគពីស្ថានភាពសេដ្ឋកិច្ចរបស់វិស័យអាកាសចរស៊ីវិល និងផ្តល់យោបល់លើកិច្ចព្រមព្រៀងដែលទាក់ទងដល់ការជម្រុញ និងការបើកច្រកទីផ្សារសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាស
- រៀបចំ គ្រប់គ្រង និងសម្របសម្រួលព័ត៌មានស្តីពីប្រព័ន្ធទិន្នន័យស្ថិតិ និងវឌ្ឍនភាពក្នុងការអភិវឌ្ឍវិស័យអាកាសចរស៊ីវិល
- ទទួលបន្ទុកសម្របសម្រួលគម្រោងសហប្រតិបត្តិការគ្រប់រូបភាពជាមួយដៃគូអភិវឌ្ឍន៍ ដែលពាក់ព័ន្ធដល់ការអភិវឌ្ឍវិស័យអាកាសចរស៊ីវិល និងតាមដានត្រួតពិនិត្យលើការអនុវត្ត
- ពិនិត្យ ផ្តល់យោបល់ និងរៀបចំឯកសារដែលទាក់ទងនឹងវិស័យអាកាសចរស៊ីវិល សម្រាប់ការចូលរួមក្នុងកិច្ចសហប្រតិបត្តិការអន្តរជាតិ
- រៀបចំ ត្រួតពិនិត្យ កែសម្រួល និងធ្វើបច្ចុប្បន្នភាពផែនការ យុទ្ធសាស្ត្រ កម្មវិធីអភិវឌ្ឍន៍វិស័យអាកាសចរស៊ីវិល និងកម្មវិធីវិនិយោគសាធារណៈនិងឯកជន សំដៅធ្វើឲ្យមានសង្គតភាពជាមួយផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងអន្តរជាតិ
- សហការ និងសម្របសម្រួលការអនុវត្តគម្រោងរបស់វិស័យឯកជនក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធក្នុងវិស័យដឹកជញ្ជូនតាមផ្លូវអាកាស
- ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តផែនការពាណិជ្ជកម្ម និងអាជីវកម្មរបស់ក្រុមហ៊ុនសម្បទានក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធក្នុងវិស័យដឹកជញ្ជូនតាមផ្លូវអាកាស
- ពិនិត្យ និងផ្តល់យោបល់លើការងារដែលទាក់ទងទៅនឹងផែនការ យុទ្ធសាស្ត្រ និងគោលនយោបាយ និងសុំការសម្រេចពីថ្នាក់ដឹកនាំរដ្ឋលេខាធិការដ្ឋាន
- ធ្វើរបាយការណ៍ពីសកម្មភាពការងាររបស់ខ្លួន
- អនុវត្តភារកិច្ចផ្សេងទៀត ដែលថ្នាក់ដឹកនាំរដ្ឋលេខាធិការដ្ឋានប្រគល់ជូន។

នាយកដ្ឋានផែនការ យុទ្ធសាស្ត្រ និងគោលនយោបាយ ដឹកនាំដោយប្រធាននាយកដ្ឋានមួយរូប អមដោយអនុប្រធាននាយកដ្ឋានមួយចំនួនជាជំនួយការ តាមការចាំបាច់។

## ជំពូកទី ៥
## ខុទ្ទកាល័យ

**មាត្រា ១៨.-**

ខុទ្ទកាល័យរដ្ឋលេខាធិការទទួលបន្ទុកបេសកកម្មទាំងឡាយ ដែលបានកំណត់តាមបទប្បញ្ញត្តិនៃអនុក្រឹត្យលេខ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន។

## ជំពូកទី ៦
## អង្គភាពស៊ើបអង្កេតគ្រោះថ្នាក់អាកាសចរណ៍

**មាត្រា ១៩.-**

អង្គភាពស៊ើបអង្កេតគ្រោះថ្នាក់អាកាសចរណ៍ មានភារកិច្ចដូចតទៅ÷

- ចូលរួមស៊ើបអង្កេត និងវាយតម្លៃឧប្បត្តិហេតុ ឬគ្រោះថ្នាក់ពាក់ព័ន្ធដល់វិស័យអាកាសចរណ៍ ដោយសហការជាមួយស្ថាប័នជាតិ និងអន្តរជាតិពាក់ព័ន្ធ
- ស៊ើបអង្កេតឧប្បត្តិហេតុ ឬគ្រោះថ្នាក់ពាក់ព័ន្ធដល់អាកាសយានទាំងក្នុង និងក្រៅប្រទេស ដែលបានចុះបញ្ជីនៅរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ដោយសហការជាមួយស្ថាប័នជាតិ និងអន្តរជាតិពាក់ព័ន្ធ
- ទទួលខុសត្រូវ និងសហការរៀបចំ និងអនុវត្តរាល់កិច្ចព្រមព្រៀងស្តីពីឧប្បត្តិហេតុ ឬគ្រោះថ្នាក់ពាក់ព័ន្ធដល់វិស័យអាកាសចរណ៍
- ត្រួតពិនិត្យ និងវាយតម្លៃលទ្ធផលស៊ើបអង្កេត និងគ្រប់គ្រងព័ត៌មាន
- រៀបចំផែនការទប់ស្កាត់ឧប្បត្តិហេតុ ឬគ្រោះថ្នាក់ពាក់ព័ន្ធដល់វិស័យអាកាសចរណ៍
- ទទួលខុសត្រូវចំពោះការធ្វើសវនកម្មរបស់អង្គការអាកាសចរស៊ីវិលអន្តរជាតិ
- ពិនិត្យ និងផ្តល់យោបល់លើការវាយតម្លៃបច្ចេកទេស ដែលទាក់ទងនឹងឧប្បត្តិហេតុ ឬគ្រោះថ្នាក់ពាក់ព័ន្ធដល់វិស័យអាកាសចរណ៍ និងសុំការសម្រេចពីថ្នាក់ដឹកនាំរដ្ឋលេខាធិការដ្ឋាន
- ធ្វើរបាយការណ៍ពីសកម្មភាពការងាររបស់ខ្លួន
- អនុវត្តភារកិច្ចផ្សេងទៀត ដែលថ្នាក់ដឹកនាំរដ្ឋលេខាធិការដ្ឋានប្រគល់ជូន។

អង្គភាពស៊ើបអង្កេតគ្រោះថ្នាក់អាកាសចរណ៍ ដឹកនាំដោយប្រធានមួយរូប អមដោយអនុប្រធានមួយចំនួនជាជំនួយការ តាមការចាំបាច់។

## ជំពូកទី ៧
## នាយកដ្ឋានសេវាកម្មអាកាសចរណ៍

**មាត្រា ២០.-**

នាយកដ្ឋានសេវាកម្មអាកាសចរណ៍ មានភារកិច្ចដូចតទៅ÷

- គ្រប់គ្រងចាត់ចែង និងផ្តល់សេវាកម្មនាំផ្លូវអាកាសនៅក្នុង ចេញ-ចូល និងឆ្លងកាត់ដែនអាកាសនៃព្រះរាជាណាចក្រកម្ពុជា ដោយអនុលោមឲ្យស្របទៅតាមច្បាប់ បទប្បញ្ញត្តិអាកាសចរស៊ីវិលកម្ពុជា និងស្តង់ដានិងអនុសាសន៍របស់អង្គការអាកាសចរស៊ីវិលអន្តរជាតិ រួមមាន:

ក- គ្រប់គ្រង និងផ្តល់សេវាកម្មព័ត៌មានឧតុនិយម និងអាកាសចរវិទ្យា

ខ- គ្រប់គ្រង និងត្រួតពិនិត្យចរាចរនាំផ្លូវអាកាស

គ- គ្រប់គ្រង និងត្រួតពិនិត្យលើប្រព័ន្ធទូរគមនាគមន៍ ប្រព័ន្ធបរិក្ខារអេឡិចត្រូនិចនាំផ្លូវអាកាស និងស្ថានីយ៍ផ្កាយរណប។

- សហការលើការងាររុករក សង្គ្រោះ និងពន្លត់អគ្គីភ័យ
- សហការលើការងារផ្តល់សេវាកម្មអាកាសយានដ្ឋាន
- ទទួលខុសត្រូវចំពោះការធ្វើសវនកម្មរបស់អង្គការអាកាសចរស៊ីវិលអន្តរជាតិ
- ពិនិត្យ និងផ្តល់យោបល់លើការវាយតម្លៃបច្ចេកទេស ដែលពាក់ព័ន្ធដល់ប្រព័ន្ធ និងសេវាកម្មនាំផ្លូវអាកាស និងសុំការសម្រេចពីថ្នាក់ដឹកនាំរដ្ឋលេខាធិការដ្ឋាន
- ធ្វើរបាយការណ៍ពីសកម្មភាពការងាររបស់ខ្លួន
- អនុវត្តភារកិច្ចផ្សេងទៀត ដែលថ្នាក់ដឹកនាំរដ្ឋលេខាធិការដ្ឋានប្រគល់ជូន។

នាយកដ្ឋានសេវាកម្មអាកាសចរណ៍ ដឹកនាំដោយប្រធាននាយកដ្ឋានមួយរូប អមដោយអនុប្រធាននាយកដ្ឋានមួយចំនួនជាជំនួយការ តាមការចាំបាច់។

## ជំពូកទី ៨
## អាកាសយានដ្ឋានអន្តរជាតិ

**មាត្រា ២១.-**

អាកាសយានដ្ឋានអន្តរជាតិ មានភារកិច្ចដូចតទៅ÷

- នាយកអាកាសយានដ្ឋានអន្តរជាតិនីមួយៗ ជាតំណាងរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ក្នុងការគ្រប់គ្រងអាកាសយានដ្ឋានអន្តរជាតិ
- សហការជាមួយក្រុមហ៊ុនគ្រប់គ្រងអាកាសយានដ្ឋានអន្តរជាតិ ក្នុងការគ្រប់គ្រងកិច្ចប្រតិបត្តិការ និងការអភិវឌ្ឍអាកាសយានដ្ឋានអន្តរជាតិ
- សហការជាមួយក្រុមហ៊ុនគ្រប់គ្រងសេវាកម្មចរាចរដែនអាកាស ក្នុងការគ្រប់គ្រងកិច្ចប្រតិបត្តិការ និងការអភិវឌ្ឍប្រព័ន្ធនាំផ្លូវអាកាសនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- សហការជាមួយអាជ្ញាធរមានសមត្ថកិច្ច ក្រុមហ៊ុនគ្រប់គ្រងអាកាសយានដ្ឋានអន្តរជាតិ ក្រុមហ៊ុនគ្រប់គ្រងសេវាកម្មនាំផ្លូវអាកាស ក្រុមហ៊ុនអាកាសចរណ៍ និងស្ថាប័នពាក់ព័ន្ធនានា ដើម្បីធានាសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈ និងការធ្វើអាជីវកម្មនៅក្នុង និងជុំវិញអាកាសយានដ្ឋានអន្តរជាតិ
- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរមានសមត្ថកិច្ចក្នុងការដឹកនាំធ្វើលំហាត់សមយុទ្ធ គ្រប់គ្រងគ្រោះអាសន្នឲ្យបានទៀងទាត់ និងចូលរួមកែលម្អផែនការគ្រប់គ្រងគ្រោះអាសន្ន ជាមួយក្រុមហ៊ុនគ្រប់គ្រងអាកាសយានដ្ឋានអន្តរជាតិ
- ពិនិត្យ និងផ្តល់យោបល់លើការវាយតម្លៃបច្ចេកទេស ដែលទាក់ទងទៅនឹងការគ្រប់គ្រង និងការអភិវឌ្ឍអាកាសយានអន្តរជាតិ និងសុំការសម្រេចពីថ្នាក់ដឹកនាំរដ្ឋលេខាធិការដ្ឋាន
- សហការទទួលខុសត្រូវ ចំពោះការធ្វើសវនកម្មរបស់អង្គការអាកាសចរស៊ីវិលអន្តរជាតិ
- ធ្វើរបាយការណ៍ពីសកម្មភាពការងាររបស់ខ្លួន
- អនុវត្តភារកិច្ចផ្សេងទៀត ដែលថ្នាក់ដឹកនាំរដ្ឋលេខាធិការដ្ឋានប្រគល់ជូន។

អាកាសយានដ្ឋានអន្តរជាតិ ដឹកនាំដោយនាយកមួយរូប អមដោយនាយករងមួយចំនួនជាជំនួយការតាមការចាំបាច់។

## ជំពូកទី ៩
## នាយកដ្ឋានដឹកជញ្ជូនតាមផ្លូវអាកាស

**មាត្រា ២២.-**

នាយកដ្ឋានដឹកជញ្ជូនតាមផ្លូវអាកាស មានភារកិច្ចដូចតទៅ÷

- រៀបចំ និងចងក្រងគោលនយោបាយ និងបទប្បញ្ញត្តិស្តីពីការដឹកជញ្ជូនតាមផ្លូវអាកាស ឲ្យស្របទៅតាមគោលបំណង និងចក្ខុវិស័យរបស់រាជរដ្ឋាភិបាលកម្ពុជា និងអង្គការអាកាសចរស៊ីវិលអន្តរជាតិ
- ជួយគាំទ្រឲ្យមាននិរន្តភាពទីផ្សារសេដ្ឋកិច្ច និងប្រសិទ្ធភាពឧស្សាហកម្មដឹកជញ្ជូនតាមផ្លូវអាកាស
- រៀបចំ ចរចា និងបង្កើតអនុស្សរណៈយោគយល់ កិច្ចព្រមព្រៀង និងលិខិតបទដ្ឋានគតិយុត្តនានាស្តីពីការធ្វើសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាស
- ចូលរួមគ្រប់គ្រង និងចាត់ចែងលើការងារអាកាសចរណ៍ចាំបាច់មួយចំនួន ដូចជា សេរីភាវូបនីយកម្មដឹកជញ្ជូនតាមផ្លូវអាកាស ជាមួយសមាគមន៍អាស៊ាន និងអង្គការដទៃទៀតទាំងក្នុងកម្រិតតំបន់ និងអន្តរជាតិ ដោយសហការជាមួយនាយកដ្ឋានទំនាក់ទំនងអន្តរជាតិ និងនីតិកម្ម
- ពិនិត្យ និងវាយតម្លៃបច្ចេកទេសក្នុងការផ្តល់លិខិតអនុញ្ញាត ឬវិញ្ញាបនបត្រដឹកជញ្ជូនតាមផ្លូវអាកាស ដោយសហការជាមួយនាយកដ្ឋានស្តង់ដានិងសុវត្ថិភាពហោះហើរ និងនាយកដ្ឋានលទ្ធភាពហោះហើរ
- ពិនិត្យ និងវាយតម្លៃបច្ចេកទេសក្នុងការផ្តល់លិខិតអនុញ្ញាតដឹកជញ្ជូនទំនិញគ្រោះថ្នាក់តាមផ្លូវអាកាស ដោយសម្របសម្រួលជាមួយនាយកដ្ឋានស្តង់ដា និងសុវត្ថិភាពហោះហើរ និងនាយកដ្ឋានសន្តិសុខអាកាសចរស៊ីវិល
- រៀបចំ និងផ្តល់ការអនុញ្ញាតសេវាកម្មហោះហើរតាមកម្មវិធី និងក្រៅកម្មវិធី និងរៀបចំចងក្រងឯកសារស្ថិតិ និងទិន្នន័យស្តីពីអាកាសចរស៊ីវិល ដោយសហការជាមួយនាយកដ្ឋាន និងស្ថាប័នពាក់ព័ន្ធ
- ទទួលខុសត្រូវចំពោះការធ្វើសវនកម្មរបស់អង្គការអាកាសចរស៊ីវិលអន្តរជាតិ
- ពិនិត្យ និងផ្តល់យោបល់លើការវាយតម្លៃបច្ចេកទេស និងសេដ្ឋកិច្ច ដែលពាក់ព័ន្ធដល់គោលនយោបាយដឹកជញ្ជូនតាមផ្លូវអាកាស និងសុំការសម្រេចពីថ្នាក់ដឹកនាំរដ្ឋលេខាធិការដ្ឋាន
- ធ្វើរបាយការណ៍ពីសកម្មភាពការងាររបស់ខ្លួន
- អនុវត្តភារកិច្ចផ្សេងទៀត ដែលថ្នាក់ដឹកនាំរដ្ឋលេខាធិការដ្ឋានប្រគល់ជូន។

នាយកដ្ឋានដឹកជញ្ជូនតាមផ្លូវអាកាស ដឹកនាំដោយប្រធាននាយកដ្ឋានមួយរូប អមដោយអនុប្រធាននាយកដ្ឋានមួយចំនួនជាជំនួយការ តាមការចាំបាច់។

## ជំពូកទី ១០
## នាយកដ្ឋានទំនាក់ទំនងអន្តរជាតិ និងនីតិកម្ម

**មាត្រា ២៣.-**

នាយកដ្ឋានទំនាក់ទំនងអន្តរជាតិ និងនីតិកម្ម មានភារកិច្ចដូចតទៅ÷

- សហប្រតិបត្តិការ និងសម្របសម្រួលរាល់ការងារជាមួយអង្គការអាកាសចរស៊ីវិលអន្តរជាតិស្តីពីការកំណត់ស្តង់ដា និងអនុសាសន៍ដែលត្រូវយកទៅអនុវត្ត កម្មវិធីសវនកម្មសន្តិសុខ និងសុវត្ថិភាព

កម្មវិធីហ្វឹកហ្វឺន កម្មវិធីការងារ និងព្រឹត្តិការណ៍ដែលទាក់ទងនឹងអាកាសចរស៊ីវិល និងការបង់វិភាគទាន
- សហការសម្របសម្រួលរៀបចំកិច្ចប្រជុំ និងបដិសណ្ឋារកិច្ច
- គ្រប់គ្រងបណ្ណាល័យ និងមជ្ឈមណ្ឌលឯកសាររបស់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- សិក្សារៀបចំតាក់តែងសេចក្តីព្រាងបទប្បញ្ញត្តិ និងលិខិតបទដ្ឋានគតិយុត្តនានា ឬសិក្សារៀបចំធ្វើវិសោធនកម្ម ការកែសម្រួលបទប្បញ្ញត្តិ និងលិខិតបទដ្ឋានគតិយុត្ត ដែលពាក់ព័ន្ធវិស័យអាកាសចរស៊ីវិលជាតិ និងអន្តរជាតិ ដោយសហការជាមួយនាយកដ្ឋានពាក់ព័ន្ធរបស់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល និងក្រុមប្រឹក្សាអ្នកច្បាប់នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រមទាំងផ្សព្វផ្សាយ និងតាមដានការអនុវត្ត
- ចូលរួមពិនិត្យផ្តល់យោបល់លើការតាក់តែង ឬការកែសម្រួលឯកសារគតិយុត្ត ដូចជា កិច្ចព្រមព្រៀងអនុស្សរណៈយោគយល់ កិច្ចសន្យា និងសេចក្តីកំណត់ និងសេចក្តីណែនាំទាំងឡាយណា ដែលបម្រើឲ្យផលប្រយោជន៍របស់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- សម្របសម្រួលរាល់ការងារជាមួយបណ្តាស្ថាប័ន អង្គការ សមាគមន៍ជាតិ អន្តរជាតិ និងបណ្តាប្រទេសជាមិត្ត ដែលទាក់ទងទៅនឹងការងារច្បាប់ និងគម្រោងសហប្រតិបត្តិការផ្តល់ជំនួយ
- ពិនិត្យ និងផ្តល់យោបល់លើការងារដែលទាក់ទងទៅនឹងកិច្ចសហប្រតិបត្តិការអន្តរជាតិ និងនីតិកម្ម និងសុំការសម្រេចពីថ្នាក់នាំរដ្ឋលេខាធិការដ្ឋាន
- សហការទទួលខុសត្រូវចំពោះការធ្វើសវនកម្មរបស់អង្គការអាកាសចរស៊ីវិលអន្តរជាតិ
- ធ្វើរបាយការណ៍ពីសកម្មភាពការងាររបស់ខ្លួន
- អនុវត្តភារកិច្ចផ្សេងទៀត ដែលថ្នាក់ដឹកនាំរដ្ឋលេខាធិការដ្ឋានប្រគល់ជូន។

នាយកដ្ឋានទំនាក់ទំនងអន្តរជាតិ និងនីតិកម្ម ដឹកនាំដោយប្រធាននាយកដ្ឋានមួយរូប អមដោយអនុប្រធាននាយកដ្ឋានមួយចំនួនជាជំនួយការ តាមការចាំបាច់។

## ជំពូកទី ១១
## មជ្ឈមណ្ឌលហ្វឹកហ្វឺនអាកាសចរស៊ីវិល

**មាត្រា ២៤.-**

មជ្ឈមណ្ឌលហ្វឹកហ្វឺនអាកាសចរស៊ីវិល មានភារកិច្ចដូចតទៅ÷
- ធ្វើការបណ្តុះបណ្តាល និងហ្វឹកហ្វឺនជំនាញបច្ចេកទេសក្នុងវិស័យអាកាសចរស៊ីវិល ទៅតាមកម្មវិធី និងផែនការបណ្តុះបណ្តាល ឲ្យស្របតាមច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងវិស័យអាកាសចរស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា និងឲ្យស្របតាមស្តង់ដានិងអនុសញ្ញាស្តីពីអាកាសចរស៊ីវិលអន្តរជាតិ
- ពង្រឹងគុណភាព និងសមត្ថភាពជំនាញរបស់មន្ត្រីពាក់ព័ន្ធ ឲ្យស្របតាមផែនការអភិវឌ្ឍធនធានមនុស្សនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់សហគ្រាសដឹកជញ្ជូនតាមផ្លូវអាកាសទាំងរដ្ឋ និងឯកជន
- សហការ និងផ្លាស់ប្តូរបទពិសោធជាមួយស្ថាប័នជាតិនិងអន្តរជាតិ និងដៃគូអភិវឌ្ឍន៍លើការបណ្តុះបណ្តាលធនធានមនុស្សក្នុងវិស័យអាកាសចរស៊ីវិល
- ពិនិត្យ ផ្តល់យោបល់លើការងារដែលទាក់ទងនឹងមជ្ឈមណ្ឌលហ្វឹកហ្វឺនអាកាសចរស៊ីវិល និងសុំការសម្រេចពីថ្នាក់ដឹកនាំរដ្ឋលេខាធិការដ្ឋាន
- ទទួលខុសត្រូវចំពោះការធ្វើសវនកម្មរបស់អង្គការអាកាសចរស៊ីវិលអន្តរជាតិ
- ធ្វើរបាយការណ៍ពីសកម្មភាពការងាររបស់ខ្លួន

- អនុវត្តភារកិច្ចផ្សេងទៀត ដែលថ្នាក់ដឹកនាំរដ្ឋលេខាធិការដ្ឋានប្រគល់ជូន។

មជ្ឈមណ្ឌលហ្វឹកហ្វឺនអាកាសចរស៊ីវិល ដឹកនាំដោយនាយកមួយរូប អមដោយនាយករងមួយចំនួនជាជំនួយការ តាមការចាំបាច់។

## ជំពូកទី ១២
## អាកាសយានដ្ឋានមូលដ្ឋាន

**មាត្រា ២៥.-**

អាកាសយានដ្ឋានមូលដ្ឋាន មានភារកិច្ចដូចតទៅ÷

- នាយកអាកាសយានដ្ឋានមូលដ្ឋាននីមួយៗ ជាតំណាងរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ក្នុងការសម្របសម្រួល គ្រប់គ្រងកិច្ចប្រតិបត្តិការអាកាសយានដ្ឋានមូលដ្ឋាន
- ធានាសុវត្ថិភាពហោះហើរ និងចុះចតឲ្យអាកាសយានរបស់ក្រុមហ៊ុនអាកាសចរណ៍ ដែលកំពុងធ្វើសេវាកម្មនៅអាកាសយានដ្ឋាន
- អនុវត្តការងារត្រួតពិនិត្យ និងគ្រប់គ្រងសេវាកម្មចរាចរដែនអាកាស ក្នុងដែនទទួលខុសត្រូវរបស់អាកាសយានដ្ឋាន
- សហការជាមួយអាជ្ញាធរមានសមត្ថកិច្ច និងស្ថាប័នពាក់ព័ន្ធនានា ក្នុងការធានាសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈ និងការធ្វើអាជីវកម្មនៅក្នុង និងជុំវិញអាកាសយានដ្ឋានមូលដ្ឋាន
- សហការរុករក សង្គ្រោះ និងពន្លត់អគ្គីភ័យនៅក្នុង និងជុំវិញអាកាសយានដ្ឋាន ក្នុងដែនសមត្ថកិច្ចទទួលខុសត្រូវ
- សហការចូលរួមពិនិត្យ និងផ្តល់យោបល់លើផែនការជួសជុលកែលម្អនិងអភិវឌ្ឍន៍អាកាសយានដ្ឋានមូលដ្ឋាន និងប្រព័ន្ធនាំផ្លូវអាកាស និងសុំការសម្រេចពីថ្នាក់ដឹកនាំរដ្ឋលេខាធិការដ្ឋាន
- ទទួលខុសត្រូវចំពោះការធ្វើសវនកម្មរបស់អង្គការអាកាសចរស៊ីវិលអន្តរជាតិ
- ធ្វើរបាយការណ៍ពីសកម្មភាពការងាររបស់ខ្លួន
- អនុវត្តភារកិច្ចផ្សេងទៀត ដែលថ្នាក់ដឹកនាំរដ្ឋលេខាធិការដ្ឋានប្រគល់ជូន។

អាកាសយានដ្ឋានមូលដ្ឋាន ដឹកនាំដោយនាយកមួយរូប អមដោយនាយករងមួយចំនួនជាជំនួយការ តាមការចាំបាច់។

## ជំពូកទី ១៣
## អង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុ

**មាត្រា ២៦.-**

អង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុ ត្រូវបានបង្កើតឡើងដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមល័ក្ខខ័ណ្ឌនៃបទបញ្ញាកំណត់ក្នុងអនុក្រឹត្យលេខ៨១ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតស្ថាប័នត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិកាក្នុងបណ្តាក្រសួង។

## ជំពូកទី ១៤
## អវសានប្បញ្ញត្តិ

**មាត្រា ២៧.-**

ការរៀបចំ និងការប្រព្រឹត្តទៅរបស់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ចាប់ពីថ្នាក់ក្រោមនាយកដ្ឋានចុះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី។

**មាត្រា ២៨.-**

អនុក្រឹត្យលេខ១២ អនក្រ.បក ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ២៩.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០១២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**បានយកសេចក្តីជម្រាបជូន**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា សូមហត្ថលេខា**

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**សុខ អាន**

**កន្លែងទទួល:**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា២៩*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

ឧបសម្ព័ន្ធរបស់
រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
លេខ ៖ ១៧ ៣ន្ធ/ស.ស៊.វ
ថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១២




Organization Structure of
the State Secretariat of Civil Aviation
No: 18
Date: 03 / February / 2012
Royal Government of Cambodia
Council of Ministers
State Secretariat of Civil Aviation
Inspection Unit for Finance (MEF)
Cabinet
Director General for (Admin. & General Work)
Admin. & Human Resource Management Department
Logistics & Finance Department
Planning, Strategy & Policy Department
Accident Investigation Unit
Aeronautical Services Department
International Airports
Air Transport Department
International Relations & Legal Affair Department
Civil Aviation Training Centre
Domestic Airports
Director General for (Operation & Technical)
Standards & Flight safety Department
Airworthiness Department
Standards & Air Nav. Safety Department
Standards & Airport Safety Department
Aviation Security Department
Security/safety Oversight Department

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៤៩ អនក្រ.បក

# អនុក្រឹត្យ

# ស្តីពី

# ការកំណត់ខ្នាតសម្រាប់ការប្រឡងប្រណាំងទីក្រុងស្អាត

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីទេសចរណ៍
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦១១/៦១៤ ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១១ ស្តីពីការបង្កើតគណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត
- បានឃើញអនុក្រឹត្យលេខ ៣៤.អនក្រ.បក ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ២៧.អនក្រ.បក ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍និងជាប្រធាន **គ.ជ.វ.ស.**

## សម្រេច

**មាត្រា ១.-**

អនុក្រឹត្យនេះមានគោលដៅកំណត់អំពីរង្វាន់សម្រាប់ទីក្រុងដែលចូលរួមប្រឡងប្រណាំងទីក្រុងស្អាត ដើម្បីជាការលើកទឹកចិត្តនិងបញ្ជាក់អំពីកិច្ចខិតខំប្រឹងប្រែងរបស់ទីក្រុងក្នុងការរៀបចំ និងការអភិវឌ្ឍទីក្រុងរបស់ខ្លួនឱ្យស័ក្តិសមជាគោលដៅបៃតងប្រកបដោយភាពទាក់ទាញនិងផ្តល់ភាពកក់ក្តៅដល់ប្រជាពលរដ្ឋក្នុងទីក្រុងនិងភ្ញៀវទេសចរ។

**មាត្រា ២.-**

រង្វាន់សម្រាប់ទីក្រុងជ័យលាភី ត្រូវបានផ្តល់ជូនក្រោមរូបភាពជាពានរង្វាន់ដែលមានឡាបិលរូបផ្កាវិជ្ជុល ចាប់ពីថ្នាក់ផ្កា០១(មួយ) ផ្កា០២(ពីរ) និងផ្កា០៣(បី) ដែលមានចែងក្នុងស្តង់ដាទីក្រុងស្អាត ហើយរង្វាន់លើកទឹកចិត្តបន្ថែមទៀតក៏អាចត្រូវបានផ្តល់ជូនផងដែរ។

ពានរង្វាន់និងរង្វាន់លើកទឹកចិត្តបន្ថែមត្រូវបានប្រគល់ជូន បន្ទាប់ពីទទួលបានវិញ្ញាបនបត្រទទួលស្គាល់ដែលចេញដោយនាយករដ្ឋមន្ត្រី និងជាប្រធានកិត្តិយសនៃ **គ.ជ.ទ.ឆ.** តាមរយៈសំណើរបស់ប្រធាន **គ.ជ.ទ.ឆ.**។

រង្វាន់លើកទឹកចិត្តបន្ថែម ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

វិញ្ញាបនបត្រទទួលស្គាល់និងពានរង្វាន់សម្រាប់ទីក្រុងជ័យលាភី ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា ៣.-**

រង្វាន់លើកទឹកចិត្តសម្រាប់ទីក្រុងដែលមិនទទួលបានជ័យលាភី ត្រូវបានកំណត់ទៅតាមពិន្ទុដែលទទួលបានលើសូចនាករគោលនីមួយៗនៃស្តង់ដាទីក្រុងស្អាត។

ទីក្រុងដែលមិនទទួលបានជ័យលាភី អាចទទួលបានរង្វាន់លើកទឹកចិត្តពីប្រធាន **គ.ជ.ទ.ឆ.**។

ប្រភេទនៃរង្វាន់លើកទឹកចិត្តសម្រាប់ទីក្រុងដែលមិនទទួលបានជ័យលាភី ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ **គ.ជ.ទ.ឆ.**។

**មាត្រា ៤.-**

ពានរង្វាន់ត្រូវប្រគល់ជូនទីក្រុងជ័យលាភីសម្រាប់រយៈពេល០៣(បី)ឆ្នាំ គិតចាប់ពីថ្ងៃចេញវិញ្ញាបនបត្រទទួលស្គាល់ដោយនាយករដ្ឋមន្ត្រី។

ករណីទីក្រុងជ័យលាភីបានបាត់បង់ឬមិនគោរពតាមលក្ខណវិនិច្ឆ័យដែលមានចែងក្នុងស្តង់ដាទីក្រុងស្អាត កម្រិតនៃពានរង្វាន់អាចត្រូវបានបញ្ចុះថ្នាក់ឬដកហូតដោយនាយករដ្ឋមន្ត្រី តាមរយៈសំណើរបស់ប្រធាន **គ.ជ.ទ.ឆ.**។

**មាត្រា ៥.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៦.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងទេសចរណ៍និងជាប្រធាន **គ.ជ.ទ.ឆ.** រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ អភិបាលនៃគណៈ-អភិបាលរាជធានីខេត្តទាំង២៤ អគ្គលេខាធិការនៃ **គ.ជ.ទ.ឆ.** ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ២០១២

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជូន
សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី ដើម្បីស្នើសុំចុះហត្ថលេខា
**រដ្ឋមន្ត្រីក្រសួងទេសចរណ៍**

**ថោង ខុន**

*កន្លែងទទួល៖*
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ទីស្តីការគណៈរដ្ឋមន្ត្រី*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៦*
- *រាជកិច្ច*
- *ឯកសារកាលប្បវត្តិ*

**ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ២៩ អនក្រ.បក ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ២០១២**
**ស្ដីពីការកំណត់រង្វាន់សម្រាប់ការប្រឡងប្រណាំងទីក្រុងស្អាត**
**ពានរង្វាន់សម្រាប់ទីក្រុងជ័យលាភី**



**ពានរង្វាន់សម្រាប់ទីក្រុងជ័យលាភី**
**ដែលទទួលបានឡាបិលរូបផ្ការំដួល ១ ទង**



**ពានរង្វាន់សម្រាប់ទីក្រុងជ័យលាភី**
**ដែលទទួលបានឡាបិលរូបផ្ការំដួល ២ ទង**



**ពានរង្វាន់សម្រាប់ទីក្រុងជ័យលាភី**
**ដែលទទួលបានឡាបិលរូបផ្ការំដួល ៣ ទង**

## គំរូវិញ្ញាបនបត្រទទួលស្គាល់ទីក្រុងជ័យលាភី




វិញ្ញាបនបត្រទទួលស្គាល់ទីក្រុងជ័យលាភី
ដែលទទួលបានឡាប៊ែលរូបផ្ការំដួល ៣ ទង

## គំរូវិញ្ញាបនបត្រទទួលស្គាល់ទីក្រុងជ័យលាភី




វិញ្ញាបនបត្រទទួលស្គាល់ទីក្រុងជ័យលាភី
ដែលទទួលបានឡាបិលរូបផ្ការំដួល ២ ទង

## គំរូវិញ្ញាបនបត្រទទួលស្គាល់ទីក្រុងជ័យលាភី



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**វិញ្ញាបនបត្រទទួលស្គាល់ជ័យលាភី**
Certificate of Trophy
ផ្តល់ជូន
Awarded to

--------
(ឈ្មោះទីក្រុង)
**ទទួលបានចំណាត់ថ្នាក់ទីក្រុងស្អាត**
**ផ្ការំដួល ១ ទង**
For Winning an Award of Clean City
1 Rumduol flowers

ទីក្រុងស្អាត
Clean City

សុពលភាព

ថ្ងៃទី ខែ ឆ្នាំ
លេខ:.......

នាយករដ្ឋមន្ត្រី
ហត្ថលេខា និង ត្រា

**វិញ្ញាបនបត្រទទួលស្គាល់ទីក្រុងជ័យលាភី**
**ដែលទទួលបានឡាបិលរូបផ្ការំដួល ១ ទង**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខៈ** ៧០ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការធ្វើអនុបយោគ ផ្ទៃដីទំហំ ៥.៩៨០ ហិកតា ក្នុងតំបន់សម្បទានដីសេដ្ឋកិច្ច ស្ថិតនៅក្នុងភូមិសាស្ត្រស្រុក សង្គមថ្មី និងស្រុករវៀង ខេត្តព្រះវិហារ

# រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល

-បានឃើញព្រះរាជក្រមលេខនស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកម/០៨០៦/៣៣៩ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ

-បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និង របស់នីតិបុគ្គលសាធារណៈ

-យោងតាមសំណើរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# សម្រេច

**មាត្រា១:**

ត្រូវបានចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ នូវផ្ទៃដីទំហំ ៥.៩៨០ (ប្រាំពាន់ប្រាំបួនរយប៉ែតសិប) ហិកតា ស្ថិតក្នុងភូមិសាស្ត្រស្រុកសង្គមថ្មី និងស្រុករវៀង ខេត្តព្រះវិហារ ក្រោមល័ក្ខខ័ណ្ឌសម្បទានដើម្បីធ្វើការវិនិយោគអភិវឌ្ឍន៍លើវិស័យដំណាំកសិ-ឧស្សាហកម្ម (កៅស៊ូ) ដូចមានក្នុងផែនទី និងនិយាមកាដែលជាឯកសារភ្ជាប់នឹងលិខិតលេខ ១១៥៣ សជណ ចុះថ្ងៃទី ០៩ ខែកញ្ញា ឆ្នាំ២០១១ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា២:**

ផ្ទៃដីដែលត្រូវបានធ្វើអនុបយោគ ដូចកំណត់ក្នុងមាត្រា១ នៃអនុក្រឹត្យនេះត្រូវស្ថិតក្រោមការចាត់ចែងនីតិវិធីបន្ត ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ព្រមទាំងមានកិច្ចសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដី ស្របតាមច្បាប់ និងគោលការណ៍របស់រាជរដ្ឋាភិបាល។

**មាត្រា៣:**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៤:**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គ្រប់ក្រសួងស្ថាប័ន និងអភិបាលខេត្តព្រះវិហារ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ២០១២

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល:

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- រាជកិច្ច
- ឯកសារកាលប្បវត្តិ

**ផែនទីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ឆាយណា ម្រ៉េនឌស (ខេមបូឌា) អ៊ិនវេសមេន ស្ថិតនៅឃុំស្ដៅ ឃុំចំរើន និងឃុំមេធម ស្រុកសង្គមថ្មី និង ស្រុករវៀង ខេត្តព្រះវិហារ**



**សញ្ញាសំគាល់**

- ▲ ក្រែ
- ● ទីរួមភូមិ/ទំនុកនាគ
- ព្រំប្រទល់ដី
- ផ្លូវ
- ផ្លូវលំ
- ព្រំប្រទល់ស្រុក
- ព្រំប្រទល់ឃុំ
- តំបន់ទ្រនាប់ផ្លូវទឹក ១ ១១៤ ហ.ត
- តំបន់ព្រៃការពារទុក ១ ៥១៧ ហ.ត

គម្របព្រៃឈើ២០០៦

- ព្រៃស្រោង ៦៣៩ ហ.ត
- ព្រៃពាក់កណ្ដាលស្រោង ១ ១៣៥ ហ.ត
- ព្រៃល្បោះ ៦ ៤៦៤ ហ.ត
- ព្រៃរបោះ ១ ៩៦៥ ហ.ត
- ដីគ្មានគម្របព្រៃ ១២៩ ហ.ត

**ផ្ទៃដីកាត់ពីផ្លូវសាធារណៈរដ្ឋ ២០ ហិកតា**
**ផ្ទៃដីផ្លូវការពារទុកសរុប ២ ៩៣១ ហិកតា**
**ផ្ទៃដីវិនិយោគសរុប ៥ ៩៨០ ហិកតា**

**ផ្ទៃដីស្នើសុំសរុប ៨ ៩៣១ ហិកតា**

| | |
|---|---|
| Coordinate System | |
| Projection | UTM |
| Zone | 48 |
| Grid | 1 Km |
| Horizontal Datum | Indian 1960 |
| Spheroid | Everest |

មាត្រដ្ឋាន ១ : ៧០ ០០០

0 0.5 1 2 Kilometers

លេខ ២៦៧

បានឃើញ និងឯកភាព

បញ្ជូនមក លោកអភិបាលស្រុក ពិនិត្យសម្រេច

ស្ដៅ, ថ្ងៃទី ២៩ ខែ ១១ ឆ្នាំ២០១១

មេឃុំ

ឆន_អ៊ុន

លេខ ៣០៨/១១ ចម

បានឃើញ និងឯកភាព

បញ្ជូនមក លោកអភិបាលស្រុក ពិនិត្យសម្រេច

ចំរើន, ថ្ងៃទី ២៩ ខែ ១១ ឆ្នាំ២០១១

មេឃុំ

សោម_សុខុម

លេខ ៤៥៧/១១

បានឃើញ និងឯកភាព

បញ្ជូនមក លោកអភិបាលស្រុក ពិនិត្យសម្រេច

រមេធម, ថ្ងៃទី ២៩ ខែ ១១ ឆ្នាំ២០១១

មេឃុំ

លេខ ......

បានឃើញ និងឯកភាព

បញ្ជូនមក លោកអភិបាលស្រុក ពិនិត្យសម្រេច

សង្គមថ្មី, ថ្ងៃទី ២៩ ខែ ១១ ឆ្នាំ២០១១

ប្រធានភូមិបាលស្រុក

សុខ ជូលីន

លេខ ០២៩/១១

បានឃើញ និងឯកភាព

បញ្ជូនមក លោកអភិបាលស្រុក ពិនិត្យសម្រេច

រវៀង, ថ្ងៃទី ២៩ ខែ ១១ ឆ្នាំ២០១១

ប្រធានភូមិបាលស្រុក

ឡុង_រិទ្ធី

លេខ ០៤២

បានឃើញ និងឯកភាព

បញ្ជូនមក លោកអភិបាលស្រុក ពិនិត្យសម្រេច

រវៀង, ថ្ងៃទី ២៩ ខែ ១១ ឆ្នាំ២០១១

ការិយាល័យកសិកម្មស្រុក

ឈិន.ស្ទួយ

លេខ ១៤/១១

បានឃើញ និងឯកភាព

បញ្ជូនមក លោកអភិបាលស្រុក ពិនិត្យសម្រេច

សង្គមថ្មី, ថ្ងៃទី ២៩ ខែ ១១ ឆ្នាំ២០១១

ការិយាល័យកសិកម្មស្រុក

ហ៊ី ហាច

លេខ ៤០៩

បានឃើញ និងឯកភាព

គោរពជូន ឯកឧត្តមអភិបាលខេត្ត មេត្តាពិនិត្យសម្រេច

សង្គមថ្មី, ថ្ងៃទី ២៩ ខែ ១១ ឆ្នាំ២០១១

អភិបាលស្រុក

រស់_ហេង

លេខ ៤៩៤ ជ.ល

បានឃើញ និងឯកភាព

គោរពជូន ឯកឧត្តមអភិបាលខេត្ត មេត្តាពិនិត្យសម្រេច

រវៀង, ថ្ងៃទី ២៩ ខែ ១១ ឆ្នាំ២០១១

អភិបាលស្រុក

ឈុយ សារី

លេខ ៤២៦ មស្ដ.ចា

បានឃើញ និងឯកភាព

គោរពជូន ឯកឧត្តមអភិបាលខេត្ត មេត្តាពិនិត្យសម្រេច

ព្រះវិហារ, ថ្ងៃទី ៣០ ខែ ១១ ឆ្នាំ២០១១

ប្រធានមន្ទីរបរិស្ថានខេត្ត

ខួយ_យុនចន្ទរ៉ុត្ន

លេខ ៣៥១

បានឃើញ និងឯកភាព

គោរពជូន ឯកឧត្តមអភិបាលខេត្ត មេត្តាពិនិត្យសម្រេច

ព្រះវិហារ, ថ្ងៃទី ៣០ ខែ ១១ ឆ្នាំ២០១១

ប្រធានមន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត

គួច_សោភ័ណ

បានឃើញ និងឯកភាព

គោរពជូន ឯកឧត្តមអភិបាលខេត្ត មេត្តាពិនិត្យសម្រេច

ព្រះវិហារ, ថ្ងៃទី ០១ ខែ ១២ ឆ្នាំ២០១១

ប្រធានមន្ទីរកសិកម្មខេត្ត

ពិន.ទ្រឹដ

លេខ ៤៧៥២.អភខ

បានឃើញ និងឯកភាព

គោរពជូន ឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មេត្តាពិនិត្យសម្រេច

ព្រះវិហារ, ថ្ងៃទី ០៥ ខែ ១២ ឆ្នាំ២០១១

អភិបាលខេត្ត

ឌឹម ហ៊ាក់

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ១៧៩ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការតែងតាំង និងប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០០/០៥៦ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីក្រមការ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៥១ ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៥២ ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០២ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសមធ្យម
- បានឃើញអនុក្រឹត្យលេខ ១៨ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- បានឃើញអនុក្រឹត្យលេខ ៦៣ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការគ្រប់គ្រងការអនុវត្តន៍ ការផ្លាស់ប្តូរក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់របស់មន្ត្រីរាជការស៊ីវិល
- តាមសំណើរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

## សម្រេច

**មាត្រា ១ :** ត្រូវបានតែងតាំងមន្ត្រីរាជការចំនួន ១១រូប នៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ដូចមានរាយនាមខាងក្រោម ÷

១. លោក **រំចេក សុខ៉ារី** ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានបច្ចេកទេស

២. លោក **ប៉ាន់ ចាន់ឡារ័ត្ន** ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានបច្ចេកទេស

៣.លោក **សូ ណាសុត** ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានបច្ចេកទេស

៤. លោក **តឹក សាលី** ជាអគ្គនាយករងនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងកិច្ចការទូទៅ

៥. លោក **សិទ្ធ សាកល** ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានបច្ចេកទេស

៦. លោក **ស៊ិន ចាន់សិរីឧត្តរា** ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានបច្ចេកទេស

៧. លោកស្រី **ទេព ស៊ុន្ធរី** ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានបច្ចេកទេស

៨. លោក **សេខ ម៉ាន្នី** ជាប្រធាននាយកដ្ឋានរដ្ឋបាលនិងគ្រប់គ្រងធនធានមនុស្ស

៩. លោក **ពាខ សារី** ជាប្រធាននាយកដ្ឋានសេវាកម្មអាកាសចរណ៍

១០. លោក **សុខ ពុធឡើន** ជាប្រធាននាយកដ្ឋានស្តង់ដានិងសុវត្ថិភាពអាកាសយានដ្ឋាន

១១. លោក **ម៉ុន រដ្ឋា** ជានាយកអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ។

**មាត្រា ២ :** ត្រូវបានប្រគល់ភារកិច្ចជូនមន្ត្រីរាជការចំនួន ១៨រូប នៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ដូចមានរាយនាមខាងក្រោម ÷

១. លោក **លី សែន** ឲ្យបំពេញមុខងារជាអគ្គនាយករងនៃអគ្គនាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅ

២. លោក **ស៊ូ លីន** ឲ្យបំពេញមុខងារជាអគ្គនាយករងនៃអគ្គនាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅ

៣. លោក **មួខ រិទ្ធី** ឲ្យបំពេញមុខងារជាអគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅ

៤. លោក **ម៉ែន ផាន់ណា** ឲ្យបំពេញមុខងារជាអគ្គនាយករង នៃអគ្គនាយកដ្ឋានបច្ចេកទេស

៥. លោក **ពេញ ណារ៉ា** ឲ្យបំពេញមុខងារជាអគ្គនាយករង នៃអគ្គនាយកដ្ឋានបច្ចេកទេស

៦. លោក **និត្យ ខន្លា** ឲ្យបំពេញមុខងារជានាយកអាកាសយានដ្ឋានអន្តរជាតិសៀមរាប

៧. លោក **ម៉ក់ សំអុល** ឲ្យបំពេញមុខងារជាប្រធាននាយកដ្ឋានត្រួតពិនិត្យសន្តិសុខ និងសុវត្ថិភាពអាកាសចរណ៍

៨. លោក **ឈុន ស៊ីថន** ឲ្យបំពេញមុខងារជាប្រធាននាយកដ្ឋានស្តង់ដា និងសុវត្ថិភាព នាំផ្លូវអាកាស

៩. លោក **ម៉ាត់ សុទ្ធិ** ឲ្យបំពេញមុខងារជាប្រធានអង្គភាពស៊ើបអង្កេតគ្រោះថ្នាក់ អាកាសចរណ៍

១០. លោក **ផាន់ ចាន់ធុច** ឲ្យបំពេញមុខងារជាប្រធាននាយកដ្ឋានសន្តិសុខអាកាសចរ ស៊ីវិល

១១. លោក **លឹម តៅ** ឲ្យបំពេញមុខងារជាប្រធាននាយកដ្ឋានស្តង់ដានិងសុវត្ថិភាពហោះហើរ

១២. លោក **ខាន់ ចន្ទី** ឲ្យបំពេញមុខងារជាប្រធាននាយកដ្ឋានដឹកជញ្ជូនតាមផ្លូវអាកាស

១៣. លោក **ហ៊ុន ឈឿន** ឲ្យបំពេញមុខងារជានាយកអាកាសយានដ្ឋានអន្តរជាតិខេត្តព្រះសីហនុ

១៤. លោក **ខឹម ទិសាល** ឲ្យបំពេញមុខងារជាប្រធាននាយកដ្ឋានលទ្ធភាពហោះហើរ

១៥. លោក **ស្រី សោភា** ឲ្យបំពេញមុខងារជាប្រធាននាយកដ្ឋានកស្តុភារ និងហិរញ្ញវត្ថុ

១៦. លោក **សារិន គុណ្ណាករ** ឲ្យបំពេញមុខងារជាប្រធាននាយកដ្ឋានទំនាក់ទំនងអន្តរជាតិនិងនីតិកម្ម

១៧. លោក **ដេត មឿន** ឲ្យបំពេញមុខងារជានាយកមជ្ឈមណ្ឌលហ្វឹកហ្វឺនអាកាសចរស៊ីវិល

១៨. លោក **មីច សត្យា** ឲ្យបំពេញមុខងារជាប្រធាននាយកដ្ឋានផែនការ យុទ្ធសាស្ត្រ និងគោលនយោបាយ។

**មាត្រា ៣** : បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា ៤** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ និងមាត្រា ២ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល** :

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៤*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៩៨ - អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយសហមេត្រី

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

### សម្រេច

**មាត្រា ១.-**

ត្រូវបានបំពាក់ **មេដាយសហមេត្រី ថ្នាក់ ធិបឌិន្ទ** ជូនអ្នកជំនាញការជប៉ុន ចំនួន១៩រូប ដែលបានខិតខំប្រឹងប្រែងជាច្រើនឆ្នាំ ក្នុងកិច្ចសហការជាមួយក្រុមការងារក្រសួងយុត្តិធម៌ និងសម្រេចបានល្អប្រសើរលើគម្រោងកសាងក្រមរដ្ឋប្បវេណី និងច្បាប់ពាក់ព័ន្ធនៃព្រះរាជាណាចក្រកម្ពុជា ដូចមានរាយនាមខាងក្រោម ៖

| | |
|---|---|
| ១-Mr. Morishima Akio | សាស្ត្រាចារ្យកិត្តិយស សាកលវិទ្យាល័យ Nagoya |
| ២-Mr. Kamata kaoru | សាស្ត្រាចារ្យកិត្តិយស សាកលវិទ្យាល័យ Waseda |
| ៣-Mr. Matsumoto Tsuneo | សាស្ត្រាចារ្យកិត្តិយស សាកលវិទ្យាល័យ Hitotsubashi |
| ៤-Mr. Minami Toshifumi | ចៅក្រមសាលាឧទ្ធរណ៍តំបន់ Tokyo |
| ៥-Mr. Motoyama Atsushi | សាស្ត្រាចារ្យ សាកលវិទ្យាល័យ Ritsumeikan |
| ៦-Mr. Nomi Yoshihisa | ព្រឹទ្ធបុរស និងជាសាស្ត្រាចារ្យសាកលវិទ្យាល័យ Tokyo |
| ៧-Mr. Nomura Toyohiro | សាស្ត្រាចារ្យសាកលវិទ្យាល័យ Gakushuin |
| ៨-Mr. Yamamoto Yutaka | សាស្ត្រាចារ្យសាកលវិទ្យាល័យ Kyoto |
| ៩-Mr. Tanamura Masayuki | សាស្ត្រាចារ្យសាកលវិទ្យាល័យ Waseda |
| ១០-Mr. Urakawa Michitaro | សាស្ត្រាចារ្យសាកលវិទ្យាល័យ Waseda |
| ១១-Mr. Niimi Ikufumi | សាស្ត្រាចារ្យសាកលវិទ្យាល័យ Meiji |
| ១២-Mr. Sakano Issei | អតីតទីប្រឹក្សានៃគម្រោងអភិវឌ្ឍន៍ វិស័យច្បាប់និងយុត្តិធម៌ |

| | |
|---|---|
| ១៣-Mr. Kamiki Atsushi | អតីតទីប្រឹក្សាច្បាប់នៃគម្រោងអភិវឌ្ឍន៍វិស័យច្បាប់ និងយុត្តិធម៌ |
| ១៤-Mss. Manabe Kana | អតីតទីប្រឹក្សានៃគម្រោងអភិវឌ្ឍន៍ វិស័យច្បាប់និងយុត្តិធម៌ |
| ១៥-Mrs. Sakuragi Kazuyo | អតីតអ្នកសម្របសម្រួលនៃគម្រោងអភិវឌ្ឍន៍ វិស័យច្បាប់និងយុត្តិធម៌ |
| ១៦-Mrs. Homma Yoshiko | អតីតទីប្រឹក្សាច្បាប់នៃគម្រោងអភិវឌ្ឍន៍វិស័យច្បាប់ និងយុត្តិធម៌ |
| ១៧-Mr. Harada Masayoshi | ទីប្រឹក្សាច្បាប់នៃគម្រោងអភិវឌ្ឍន៍វិស័យច្បាប់ និងយុត្តិធម៌ |
| ១៨-Mrs. Kanetake EmiKo | ទីប្រឹក្សាច្បាប់ និងអ្នកសម្របសម្រួលនៃគម្រោងអភិវឌ្ឍន៍វិស័យច្បាប់ និងយុត្តិធម៌ |
| ១៩-Mss. Tamiya Ayako | ទីប្រឹក្សាច្បាប់នៃគម្រោងអភិវឌ្ឍន៍វិស័យច្បាប់និងយុត្តិធម៌ |

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែកុម្ភៈ ឆ្នាំ ២០១២

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ដូចមាត្រា១ និងមាត្រា២
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ២៤០ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយការងារ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់អភិបាលនៃគណៈអភិបាលខេត្តព្រះសីហនុ

## សម្រេច

**មាត្រា ១.-**

ត្រូវបានបំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការនិងសប្បុរសជន ចំនួន៣៤រូប ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចបំរើជាតិមាតុភូមិ កន្លងមក ដូចមានរាយនាមខាងក្រោម ៖

**ក-មេដាយមាសការងារ**

| | |
|---|---|
| ១-លោក ជួង ចន្ទ្រា | មន្ត្រីរដ្ឋបាលព្រៃឈើ ផ្នែកស្រែអំបិល ខេត្តកោះកុង |
| ២-លោក ទឹម សាន | ប្រធានការដ្ឋាន ក្រុមហ៊ុន AZ ផ្លូវជាតិលេខ៤ |
| ៣-អនុសេនីយ៍ទោឆេព ណារិទ្ធ | អត្តលេខ ១៤៦១៨ នាយប៉ុស្តិ៍រដ្ឋបាលនគរបាល ឃុំអូរបាក់រទេះ |
| ៤-ព្រិន្ទបាលឯក ស៊ិន ឯក | អត្តលេខ៤២២៣០ នាយរងផ្នែកសន្តិសុខ នគរបាលស្រុកកំពង់សីលា |
| ៥-លោក សេង សោភ័ណ្ឌ | ប្រធានការិយាល័យមន្ទីរទំនាក់ទំនងរដ្ឋសភា ខេត្តព្រះសីហនុ |
| ៦-លោក សន រិទ្ធី | ប្រធានគ្រប់គ្រងរដ្ឋបាលទូទៅ ក្រុមហ៊ុនសលជីប៉ុនគ្រុប |
| ៧-កញ្ញា សន រស្មី | អនុប្រធានគ្រប់គ្រងរដ្ឋបាលទូទៅ ក្រុមហ៊ុនសលជីប៉ុនគ្រុប |
| ៨-លោក ជួង ឆាយវិបុល | មន្ត្រីរដ្ឋបាលព្រៃឈើ ស្រុកកំពង់សីលា ខេត្តព្រះសីហនុ |
| ៩-លោក អ៊ុន ម៉ុនធឿន | មន្ត្រីរដ្ឋបាលព្រៃឈើ ស្រុកកំពង់សីលា ខេត្តព្រះសីហនុ |
| ១០-លោកស្រី ផាត សុភ្នុល | ប្រធានសមាគមយឹតយោងកុមារជនបទ ឃុំកំពង់សីលា |
| ១១-ពលបាលទោហង្ស រិទ្ធី | អត្តលេខ ៥៩៩១៦ មន្ត្រីរដ្ឋបាលប៉ុស្តិ៍នគរបាល ឃុំអូរបាក់រទេះ |
| ១២-លោក គង់ សុទ្ធឡី | នាយកសាលាវិទ្យាល័យហ៊ុន សែន កំពង់សីលា ស្រុកកំពង់សីលា |

១៣-លោក ស៊ី ហេង ទីប្រឹក្សាក្រុងព្រះសីហនុ ខេត្តព្រះសីហនុ

១៤-លោកស្រី ផេង ស៊ីម៉ាឡា អនុប្រធានការិ. ថវិកានីយកម្ម និងហិរញ្ញកិច្ច មន្ទីរហិរញ្ញវត្ថុ

១៥-លោកស្រី ជួន ម៉ិនណ្ណារី អនុប្រធានការិ. រដ្ឋបាលនិងបុគ្គលិកហិរញ្ញវត្ថុ មន្ទីរហិរញ្ញវត្ថុ

ខ-មេជាយប្រាក់ការងារ:

១-លោក ជាំ គួច មន្ត្រីថវិកានីយកម្ម ហិរញ្ញកិច្ច មន្ទីរហិរញ្ញវត្ថុ ខេត្តព្រះសីហនុ

២-លោក ឃុត សុខាន់ មន្ត្រីថវិកានីយកម្ម ហិរញ្ញកិច្ច មន្ទីរហិរញ្ញវត្ថុ ខេត្តព្រះសីហនុ

៣-លោកស្រី យ៉ង់ សុធី មន្ត្រីថវិកានីយកម្ម ហិរញ្ញកិច្ច មន្ទីរហិរញ្ញវត្ថុ ខេត្តព្រះសីហនុ

៤-លោក ឌឹម វ៉ាន់ធុច មន្ត្រីរដ្ឋបាលនិងបុគ្គលិកហិរញ្ញវត្ថុ មន្ទីរហិរញ្ញវត្ថុ ខេត្តព្រះសីហនុ

៥-អនុសេនីយ៍ត្រីតូច ចន្ធី អត្តលេខ ២៤២៥៣ នាយរងផ្នែកយុត្តិធម៌ ស្រុកកំពង់សីលា

៦-ព្រិន្ទបាលឯកអៀត ធីរៈ អត្តលេខ ៥៩៨៧៤ នាយរងប៉ុស្តិ៍ រដ្ឋបាលនគរបាល ឃុំអូរបាក់រទេះ

៧-ព្រិន្ទបាលទោឆេត ណារិន អត្តលេខ ៥៩៩១៥ មន្ត្រីប៉ុស្តិ៍រដ្ឋបាល នគរបាល ឃុំអូរបាក់រទេះ

៨-លោក ជួន គីមឡុង អនុប្រធានស្ថានីយ៍ ស្ទឹងច្រាល ក្រុមហ៊ុន AZ ផ្លូវជាតិលេខ៤

៩-លោក គុណា ចិ សប្បុរសជន

១០-លោកស្រី លាស់ លីន មន្ត្រីថវិកានីយកម្ម ហិរញ្ញកិច្ច មន្ទីរហិរញ្ញវត្ថុ ខេត្តព្រះសីហនុ

១១-លោក ជួង សុខផល អាចារ្យវត្តព្រៃប្រសិទ្ធ ឃុំអូរបាក់រទេះ ស្រុកកំពង់សីលា

១២-លោក លឹម ទ្រី សប្បុរសជន ឃុំស្ទឹងឆាយ ស្រុកកំពង់សីលា ខេត្តព្រះសីហនុ

១៣-លោកស្រី សន មឿន បុគ្គលិកពេទ្យ មណ្ឌលសុខភាពតក្កវិទ្ធ ស្រុកកំពង់សីលា

១៤-លោក សុខ ស៊ុនហេង មេភូមិស្ទឹងឆាយខាងត្បូង ឃុំស្ទឹងឆាយ ស្រុកកំពង់សីលា

១៥-លោក កេត ផន មេភូមិស្ទឹងឆាយខាងជើង ឃុំស្ទឹងឆាយ ស្រុកកំពង់សីលា

១៦-លោក ម៉ា ឡោត មេភូមិអូរតាហាយ ឃុំស្ទឹងឆាយ ស្រុកកំពង់សីលា

១៧-លោក អ៊ិត គីម មេភូមិគីរីវ័ន្ត ឃុំស្ទឹងឆាយ ស្រុកកំពង់សីលា

១៨-លោក សួន ឡាច អនុប្រធានភូមិស្ទឹងឆាយខាងត្បូង ឃុំស្ទឹងឆាយ ស្រុកកំពង់សីលា

១៩-ព្រិន្ទបាលទោឆាយ ភន អត្តលេខ ៤២២៧៤ មន្ត្រីនគរបាល ប៉ុស្តិ៍រដ្ឋបាល ឃុំស្ទឹងឆាយ

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលនៃគណៈអភិបាលខេត្តព្រះសីហនុ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ២២១ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ អភិបាលនៃគណៈអភិបាលខេត្តព្រះសីហនុ

### សម្រេច

**មាត្រា ១.-**

ត្រូវបានបំពាក់ មេដាយមុនីសារាភ័ណ្ឌ តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការ និង សប្បុរសជន ចំនួន ៣៤រូប ដែលមានស្នាដៃល្អ ក្នុងការបំពេញភារកិច្ច បម្រើជាតិមាតុភូមិ និងជួយអភិវឌ្ឍន៍ខេត្តព្រះសីហនុ កន្លងមក ដូចមានរាយព្រះនាម និងនាមខាងក្រោម៖

**ក-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ ធិបឌិន្ទ**

| | | | |
|---|---|---|---|
| ១- | ព្រះតេជគុណ | គង់ ប្រុស | ព្រះគ្រូចៅអធិការវត្ត ព្រហ្មកេរ្តិ៍ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ |
| ២- | ព្រះតេជគុណ | ចេច កុសល | ព្រះគ្រូចៅអធិការវត្ត ព្រៃប្រសិទ្ធិ ឃុំអូរបាក់រទេះ ស្រុកកំពង់សីលា |
| ៣- | លោក | អាថ លីអេង | នាយកក្រុមហ៊ុន ឌីវីឡុបម៉ែនខបភរ៉េហ្សិន អេនខនស្ត្រាក់សិន |
| ៤- | លោកស្រី | យុន យុន | នាយិការងក្រុមហ៊ុន ឌីវីឡុបម៉ែនខបភរ៉េហ្សិន អេនខនស្ត្រាក់សិន |
| ៥- | លោក | គិន រួច | សប្បុរសជន |
| ៦- | លោក | ឈ្នួន គីមសាន | សប្បុរសជន |

**ខ-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ សេនា**

| | | | |
|---|---|---|---|
| ១- | លោក | ហេង ហឿន | មេឃុំស្ទឹងឆាយ ស្រុកកំពង់សីលា ខេត្តព្រះសីហនុ |
| ២- | លោក | ឌី សារ៉ុម | សមាជិកក្រុមប្រឹក្សាឃុំកំពង់សីលា ស្រុកកំពង់សីលា ខេត្តព្រះសីហនុ |
| ៣- | លោក | ឌិន ថេង | សប្បុរសជន |
| ៤- | លោក | គុក សំអ៊ាន | អនុប្រធានភូមិបាលស្រុកស្រែអំបិល ខេត្តកោះកុង |
| ៥- | អនុសេនីយ៍ឯក | ចាន់ សេដ្ឋា | អត្តលេខ ០១៤៥៨៦ អធិការរងនគរបាល ស្រុកកំពង់សីលា ខេត្តព្រះសីហនុ |
| ៦- | អនុសេនីយ៍ឯក | សេង រតនា | អត្តលេខ ០៤៣០៩ អធិការរងនគរបាល ស្រុកកំពង់សីលា ខេត្តព្រះសីហនុ |
| ៧- | អនុសេនីយ៍ឯក | ឈុំ ទិត្យា | អត្តលេខ ០១៤៥៧៨ អធិការរងនគរបាល ស្រុកថ្មបាំង ខេត្តព្រះសីហនុ |

៨- អនុសេនីយ៍ឯក ហួត ចាន់ធី អគ្គលេខ ០២៣៧៨៥ អធិការរងនគរបាល ស្រុកកំពង់សីលា ខេត្តព្រះសីហនុ

៩- អនុសេនីយ៍ឯក ឡូច សទ្ធា អគ្គលេខ ០១០១៨១ អធិការរងនគរបាល ស្រុកកំពង់សីលា ខេត្តព្រះសីហនុ

១០- អនុសេនីយ៍ទោ អៀម ជា អគ្គលេខ ០២៣៧១៥ នាយប៉ុស្តិ៍ រដ្ឋបាលនគរបាល ឃុំចំការហ្លួង ស្រុកកំពង់សីលា

១១- អនុសេនីយ៍ត្រី អ៊ុក សុភាព អគ្គលេខ ៥៩៨៨១ នាយរងប៉ុស្តិ៍ រដ្ឋបាលនគរបាល ឃុំស្ទឹងឆាយ ស្រុកកំពង់សីលា

១២- លោក សួន សំអឿន សប្បុរសជន

គ-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ អស្សឫទ្ធិ

១- អនុសេនីយ៍ឯក គិត ឆាយ អគ្គលេខ ០២៣៣៦០ អនុប្រធានមន្ទីរភស្តុភារ កងរាជអាវុធហត្ថ ខេត្តព្រះសីហនុ

២- អនុសេនីយ៍ឯក អ៊ិត ជីវី អគ្គលេខ ០២០៦០៨ នាយសេនាធិការដ្ឋាន កងរាជអាវុធហត្ថ ខេត្តព្រះសីហនុ

៣- អនុសេនីយ៍ឯក លាង ឈឿច អគ្គលេខ ០២០៥៦០ មេបញ្ជាការរង កងរាជអាវុធហត្ថ ខណ្ឌទួលគោក

៤- លោក អ៊ុំ ទុទ្ធី នាយរងផ្នែករដ្ឋបាលព្រៃឈើ ស្រុកកំពង់សីលា ខេត្តព្រះសីហនុ

៥- លោក ម៉ែន កុសល ប្រធានស្វ័យការពារសន្តិសុខឃុំស្ទឹងឆាយ ស្រុកកំពង់សីលា

៦- លោក ប្រាក់ សុវណ្ណ អនុប្រធានមន្ទីរអភិវឌ្ឍន៍ជនបទ ខេត្តព្រះសីហនុ

៧- អនុសេនីយ៍ទោ ជួង នាម អគ្គលេខ ១៨២២៩ នាយប៉ុស្តិ៍ រដ្ឋបាលនគរបាល ឃុំកំពង់សីលា

៨- លោក ឌុន នី ប្រធានការិយាល័យធម្មការ និងសាសនា ស្រុកកំពង់សីលា

៩- លោក ខៀវ ពៅ ប្រធានការិយាល័យបរិស្ថាន ស្រុកកំពង់សីលា ខេត្តព្រះសីហនុ

១០- វរសេនីយ៍ទោ អ៊ុំ សុខា អគ្គលេខ ០៨៥៨៦ នាយការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនិតិជន នគរបាល ខេត្តព្រះសីហនុ

១១- វរសេនីយ៍ត្រី អ៊ឹម ចលក្ខណ៍ អគ្គលេខ ០៨៣៥១ នាយរងការិយាល័យអន្តោប្រវេសន៍ ខេត្តព្រះសីហនុ

១២- លោក ស្បោង ពៅ ជំនួយការឯកឧត្តមអភិបាលខេត្តព្រះសីហនុ

១៣- លោក សារ៉ាត ចន្ទទរៈ ជំនួយការឯកឧត្តមអភិបាលខេត្តព្រះសីហនុ

១៤- លោក ខៀវ ម៉ុនធឿន ជំនួយការឯកឧត្តមអភិបាលខេត្តព្រះសីហនុ

១៥- លោក ឆាន សារេត ជំនួយការឯកឧត្តមអភិបាលខេត្តព្រះសីហនុ

១៦- លោក សៀន ពុធ ជំនួយការឯកឧត្តមអភិបាលខេត្តព្រះសីហនុ

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលនៃគណៈអភិបាលខេត្តព្រះសីហនុ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ, ថ្ងៃទី ៧ ខែ កុម្ភៈ ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៤៤៧ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយសុវត្ថារា

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ អភិបាលនៃគណៈអភិបាលខេត្តព្រះសីហនុ

**សម្រេច**

**មាត្រា ១.-**

ត្រូវបានបំពាក់ មេដាយសុវត្ថារា ថ្នាក់ ធិបឌិន្ទ ជូនមន្ត្រីរាជការ និង សប្បុរសជន ចំនួន ១៤រូប ដែលមានស្នាដៃល្អ ក្នុងការបំពេញភារកិច្ច បម្រើជាតិមាតុភូមិ កន្លងមក និងជួយអភិវឌ្ឍន៍ ខេត្តព្រះសីហនុ ដូចមានរាយនាមខាងក្រោម៖

| | | | |
|---|---|---|---|
| ១- | លោក | ឌី សុខុម | នាយខណ្ឌរដ្ឋបាលព្រៃឈើខេត្តព្រះសីហនុ |
| ២- | លោក | ស្រ៊ុន ម៉ិនថាត | សប្បុរសជន |
| ៣- | លោកស្រី | សេង ផល្លីន | នាយិការង ក្រុមហ៊ុនសលជីប៊ុនគ្រុប |
| ៤- | លោក | ជា សុពុទ្ធី | ប្រធានអគ្គិសនីខេត្តព្រះសីហនុ |
| ៥- | លោក | ឯម ភាព | នាយកទីចាត់ការ ផែនការ និងវិនិយោគ ខេត្តព្រះសីហនុ |
| ៦- | វរៈសេនីយ៍ឯក | សុខ សាគល | អត្តលេខ ០០២៨៣២ មេបញ្ជាការរង និងជានាយសេនាធិការតំបន់ប្រតិបត្តិការសឹករង ខេត្តព្រះសីហនុ |
| ៧- | លោក | គី ទុឡា | អនុប្រធានអគ្គិសនី ទទួលបន្ទុកអាជីវកម្ម ខេត្តព្រះសីហនុ |
| ៨- | លោក | ឆ៉ាត សិត | នាយករង នាយកដ្ឋានគណនេយ្យ-ហិរញ្ញវត្ថុ កំពង់ផែស្វយ័ត ខេត្តព្រះសីហនុ |
| ៩- | វរៈសេនីយ៍ត្រី | ហុង សារិន | អត្តលេខ ០១៦៩០២ នាយផ្នែកវិស្វកម្ម និងសំណង់អភិវឌ្ឍន៍អគ្គបញ្ជាការ |
| ១០- | លោក | ឡុង ស៊ីម៉ូ | ប្រធានស្នាក់ការពន្ធដារ ស្រុកស្រែអំបិល ខេត្តកោះកុង |
| ១១- | លោក | ព្រហ្ម ខេមរា | សប្បុរសជន |
| ១២- | លោកស្រី | តួង និស្សរ៉ូយ | សប្បុរសជន |

១៣- លោកស្រី សេង ផល្លី សប្បុរសជន

១៤- លោកស្រី គុណ ដានី សប្បុរសជន

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលនៃគណៈអភិបាលខេត្តព្រះសីហនុ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ... ខែ កុម្ភៈ ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល:**

- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ដូចមាត្រា១ និងមាត្រា២
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការដំឡើងថ្នាក់មន្ត្រីរាជការ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២ ៥ ខែ កញ្ញា ឆ្នាំ ២ ០០៨ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងទេសចរណ៍

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៨ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងធនធានទឹក និងឧតុនិយម

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងបរិស្ថាន

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៥១ ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់
-បានឃើញអនុក្រឹត្យលេខ ៣៤ អនក្រ.បក ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
-បានឃើញអនុក្រឹត្យលេខ ៥៨ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងធនធានទឹក និងឧតុនិយម
-បានឃើញអនុក្រឹត្យលេខ ៥៧ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
-បានឃើញអនុក្រឹត្យលេខ ៥៥ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
-បានឃើញអនុក្រឹត្យលេខ ១៤ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន
-បានឃើញអនុក្រឹត្យលេខ ១៣ អនក្រ.បក ចុះថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០០៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
-បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
-យោងតាមសំណើរបស់រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

## សម្រេច

**មាត្រា១..** ត្រូវបានដំឡើងថ្នាក់ប្រចាំឆ្នាំជូនមន្ត្រីរាជការចំនួន ៤៤ រូប ក្នុងឋានន្តរស័ក្តិរមន្ត្រី នៃក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាលរបស់ក្រសួង ស្ថាប័ន ចាប់ពីថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ២០១១ ដូចមានរាយនាមខាងក្រោម ៖

| **ក្រសួងទេសចរណ៍** | | | | |
|---|---|---|---|---|
| ល.រ | នាម និងគោត្តនាម | ភេទ | ឋានន្តរស័ក្តិចាស់ និងថ្នាក់ចាស់ | ថ្នាក់ស្នើសុំ |
| ១ | **ឡុង ធីរៈ** | ប | ពីរមន្ត្រី ថ្នាក់លេខ ៥ | ទៅថ្នាក់លេខ ៤ |
| ២ | **ជុង ឡឹម** | ប | ពីរមន្ត្រី ថ្នាក់លេខ ៦ | ទៅថ្នាក់លេខ ៥ |
| ៣ | **កើត ពុទ្ធថវី** | ប | ពីរមន្ត្រី ថ្នាក់លេខ ៦ | ទៅថ្នាក់លេខ ៥ |
| ៤ | **អ៊ុំ ឃីម** | ប | ពីរមន្ត្រី ថ្នាក់លេខ ៦ | ទៅថ្នាក់លេខ ៥ |
| ៥ | **ប្រាក់ ច័ន្ទតារា** | ប | ពីរមន្ត្រី ថ្នាក់លេខ ៨ | ទៅថ្នាក់លេខ ៧ |
| ៦ | **សុខ តុងហាប់** | ប | ពីរមន្ត្រី ថ្នាក់លេខ ១០ | ទៅថ្នាក់លេខ ៩ |
| ៧ | **ម៉ៅ សុចិត្រា** | ប | ពីរមន្ត្រី ថ្នាក់លេខ ១០ | ទៅថ្នាក់លេខ ៩ |
| **ក្រសួងធនធានទឹក និងឧតុនិយម** | | | | |
| ល.រ | នាម និងគោត្តនាម | ភេទ | ឋានន្តរស័ក្តិចាស់ និងថ្នាក់ចាស់ | ថ្នាក់ស្នើសុំ |
| ១ | **សៅ សេរីមុន្នី** | ប | ពីរមន្ត្រី ថ្នាក់លេខ ៦ | ទៅថ្នាក់លេខ ៥ |
| ២ | **ឯម ម៉ិនធឿន** | ប | ពីរមន្ត្រី ថ្នាក់លេខ ៥ | ទៅថ្នាក់លេខ ៤ |
| ៣ | **ម៉ី លីហួត** | ប | ពីរមន្ត្រី ថ្នាក់លេខ ៥ | ទៅថ្នាក់លេខ ៤ |
| ៤ | **ជង សេងអ៊ីម** | ប | ពីរមន្ត្រី ថ្នាក់លេខ ៥ | ទៅថ្នាក់លេខ ៤ |
| ៥ | **ជួន មិត្តថុល** | ប | ពីរមន្ត្រី ថ្នាក់លេខ ៥ | ទៅថ្នាក់លេខ ៤ |
| ៦ | **ថេង តារា** | ប | ពីរមន្ត្រី ថ្នាក់លេខ ៧ | ទៅថ្នាក់លេខ ៦ |

| **ក្រសួងបរិស្ថាន** | | | | |
|---|---|---|---|---|
| ល.រ | នាម និងគោត្តនាម | ភេទ | ឋានន្តរស័ក្តិចាស់ និងថ្នាក់ចាស់ | ថ្នាក់ស្នើសុំ |
| ១ | **សំ ខាន់ឌី** | ប | ពីវរមន្ត្រី ថ្នាក់លេខ ៣ | ទៅថ្នាក់លេខ ២ |
| ២ | **អៀង ចិត្រា** | ប | ពីវរមន្ត្រី ថ្នាក់លេខ ៥ | ទៅថ្នាក់លេខ ៤ |
| ៣ | **កុច សុខាន** | ប | ពីវរមន្ត្រី ថ្នាក់លេខ ៦ | ទៅថ្នាក់លេខ ៥ |
| ៤ | **ទេព ផល្លា** | ប | ពីវរមន្ត្រី ថ្នាក់លេខ ៦ | ទៅថ្នាក់លេខ ៥ |
| ៥ | **ម៉េង សាខុធ** | ប | ពីវរមន្ត្រី ថ្នាក់លេខ ៦ | ទៅថ្នាក់លេខ ៥ |
| ៦ | **ខួន គង់** | ប | ពីវរមន្ត្រី ថ្នាក់លេខ ៧ | ទៅថ្នាក់លេខ ៦ |
| ៧ | **អ៊ុក សីហា** | ស | ពីវរមន្ត្រី ថ្នាក់លេខ ៧ | ទៅថ្នាក់លេខ ៦ |
| ៨ | **ជឹម វណ្ណា** | ប | ពីវរមន្ត្រី ថ្នាក់លេខ ៨ | ទៅថ្នាក់លេខ ៧ |
| ៩ | **ជួន ច័ន្ទរិទ្ធី** | ប | ពីវរមន្ត្រី ថ្នាក់លេខ ៨ | ទៅថ្នាក់លេខ ៧ |
| ១០ | **ឌិន ពន្លក** | ប | ពីវរមន្ត្រី ថ្នាក់លេខ ៨ | ទៅថ្នាក់លេខ ៧ |
| ១១ | **មាស សុផល** | ប | ពីវរមន្ត្រី ថ្នាក់លេខ ៨ | ទៅថ្នាក់លេខ ៧ |
| ១២ | **ឡុង រិទ្ធីវឌ្ឍ** | ប | ពីវរមន្ត្រី ថ្នាក់លេខ ៩ | ទៅថ្នាក់លេខ ៨ |
| ១៣ | **កែន សេរីវឌ្ឍា** | ប | ពីវរមន្ត្រី ថ្នាក់លេខ ១០ | ទៅថ្នាក់លេខ ៩ |
| ១៤ | **គល់ ខន្ធរ៉ា** | ប | ពីវរមន្ត្រី ថ្នាក់លេខ ១០ | ទៅថ្នាក់លេខ ៩ |
| ១៥ | **គីម ណុង** | ប | ពីវរមន្ត្រី ថ្នាក់លេខ ១០ | ទៅថ្នាក់លេខ ៩ |
| ១៦ | **ចាន់ សុម៉ាលី** | ប | ពីវរមន្ត្រី ថ្នាក់លេខ ១០ | ទៅថ្នាក់លេខ ៩ |
| ១៧ | **ជ្រិន សុខា** | ប | ពីវរមន្ត្រី ថ្នាក់លេខ ១០ | ទៅថ្នាក់លេខ ៩ |
| ១៨ | **ឈុន វណ្ណៈ** | ប | ពីវរមន្ត្រី ថ្នាក់លេខ ១០ | ទៅថ្នាក់លេខ ៩ |
| ១៩ | **ទឹម ម៉ានី** | ប | ពីវរមន្ត្រី ថ្នាក់លេខ ១០ | ទៅថ្នាក់លេខ ៩ |
| ២០ | **ពុទ្ធ សុរិទ្ធី** | ប | ពីវរមន្ត្រី ថ្នាក់លេខ ១០ | ទៅថ្នាក់លេខ ៩ |
| ២១ | **ម៉ម សុវណ្ណា** | ប | ពីវរមន្ត្រី ថ្នាក់លេខ ១០ | ទៅថ្នាក់លេខ ៩ |
| ២២ | **វ៉ាន់ មុនីនាថ** | ប | ពីវរមន្ត្រី ថ្នាក់លេខ ១០ | ទៅថ្នាក់លេខ ៩ |
| ២៣ | **ស្រី ម៉ារ៉ូណា** | ប | ពីវរមន្ត្រី ថ្នាក់លេខ ១០ | ទៅថ្នាក់លេខ ៩ |
| ២៤ | **ស៊ី រ៉ាមុនី** | ប | ពីវរមន្ត្រី ថ្នាក់លេខ ១០ | ទៅថ្នាក់លេខ ៩ |
| ២៥ | **ហេង តារិទ្ធ** | ប | ពីវរមន្ត្រី ថ្នាក់លេខ ១០ | ទៅថ្នាក់លេខ ៩ |
| ២៦ | **ហោរ ស៊ីម៉េង** | ប | ពីវរមន្ត្រី ថ្នាក់លេខ ១០ | ទៅថ្នាក់លេខ ៩ |
| ២៧ | **អេង គឹមសាន** | ប | ពីវរមន្ត្រី ថ្នាក់លេខ ១០ | ទៅថ្នាក់លេខ ៩ |

| **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** | | | | |
|---|---|---|---|---|
| ល.រ | នាម និងគោត្តនាម | ភេទ | ឋានន្តរស័ក្តិចាស់ និងថ្នាក់ចាស់ | ទៅថ្នាក់ស្នើសុំ |
| ១ | **យិន សារឿន** | ប | ពីវរមន្ត្រី ថ្នាក់លេខ ៦ | ទៅថ្នាក់លេខ ៥ |
| ២ | **លឹម អេលឡូរ៉ាដូ** | ប | ពីវរមន្ត្រី ថ្នាក់លេខ ៥ | ទៅថ្នាក់លេខ ៤ |
| ៣ | **គឹម ហុង** | ប | ពីវរមន្ត្រី ថ្នាក់លេខ ៤ | ទៅថ្នាក់លេខ ៣ |
| ៤ | **អ៊ុន ស៊ីដេត** | ប | ពីវរមន្ត្រី ថ្នាក់លេខ ៦ | ទៅថ្នាក់លេខ ៥ |

**មាត្រា២.-** ត្រូវបានដំឡើងថ្នាក់តាមកម្រិតសញ្ញាបត្រជូនមន្ត្រីរាជការចំនួន ០២ រូប ក្នុងឋានន្តរស័ក្តិវរមន្ត្រី នៃក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល របស់ក្រសួងស្ថាប័ន ដូចមានរាយនាមខាងក្រោម ៖

| **ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍** | | | | |
|---|---|---|---|---|
| ល.រ | នាម និងគោត្តនាម | ភេទ | ឋានន្តរស័ក្តិចាស់ និងថ្នាក់ចាស់ | ទៅថ្នាក់ស្នើសុំ |

| | | | | |
|---|---|---|---|---|
| ១ | **ឈី សុខា** | ប | ពីវរមន្ត្រី ថ្នាក់លេខ ៧ | ទៅថ្នាក់លេខ ៦ |
| **ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល** | | | | |
| ល.រ | នាម និងគោត្តនាម | ភេទ | ឋានន្តរស័ក្តិចាស់ និងថ្នាក់ចាស់ | ទៅថ្នាក់ស្នើសុំ |
| ១ | **យក់ ប៊ុនសិន** | ប | ពីវរមន្ត្រី ថ្នាក់លេខ ៣ | ទៅថ្នាក់លេខ ២ |

**មាត្រា៣.-** ត្រូវបានដំឡើងថ្នាក់តាមកម្រិតសញ្ញាបត្រជូនមន្ត្រីរាជការចំនួន ០១ រូប ក្នុងឋានន្តរស័ក្តិវរមន្ត្រី នៃក្របខណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ របស់ក្រសួងសាធារណការ និងដឹកជញ្ជូន ដូចមាននាមខាងក្រោម ៖

| **ក្រសួងសាធារណការ និងដឹកជញ្ជូន** | | | | |
|---|---|---|---|---|
| ល.រ | នាម និងគោត្តនាម | ភេទ | ឋានន្តរស័ក្តិចាស់ និងថ្នាក់ចាស់ | ថ្នាក់ស្នើសុំ |
| ១ | **នូ ចន្ថារៈ** | ប | ពីមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ១០ | ទៅថ្នាក់លេខ ៩ |

**មាត្រា៤.-** មន្ត្រីរាជការដែលត្រូវបានដំឡើងថ្នាក់ដូចមានឈ្មោះក្នុងមាត្រា ២ និងមាត្រា ៣ ខាងលើ ត្រូវរក្សាទុកអតីតភាពសម្រាប់ឡើងថ្នាក់ តាមវេនជ្រើសរើស និងវេនអតីតភាពជដែល។

**មាត្រា៥.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ មាត្រា២ និងមាត្រា៣ ខាងលើត្រូវអនុវត្តអនុក្រឹត្យនេះឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០១២

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា៥
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ២៤៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិរជនដែលត្រូវជូនគ្រឿងឥស្សរិយយស

## សម្រេច

**មាត្រា ១.-**

ត្រូវបានបំពាក់ មេដាយមុនីសារាភ័ណ្ឌ តាមលំដាប់ថ្នាក់ ជូនសប្បុរសជន ចំនួន៣៣រូប ដែលមានស្នាដៃល្អក្នុងការចូលរួមឧបត្ថម្ភគាំពារដល់ដំណើរការកសាងអង្គភាពបញ្ជាការដ្ឋានជាតិកម្លាំងពិសេស ប្រឆាំងភេរវកម្មកន្លងមក ដូចមានរាយនាមខាងក្រោម ៖

**ក-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ សេនា:**

| | | | |
|---|---|---|---|
| ១-លោកឧកញ៉ា | សេង | ទូច | សប្បុរសជន |
| ២-ឯកឧត្តម | ពេញ | ធារម្យ | សប្បុរសជន |
| ៣-ឯកឧត្តម | សៅ | លី | សប្បុរសជន |
| ៤-លោក | ហាំង | តុលា | សប្បុរសជន |
| ៥-លោក | លាង | សំណាត់ | សប្បុរសជន |
| ៦-លោក | ជាម | ឃុនណាត | សប្បុរសជន |
| ៧-លោក | ឆាយ | សេងអៀង | សប្បុរសជន |
| ៨-លោក | ឡៅ | លីហុក | សប្បុរសជន |
| ៩-លោក | ឈួរ | ម៉េង | សប្បុរសជន |
| ១០-លោក | តាំង | គួង | សប្បុរសជន |
| ១១-ឯកឧត្តម | គាត | រស្មី | សប្បុរសជន |

| | | | |
|---|---|---|---|
| ១២-លោក | ហែម | រិទ្ធី | សប្បុរសជន |
| ១៣-លោក | ឈួ | ទិចិត្រ | សប្បុរសជន |
| ១៤-លោក | ហេង | ស្រេង | សប្បុរសជន |
| ១៥-លោក | ឆន់ | ឆែអ៊ាង | សប្បុរសជន |
| ១៦-លោក | ហេង | សារ៉ា | សប្បុរសជន |
| ១៧-លោក | អ៊ួច | ទិចិត្រ | សប្បុរសជន |

ក-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ អស្សឫទ្ធិ៍:

| | | | |
|---|---|---|---|
| ១-លោក | អាន | ជាលី | សប្បុរសជន |
| ២-លោក | ដួង | មុនី | សប្បុរសជន |
| ៣-លោក | ប៊ុន | សារម៉េត | សប្បុរសជន |
| ៤-លោក | ប៊ុន | សុភក្តិរិទ្ធ | សប្បុរសជន |
| ៥-លោកវេជ្ជបណ្ឌិត | ចាន់ | សុភ័ស្ត | សប្បុរសជន |
| ៦-លោកវេជ្ជបណ្ឌិត | ស៊ឹម | ស៊ូយ៉េង | សប្បុរសជន |
| ៧-លោកវេជ្ជបណ្ឌិត | ស៊ូ | ស៊ីផាន់ណា | សប្បុរសជន |
| ៨-លោកវេជ្ជបណ្ឌិត | ស៊ឹម | សុខចាន់ | សប្បុរសជន |
| ៩-លោកវេជ្ជបណ្ឌិត | ឡុង | សុគា | សប្បុរសជន |
| ១០-លោក | ឆូច | លីដែល | សប្បុរសជន |
| ១១-លោក | ម៉ៅ | គន្ធា | សប្បុរសជន |
| ១២-លោក | សេង | ប៊ុនឡឿន | សប្បុរសជន |
| ១៣-លោក | មាស | តារា | សប្បុរសជន |
| ១៤-លោកបណ្ឌិត | ភង | ចំរុងដារ៉ាវត្ត | សប្បុរសជន |
| ១៥-លោក | ភួយ | ឡេប៉ូ | សប្បុរសជន |
| ១៦-លោក | ម៉ាន់ | ចំរុងឌី | សប្បុរសជន |

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិរវជនដែលត្រូវជូនគ្រឿងឥស្សរិយយស ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១២

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ២៧៨ អនក្រ.បក

## អនុក្រឹត្យ

## ស្ដីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្ដីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិរវជនដែលត្រូវជូនគ្រឿងឥស្សរិយយស

**សម្រេច**

**មាត្រា ១.-**

ត្រូវបានបំពាក់ មេដាយមាសស្ថាបនាជាតិ ជូនសប្បុរសជន ចំនួន២០រូប ដែលបានចូលរួមឧបត្ថម្ភគាំពារដល់ដំណើរការកសាងអង្គភាពបញ្ជាការដ្ឋានជាតិកម្លាំងពិសេសប្រឆាំងភេរវកម្ម កន្លងមក ដូចមានរាយនាមខាងក្រោម ៖

| | | | |
|---|---|---|---|
| ១-លោក | គឹម | ឧុទ្ធី | សប្បុរសជន |
| ២-លោក | តែ | ជួរ | សប្បុរសជន |
| ៣-លោកស្រី | ឡៅ | អានី | សប្បុរសជន |
| ៤-លោក | ឈី | ពៅ | សប្បុរសជន |
| ៥-លោក | ជា | ចំណាន | សប្បុរសជន |
| ៦-លោកឧកញ៉ា | ម៉ា | ឆេង | សប្បុរសជន |
| ៧-លោកឧកញ៉ា | ម៉ិន | ចាន់នី | សប្បុរសជន |
| ៨-លោក | YABUMOTO YUTO | | សប្បុរសជន |
| ៩-លោក | GINO D.YOUNG YOO | | សប្បុរសជន |
| ១០-លោកឧកញ៉ា | LAWRENCE YAP | | សប្បុរសជន |
| ១១-លោក | ZHUO WEN ZE | | សប្បុរសជន |
| ១២-លោក | LIN LUN | | សប្បុរសជន |

| | | |
|---|---|---|
| ១៣-ក្រុមហ៊ុន | N.C.X CO., LTD | |
| ១៤-លោក | CHEN CHANG JIANG | សប្បុរសជន |
| ១៥-លោក | XIANG DI GANG | សប្បុរសជន |
| ១៦-លោក | TAN T. CHUA | សប្បុរសជន |
| ១៧-លោក | SHI YONG PING | សប្បុរសជន |
| ១៨-ក្រុមហ៊ុន | T.C.M Engineering | |
| ១៩-ក្រុមហ៊ុន | Xing Yuan Kanng Yeak | |
| ២០-លោក | WEI CHANG HUI | សប្បុរសជន |

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ កុម្ភៈ ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ដូចមាត្រា១ និងមាត្រា២
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខៈ ០៤៦២ សហវ.ប្រក

# ប្រកាស
## ស្តីពី
## ការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន និង យានជំនិះគ្រប់ប្រភេទ សម្រាប់ឆ្នាំ២០១២

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ

-បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៩/០២៦ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១០

-បានឃើញក្រឹត្យលេខ ២៤/ក្រ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ១៩៩១ ដែលប្រកាសឱ្យប្រើច្បាប់ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ១៩៩១ ស្តីពីការបង្កើតពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ

-បានឃើញអនុក្រឹត្យលេខ ០៨/អនក្រ ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៩១ ស្តីពីការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ

-បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតម្លើងទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យទៅជាអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រង របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-យោងតាមការងារចាំបាច់ក្នុងការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទសម្រាប់ឆ្នាំ២០១២

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
www.mef.gov.kh
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798
mef_adm@yahoo.com

## សម្រេច ៖

**ប្រការ១**.- ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទសម្រាប់ឆ្នាំ២០១២ ត្រូវប្រមូលចាប់ពីថ្ងៃទី ១៥ ខែកុម្ភៈ ឆ្នាំ២០១២ រហូតដល់ថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០១២ ។

**ប្រការ២**.- ដើម្បីបង់ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទសម្រាប់ឆ្នាំ២០១២ ម្ចាស់មធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ ត្រូវបំពេញលិខិតប្រកាសចំនួន ០២ សន្លឹក តាមគំរូឯកភាពរបស់អគ្គនាយកដ្ឋានពន្ធដារ (លើកលែងតែម្ចាស់ទោចក្រយានយន្ត និងត្រីចក្រយានយន្តបំពាក់ដោយម៉ាស៊ីនម៉ូតូ) ព្រមទាំងបង្ហាញ និងប្រគល់ជូនមន្ត្រីដែលមានសមត្ថកិច្ច នូវបង្កាន់ដៃបង់ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទសម្រាប់ឆ្នាំ២០១១ ដើម្បីជាភស្តុតាងបញ្ជាក់ថាមធ្យោបាយដឹកជញ្ជូន និងយានជំនិះនោះបានបង់ពន្ធសម្រាប់ឆ្នាំ២០១១ រួចហើយ ។

**ប្រការ៣**.- ម្ចាស់មធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទណា ពុំមានបង្កាន់ដៃបង់ពន្ធបញ្ជាក់ថាបានបង់ពន្ធឆ្នាំ២០១១ ទេនោះ ម្ចាស់មធ្យោបាយដឹកជញ្ជូន និងយានជំនិះនោះ ត្រូវបង់ប្រាក់ពន្ធសម្រាប់ឆ្នាំ២០១១ និងត្រូវបង់ប្រាក់ពិន័យ ដែលមានចំនួនស្មើនឹងប្រាក់ពន្ធ ទើបអនុញ្ញាតឱ្យបង់ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទសម្រាប់ ឆ្នាំ២០១២ ។

**ប្រការ៤**.- ម្ចាស់មធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទណាដែលបាត់បង្កាន់ដៃបង់ពន្ធសម្រាប់ឆ្នាំ២០១១ ម្ចាស់មធ្យោបាយដឹកជញ្ជូន និងយានជំនិះនោះ ត្រូវមានលិខិតបញ្ជាក់ថាបានបង់ពន្ធសម្រាប់ឆ្នាំ២០១១ រួចហើយ ដែលចេញដោយប្រធានសាខាពន្ធដារខេត្ត-ខណ្ឌ នៃទីកន្លែងដែលយានយន្តនោះបានបង់ពន្ធសម្រាប់ឆ្នាំ២០១១ ។

**ប្រការ៥**.- ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ ត្រូវកំណត់លើគ្រប់មធ្យោបាយដឹកជញ្ជូន និងយានជំនិះ ទៅតាមប្រភេទនីមួយៗ ដូចមានចែងក្នុងតារាងឧបសម្ព័ន្ធ I និង II ភ្ជាប់ជាមួយនឹងប្រកាសនេះ ដោយមិនគិតថាជារបស់រដ្ឋ ឬឯកជនឡើយ ។

**ប្រការ៦**.- ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះនេះ ត្រូវបានលើកលែងចំពោះ ៖

- រថយន្តគិលានសង្គ្រោះ រថយន្តពន្លត់អគ្គីភ័យរបស់រដ្ឋ
- មធ្យោបាយដឹកជញ្ជូន និងយានជំនិះ ជាកម្មសិទ្ធិរបស់កងយោធពលខេមរភូមិន្ទ កងរាជអាវុធហត្ថ នគរបាលជាតិ ដែលបំរើឱ្យការងារសំរាប់កិច្ចការពារប្រទេស សន្តិសុខ និងសណ្តាប់ធ្នាប់សង្គម
- មធ្យោបាយដឹកជញ្ជូន និងយានជំនិះ របស់បេសកកម្មទូត ឬកុងស៊ុលបរទេស អង្គការអន្តរជាតិ ឬទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលនានា ។

**ប្រការ៧**.- ក្រោយពេលបង់ពន្ធបានត្រឹមត្រូវរួចហើយ ម្ចាស់មធ្យោបាយដឹកជញ្ជូន និងយានជំនិះនីមួយៗត្រូវបានទទួលបង្កាន់ដៃបង់ពន្ធមួយសន្លឹក និងបណ្ណបង់ពន្ធមួយសន្លឹក សំរាប់បិទភ្ជាប់មធ្យោបាយដឹកជញ្ជូន និងយានជំនិះនីមួយៗនោះ ។ បង្កាន់ដៃបង់ពន្ធនេះត្រូវថែរក្សាកុំឱ្យបាត់បង់ និងត្រូវយកជាប់ជាមួយយានយន្តសម្រាប់ទុកបង្ហាញមន្ត្រីត្រួតពិនិត្យដែលមានសមត្ថកិច្ច និងទុកជាឯកសារសម្រាប់បង់ពន្ធឆ្នាំ២០១៣ ។

**ប្រការ៨.-** សម្រាប់ឆ្នាំ២០១២ បណ្ណបង់ពន្ធដែលត្រូវបិទភ្ជាប់នឹងមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ មានរូបភាព និងលក្ខណៈសំគាល់ដូចខាងក្រោម ៖

**១.បណ្ណរាងអដ្ឋកោណ ៖**

នៅផ្នែកខាងលើនៃបណ្ណមានបោះពុម្ពអក្សរ "**ព្រះរាជាណាចក្រកម្ពុជា**" "**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**" "**អគ្គនាយកដ្ឋានពន្ធដារ**" និងលេខ "**២០១២**" ។ ផ្នែកកណ្តាលបណ្ណមានបោះពុម្ព Hologram រូបហង្សមានស្នើប្រាំពីរពណ៌ព្រមទាំងមានកម្រងស្លឹកឈើទ្រពីក្រោមតាមរចនាបថអង្គរ និងអក្សរ "**បណ្ណបង់ពន្ធរថយន្ត**" ឬ "**បណ្ណបង់ពន្ធត្រាក់ទ័រ**" ។ នៅផ្នែកខាងក្រោមបណ្ណមានបោះពុម្ព Barcode ដោយអមជាមួយនូវលេខរៀង៧ខ្ទង់របស់បណ្ណ ។ ផ្នែកខាងក្រោយនៃសន្លឹកបណ្ណ និងបង្កាន់ដៃរបស់បណ្ណមានបង្កប់បន្ទះឈីប (Chip) សម្រាប់ការពារការក្លែងបន្លំបណ្ណ (លើកលែងបណ្ណបង់ពន្ធត្រាក់ទ័រ) ។

បណ្ណរាងអដ្ឋកោណនេះមាន១៥ពណ៌គឺ ៖

- បណ្ណពណ៌ត្រាវប្រើសម្រាប់ ត្រាក់ទ័រមានកម្លាំង ៣៥ សេះ (៣០.០០០រៀល)
- បណ្ណពណ៌បៃតងប្រើសម្រាប់ ត្រាក់ទ័រមានកម្លាំង ៦៥ សេះ (៤០.០០០រៀល)
- បណ្ណពណ៌លឿងទុំប្រើសម្រាប់ ត្រាក់ទ័រមានកម្លាំង ៨២ សេះ (៥០.០០០រៀល)
- បណ្ណពណ៌ផ្កាឈូក(៨០.០០០រៀល) ប្រើសម្រាប់ ៖
  + រថយន្តទេសចរណ៍ទំហំស៊ីឡាំងដល់ ១៥០០ ស.ម³ គិតពីឆ្នាំផលិតលើសពី ៥ឆ្នាំ
- បណ្ណពណ៌ខៀវខ្ចី(១០០.០០០រៀល) ប្រើសម្រាប់ ៖
  + រថយន្តទេសចរណ៍ទំហំស៊ីឡាំងដល់ ១៥០០ ស.ម³ គិតពីឆ្នាំផលិតដល់ ៥ឆ្នាំ
  + រថយន្តទេសចរណ៍ទំហំស៊ីឡាំងលើសពី១៥០០ ស.ម³ដល់២០០០ស.ម³ គិតពីឆ្នាំផលិតលើសពី៥ឆ្នាំ
- បណ្ណពណ៌ស្វាយ (១៥០.០០០រៀល) ប្រើសម្រាប់ ៖
  + រថយន្តដឹកទំនិញដល់ ៣ តោន
  + រថយន្តដឹកអ្នកដំណើរមានកៅអីដល់ ១៥ កៅអី
  + រថយន្តទេសចរណ៍ទំហំស៊ីឡាំងលើសពី១៥០០ស.ម³ដល់២០០០ស.ម³គិតពីឆ្នាំផលិតដល់ ៥ឆ្នាំ
- បណ្ណពណ៌លឿង(២០០.០០០រៀល) ប្រើសម្រាប់ ៖
  + រថយន្តដឹកអ្នកដំណើរធុនមធ្យមមានកៅអីពី ១៦ ដល់ ២៥ កៅអី
- បណ្ណពណ៌ក្រហម (២៥០.០០០រៀល)ប្រើសម្រាប់ ៖
  + រថយន្តដឹកទំនិញលើសពី ៣ តោន ដល់ ១០ តោន
  + រ៉ឺម៉កសណ្តោង ដល់ ១០ តោន
  + រថយន្តដឹកអ្នកដំណើរធុនធំមានកៅអីលើសពី ២៥
- បណ្ណពណ៌ទឹកប៊ិច (៣៦០.០០០រៀល) ប្រើសម្រាប់ ៖
  + រថយន្តទេសចរណ៍ទំហំស៊ីឡាំងលើសពី២០០០ស.ម³ដល់ ២៩០០ស.ម³ គិតពីឆ្នាំផលិតលើសពី៥ឆ្នាំ
- បណ្ណពណ៌ខៀវ (៤៥០.០០០រៀល) ប្រើសម្រាប់ ៖
  + រថយន្តដឹកទំនិញលើសពី ១០ តោន ដល់ ២០ តោន
  + រ៉ឺម៉កសណ្តោងលើសពី ១០ តោន ដល់ ២០ តោន
- បណ្ណពណ៌បៃតងចាស់ (៥០០.០០០រៀល) ប្រើសម្រាប់ ៖

+ រថយន្តទេសចរណ៍ទំហំស៊ីឡាំងលើសពី ២០០០ ស.ម³ ដល់ ២៩០០ ស.ម³ គិតពី ឆ្នាំផលិតដល់ ៥ឆ្នាំ

- បណ្ណពណ៌បៃតងរំលេចពណ៌លឿង (៧៥០.០០០រៀល) ប្រើសម្រាប់ ៖
  + រថយន្តដឹកទំនិញលើសពី ២០ តោន
  + រ៉ឺម៉កសណ្តោងលើសពី ២០ តោន
- បណ្ណពណ៌ផ្កាឈូករំលេចពណ៌បៃតង (១.២០០.០០០រៀល) ប្រើសម្រាប់ ៖
  + រថយន្តទេសចរណ៍ទំហំស៊ីឡាំងលើសពី ២៩០០ស.ម³ ដល់ ៤០០០ ស.ម³ គិតពីឆ្នាំផលិតលើសពី ៥ឆ្នាំ
- បណ្ណពណ៌ទឹកប៊ិចរំលេចពណ៌លឿង (១.៦០០.០០០រៀល)ប្រើសម្រាប់ ៖
  + រថយន្តទេសចរណ៍ទំហំស៊ីឡាំងលើសពី ២៩០០ស.ម³ ដល់ ៤០០០ ស.ម³ គិតពីឆ្នាំផលិតដល់ ៥ឆ្នាំ
- បណ្ណពណ៌ឈាមជ្រូករំលេចពណ៌ត្រួយចេក (២.០០០.០០០រៀល)ប្រើសម្រាប់ ៖
  + រថយន្តទេសចរណ៍ទំហំស៊ីឡាំងលើសពី ៤០០០ ស.ម³ ឡើងទៅ

**២. បណ្ណរាងរង្វង់មូល ៖**

នៅផ្នែកខាងលើនៃបណ្ណមានបោះពុម្ពអក្សរ "**ព្រះរាជាណាចក្រកម្ពុជា**" "**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**" "**អគ្គនាយកដ្ឋានពន្ធដារ**" និងលេខ "**២០១២**"។ ផ្នែកកណ្តាលបណ្ណមានបោះពុម្ព Hot Stamping រូបហង្សមានស្មៃប្រាំពីរពណ៌ព្រមទាំងមានកំរងស្លឹកឈើទ្រពីក្រោមតាមរចនាបថអង្គរ និងអក្សរ "**បណ្ណបង់ពន្ធលើយានយន្ត**" ។ នៅផ្នែកខាងក្រោមបណ្ណមានបោះពុម្ព Barcode ដោយអមជាមួយនូវលេខរៀង៧ខ្ទង់របស់បណ្ណនិងលេខតំណាងទីកប្រាក់ពន្ធតាមប្រភេទបណ្ណនីមួយៗ។

បណ្ណរាងរង្វង់មូលនេះ មាន៤ពណ៌គឺ ៖

- បណ្ណពណ៌បៃតងរំលេចពណ៌លឿងទុំ (៣.០០០រៀល) ប្រើសម្រាប់ ៖
  + ទោចក្រយានយន្តទំហំពិស្តុង ដល់ ៧០ សម³
- បណ្ណពណ៌ទឹកប៊ិចរំលេចពណ៌បៃតង (៤.៥០០រៀល) ប្រើសម្រាប់ ៖
  + ទោចក្រយានយន្តមានទំហំពិស្តុងលើសពី ៧០ សម³ ទៅ ១២៥ សម³
- បណ្ណពណ៌ខៀវខ្ចីរំលេចពណ៌ផ្កាឈូក (៧.៥០០រៀល) ប្រើសម្រាប់ ៖
  + ទោចក្រយានយន្តមានទំហំពិស្តុងលើសពី ១២៥ សម³ ឡើងទៅ
- បណ្ណពណ៌ផ្កាឈូករំលេចពណ៌លឿង (១៥.០០០រៀល) ប្រើសម្រាប់ ៖
  + ត្រីចក្រយានយន្ត និងម៉ូតូរ៉ឺម៉កដឹកទំនិញ ឬអ្នកដំណើរ (បំពាក់ដោយម៉ាស៊ីនម៉ូតូ)

**៣. បណ្ណរាងត្រីកោណ៖**

នៅផ្នែកខាងលើនៃបណ្ណមានបោះពុម្ពអក្សរ "**ព្រះរាជាណាចក្រកម្ពុជា**" "**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**" "**អគ្គនាយកដ្ឋានពន្ធដារ**" និងលេខ "**២០១២**"។ ផ្នែកកណ្តាលបណ្ណមានបោះពុម្ព Hot Stamping រូបហង្សមានស្មៃប្រាំពីរពណ៌ព្រមទាំងមានកំរងស្លឹកឈើទ្រពីក្រោមតាមរចនាបថអង្គរ និងអក្សរ "**បណ្ណបង់ពន្ធជលយាន**" ។ នៅផ្នែកខាងក្រោមបណ្ណមានបោះពុម្ព Barcode ដោយអមជាមួយនូវលេខរៀង៧ខ្ទង់របស់បណ្ណនីមួយៗ។

បណ្ណរាងត្រីកោណនេះមាន៣ពណ៌គឺ ៖

- បណ្ណពណ៌បៃតងរំលេចពណ៌លឿងទុំប្រើសម្រាប់ ៖

+ ជលយាន ឬជលយានយន្ត ដែលមានប្រាក់ពន្ធត្រូវបង់ចំនួន ១០.០០០ រៀល ដល់ ៧០.០០០រៀល

- បណ្ណពណ៌ទឹកប៊ិចរលេចពណ៌ខៀវ ប្រើសម្រាប់ ៖

+ ជលយាន ឬជលយានយន្ត ដែលមានប្រាក់ពន្ធត្រូវបង់ចំនួន ១០០.០០០រៀល ដល់ ៥០០.០០០រៀល

- បណ្ណពណ៌ផ្កាឈូករលេចពណ៌លឿង ប្រើសម្រាប់ ៖

+ ជលយាន ឬជលយានយន្ត ដែលមានប្រាក់ពន្ធត្រូវបង់ចំនួន ៦០០.០០០រៀល ដល់ ១.២០០.០០០រៀល

**ប្រការ៩**.- ដោយឡែក សម្រាប់ការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ ចំពោះរថយន្តដឹកទំនិញ និងរ៉ឺម៉ក-សណ្តោង ការកំណត់ចំនួនប្រាក់ពន្ធត្រូវផ្អែកតាមទម្ងន់សរុប ដែលរួមមានទម្ងន់រថយន្តទទេ និង ទម្ងន់ផ្ទុក ( ទំនិញ-មនុស្ស) ។

-ចំពោះរថយន្តដែលបំប្លែងមកពីគោយន្ត និង រថយន្តកែច្នៃកង់បី (បំពាក់ដោយម៉ាស៊ីនរថយន្ត) ត្រូវកំណត់ជា រថយន្តដឹកទំនិញដល់ ៣ តោន និងត្រូវបង់ ១៥០,០០០រៀល

- រីឯរថយន្តដឹកទំនិញធុនធ្ងន់ដែលមានភ្លៅ ៣ កង់ ១០ ប្រាក់ពន្ធត្រូវបង់ ៧៥០,០០០រៀល
- រថយន្តដឹកទំនិញដែលមានភ្លៅ ៣ កង់ ៦ ប្រាក់ពន្ធត្រូវបង់ ៤៥០,០០០រៀល
- រ៉ឺម៉កសណ្តោងដែលមានភ្លៅ ២ កង់ ៨ ប្រាក់ពន្ធត្រូវបង់ ៤៥០,០០០រៀល និង
- រ៉ឺម៉កសណ្តោងដែលមានភ្លៅ ២ កង់ ៤ ប្រាក់ពន្ធត្រូវបង់ ២៥០,០០០រៀល ។

**ប្រការ១០**.- រថយន្តដឹកទំនិញធុនតូច(PICK UP) ដែលមានទ្វារ៤ (ពីរបាំង) ៖

- ចាត់ទុកជារថយន្តទេសចរណ៍ ចំពោះរថយន្តមានអាយុកាលគិតពីឆ្នាំផលិតដល់០៧ឆ្នាំ នឹងត្រូវបង់ពន្ធតាមទំហំស៊ីឡាំងដូចមានចែងក្នុងតារាងឧបសម្ព័ន្ធ ។ និង II ភ្ជាប់ជាមួយនឹងប្រកាសនេះ ។
- ចាត់ទុកជារថយន្តដឹកទំនិញធុនតូច ចំពោះរថយន្តមានអាយុកាលគិតពីឆ្នាំផលិតលើសពី ០៧ឆ្នាំ នឹងត្រូវបង់ពន្ធតាមទំងន់ផ្ទុកទំនិញរបស់រថយន្ត ដូចមានចែងក្នុងតារាងឧបសម្ព័ន្ធ I ។

**ប្រការ១១**.- យានយន្តគ្រប់ប្រភេទ ដែលមានបណ្ណសម្គាល់យានយន្ត ប៉ុន្តែមិនបានបង់ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទសម្រាប់ឆ្នាំ២០១១ ហើយបានលក់ទៅឱ្យអ្នកផ្សេង ក្នុងករណីនេះម្ចាស់យានយន្តត្រូវបង់ពន្ធសម្រាប់ឆ្នាំ២០១១ និងបង់ប្រាក់ពិន័យស្មើនឹងប្រាក់ពន្ធ ទើបអនុញ្ញាតឱ្យបង់ពន្ធសម្រាប់ឆ្នាំ២០១២ ។

**ប្រការ១២**.- មធ្យោបាយដឹកជញ្ជូនដែលជាទ្រព្យសកម្មរបស់សហគ្រាសជាប់ពន្ធតាមរបបស្វ័យប្រកាស ត្រូវមកបំពេញលិខិតប្រកាសតាមគំរូដោយឡែក និងបង់ពន្ធនៅអង្គភាពពន្ធដារដែលសហគ្រាសបានប្រកាសបង់ពន្ធ-អាករ ជារៀងរាល់ខែ ។

**ប្រការ១៣**.- ចាប់ពីថ្ងៃទី ១៦ ខែកក្កដា ឆ្នាំ២០១២ នេះតទៅ អង្គភាពពន្ធដារត្រូវធ្វើការត្រួតពិនិត្យ និងដាក់ពិន័យចំនួនមួយដងស្មើប្រាក់ពន្ធបន្ថែមលើប្រាក់ពន្ធដែលត្រូវបង់ចំពោះមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទទាំងឡាយណា ដែលមិនបានបង់ពន្ធសម្រាប់ឆ្នាំ២០១២ ដូចបានកំណត់ក្នុងប្រការ១ខាងលើ ។

ប៉ុន្តែចំពោះមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ ដែលទើបដាក់អោយធ្វើចរាចរនៅក្រោយថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០១២ ត្រូវមានវិក្កយបត្របញ្ជាក់ ឬឯកសារផ្សេងៗចេញដោយអ្នកលក់អមដោយបង្កាន់ដៃបង់ពន្ធនាំចូល ឬបណ្ណសម្គាល់យានយន្ត(ប័តគម្លង)... ភ្ជាប់ជាមួយលិខិតប្រកាសសុំបង់ពន្ធ និងត្រូវមកប្រកាស បង់ពន្ធនៅតាមទីស្នាក់ការពន្ធដារ ឬទីកន្លែងប្រមូលពន្ធដែលកំណត់ដោយសាខាពន្ធដារខេត្ត-ខណ្ឌ នៅរៀងរាល់ថ្ងៃធ្វើការ ។ បើពុំមកប្រកាសសុំបង់ពន្ធក្នុងរយៈពេល ១ខែ គិតចាប់ពីថ្ងៃដែលដាក់ឱ្យធ្វើចរាចរ ត្រូវពិន័យចំនួនមួយដងស្មើប្រាក់ពន្ធបន្ថែមលើប្រាក់ពន្ធដែលត្រូវបង់សម្រាប់ឆ្នាំ២០១២ នេះ ។

**ប្រការ១៤.-** ប្រកាសនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១២

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

គាត ឈន់

*កន្លែងទទួល ៖*

- ទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីជ្រាប"
- គ្រប់ក្រសួង-ស្ថាប័នកណ្តាល
- គ្រប់សាលារាជធានី-ខេត្ត "ដើម្បីជ្រាបជាព័ត៌មាន"
- គ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ "ដើម្បីមុខការ"
- គ្រប់សាខាពន្ធដារខេត្ត-ខណ្ឌ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ: ០០១ សហវ.អគហ

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០១២

# សារាចរណែនាំ
# ស្តីពី
# ការអនុវត្តច្បាប់ស្តីពីលទ្ធកម្មសាធារណៈ

រាជរដ្ឋាភិបាល បានប្រកាសដាក់ឱ្យអនុវត្តនូវកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្នុងដំណាក់កាលទី១នៅថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០០៤ និងដំណាក់កាលទី២នៅថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០០៨ ។ ការកែទម្រង់ក្នុងដំណាក់កាលទី១ បានដើរតួនាទីយ៉ាងសំខាន់ក្នុងការកែលម្អការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដោយសម្រេចបាននូវភាពជឿទុកចិត្តលើថវិកា ។ ដំណាក់កាលទី២ នៃកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បច្ចុប្បន្នកំពុងផ្តោតអាទិភាពជាពិសេសទៅលើការបង្កើនគណនេយ្យភាពហិរញ្ញវត្ថុ ដែលក្នុងនោះ ការពង្រឹងកិច្ចគ្រប់គ្រងលទ្ធកម្មសាធារណៈគឺជាសមាសភាពមួយដ៏សំខាន់ ។

កន្លងមក នៅក្នុងក្របខណ្ឌនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានធ្វើវិសហមជ្ឈការលទ្ធកម្មសាធារណៈ ដោយប្រគល់សិទ្ធិជាបន្តបន្ទាប់ជូនស្ថាប័នអនុវត្តលទ្ធកម្ម ក្នុងការអនុវត្តនិងសម្រេចលើកិច្ចលទ្ធកម្មសាធារណៈ ។ ប្រការនេះតម្រូវឱ្យផ្តោតការយកចិត្តទុកដាក់លើការពង្រឹងសមត្ថភាពនិងការទទួលខុសត្រូវរបស់ស្ថាប័នអនុវត្តលទ្ធកម្ម ។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងមានតួនាទីរៀបចំគោលនយោបាយលទ្ធកម្មសាធារណៈ បណ្តុះបណ្តាល សង្កេតការណ៍ និងធ្វើសវនកម្មលើកិច្ចលទ្ធកម្មដែលបានអនុវត្តរួច ។ ក្នុងស្មារតីនេះ និងស្របតាមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ច្បាប់ស្តីពីលទ្ធកម្មសាធារណៈ ត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស / រកម / ០១១២/០០៤ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១២ ។ ច្បាប់នេះ ត្រូវបានបង្កើតឡើងក្នុងគោលបំណងធានាឱ្យដំណើរការលទ្ធកម្មសាធារណៈសម្រាប់ការទិញ ការសាងសង់ ការផ្គត់ផ្គង់ ការផ្តល់សេវាកម្ម និងការផ្តល់សេវាទីប្រឹក្សា ប្រព្រឹត្តទៅប្រកបដោយតម្លាភាព គណនេយ្យភាព ភាពយុត្តិធម៌ ប្រសិទ្ធភាព

គុណភាព សមភាព ការសន្សំសំចៃ និងភាពទាន់ពេលវេលា ព្រមទាំងធានាឱ្យបាននូវប្រព័ន្ធលទ្ធកម្មសាធារណៈឯកភាពមួយនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ ច្បាប់នេះ ក៏មានគោលបំណងរួមចំណែកក្នុងការបង្ការអំពើពុករលួយផងដែរ ។

ដើម្បីសម្រេចបាននូវគោលបំណងខាងលើ ច្បាប់ស្តីពីលទ្ធកម្មសាធារណៈ បានតម្រូវឱ្យរាជរដ្ឋាភិបាលរៀបចំនូវអនុក្រឹត្យនិងប្រកាសមួយចំនួន សម្រាប់ដាក់ឱ្យស្ថាប័នអនុវត្តលទ្ធកម្មដែលក្នុងនោះមានក្រសួង ស្ថាប័ន រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈរដ្ឋបាល អង្គភាពស្វយ័តភាពហិរញ្ញវត្ថុដទៃទៀត និងដៃគូឯកជនសាធារណៈ អនុវត្តស្របតាមបទប្បញ្ញត្តិដែលមានចែងនៅក្នុងច្បាប់នេះ ។

ក្នុងពេលកំពុងបន្តរៀបចំលិខិតបទដ្ឋានគតិយុត្ត និងក្នុងស្មារតីនៃការពង្រឹងសមត្ថភាពនិងការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័ន រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈរដ្ឋបាល អង្គភាពស្វយ័តភាពហិរញ្ញវត្ថុដទៃទៀត និងដៃគូឯកជនសាធារណៈ ស្របតាមគោលការណ៍នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ព្រមទាំងអនុលោមតាមមាត្រា៧៤នៃច្បាប់ស្តីពីលទ្ធកម្មសាធារណៈ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមធ្វើការណែនាំគ្រប់ស្ថាប័នអនុវត្តលទ្ធកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា *ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមវិធាននិងបទប្បញ្ញត្តិ វិធីសាស្ត្រនិងនីតិវិធីលទ្ធកម្មសាធារណៈ ដែលចែងក្នុងអនុក្រឹត្យលេខ១០៥ អនក្រ.បក ចុះ ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៦ ស្តីពីលទ្ធកម្មសាធារណៈ និងប្រកាសលេខ៣៨១ សហវ.ប្រក ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១០ ស្តីពីការដាក់ឱ្យប្រើប្រាស់សៀវភៅលទ្ធកម្មស្តីពីការអនុវត្តវិធាននិងបទប្បញ្ញត្តិស្តីពីលទ្ធកម្មសាធារណៈ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងលទ្ធកម្មសាធារណៈដែលនៅជាធរមាន រហូតដល់ពេលមានលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួស* ។

ទន្ទឹមនឹងនេះ ស្ថាប័នអនុវត្តលទ្ធកម្មត្រូវប្រកាន់ខ្ជាប់នូវក្រមសីលធម៌លទ្ធកម្ម និងបទប្បញ្ញត្តិទាំងឡាយដែលមានចែងក្នុងច្បាប់ស្តីពីលទ្ធកម្មសាធារណៈ ពិសេសត្រង់មាត្រា៧៣ ដែលចែងថា *"បទល្មើសពុករលួយដែលមានចែងក្នុងច្បាប់នេះ និងក្នុងច្បាប់និងបទប្បញ្ញត្តិជាធរមានដទៃទៀតនៃព្រះរាជាណាចក្រកម្ពុជា ក៏ស្ថិតនៅក្រោមសមត្ថកិច្ចរបស់អង្គភាពប្រឆាំងអំពើពុករលួយដែលជាអង្គភាពតែមួយគត់ មានសមត្ថកិច្ចស៊ើបអង្កេតនិងកសាងសំណុំរឿងពុករលួយទៅតុលាការ ។ អង្គភាពនិងបុគ្គលដទៃទៀត ដែលបានដឹងពីបទល្មើសពុករលួយទាំងឡាយណាដែលមានចែងក្នុងច្បាប់នេះ និងក្នុងច្បាប់និងបទប្បញ្ញត្តិជាធរមានដទៃទៀតនៃព្រះរាជាណាចក្រកម្ពុជា ត្រូវប្តឹងទៅអង្គភាព ឬការិយាល័យរាជធានី ខេត្ត ប្រឆាំងអំពើពុករលួយ អំពីរឿងហេតុនៃបទល្មើសទាំងនេះ"*។

ទទួលបាននូវសារាចរណែនាំនេះ សូមសម្តេច ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលជាប្រធានក្រសួង ស្ថាប័ន រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈរដ្ឋបាល អង្គភាពស្វយ័តភាពហិរញ្ញវត្ថុដទៃទៀត និងដៃគូឯកជនសាធារណៈ យកចិត្តទុកដាក់អនុវត្តឱ្យបានម៉ឺងម៉ាត់និងមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់

**ចម្លងជូន:**
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាប"
- គ្រប់ក្រសួង ស្ថាប័ន
- គ្រប់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់
- គ្រប់សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈរដ្ឋបាល អង្គភាពស្វយ័តភាពហិរញ្ញវត្ថុដទៃទៀត ដៃគូឯកជនសាធារណៈ
  "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ០០៦ សហវ.សជណ

រាជធានីភ្នំពេញ, ថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១២

# សេចក្តីជូនដំណឹង
# ស្តីពី
# ការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ សម្រាប់ឆ្នាំ២០១២

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានកិត្តិយសសូមជម្រាបលោក-លោកស្រី ដែលជាម្ចាស់មធ្យោបាយដឹកជញ្ជូន និងយានយន្តគ្រប់ប្រភេទ មេត្តាជ្រាបថា ការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទសម្រាប់ឆ្នាំ២០១២ ត្រូវចាប់អនុវត្តពីថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១២ រហូតដល់ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១២ ។

ពន្ធនេះត្រូវបានលើកលែងចំពោះ ៖

-រថយន្តគិលានសង្គ្រោះ រថយន្តពន្លត់អគ្គីភ័យរបស់រដ្ឋ

-មធ្យោបាយដឹកជញ្ជូន និងយានជំនិះ ជាកម្មសិទ្ធិរបស់កងយោធពលខេមរភូមិន្ទ កងរាជអាវុធហត្ថ នគរបាលជាតិ ដែលបំរើឱ្យការងារសម្រាប់កិច្ចការពារប្រទេស សន្តិសុខ និងសណ្តាប់ធ្នាប់សង្គម

-មធ្យោបាយដឹកជញ្ជូន និងយានជំនិះរបស់បេសកកម្មទូត ឬកុងស៊ុលបរទេស អង្គការអន្តរជាតិ ឬទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលនានា ។

ដើម្បីបង់ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទសម្រាប់ឆ្នាំ២០១២ ម្ចាស់មធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ ត្រូវបំពេញនូវលិខិតប្រកាសចំនួន ០២ សន្លឹក តាមគំរូឯកភាពរបស់អគ្គនាយកដ្ឋានពន្ធដារ (លើកលែងតែម្ចាស់ទោចក្រយានយន្ត និងត្រីចក្រយានយន្តបំពាក់ដោយម៉ាស៊ីនម៉ូតូ) ព្រមទាំងត្រូវបង្ហាញ និងប្រគល់ជូនមន្ត្រីដែលមានសមត្ថកិច្ចនូវបង្កាន់ដៃបង់ពន្ធសម្រាប់ឆ្នាំ២០១១ សម្រាប់ជាភស្តុតាងបញ្ជាក់ថា មធ្យោបាយដឹកជញ្ជូន និងយានជំនិះនោះបានបង់ពន្ធសម្រាប់ឆ្នាំ២០១១រួចហើយ ។ ក្នុងករណីបាត់បង្កាន់ដៃបង់ពន្ធសម្រាប់ឆ្នាំ២០១១ ម្ចាស់មធ្យោបាយដឹកជញ្ជូន និងយានជំនិះ ត្រូវមានលិខិតបញ្ជាក់ថាបានបង់ពន្ធសម្រាប់ឆ្នាំ២០១១ ដែលចេញដោយប្រធានសាខាពន្ធដារខេត្ត-ខណ្ឌ នៃទីកន្លែងដែលយានយន្តនោះបានបង់ពន្ធសម្រាប់ឆ្នាំ២០១១ ។

ម្ចាស់មធ្យោបាយដឹកជញ្ជូន និងយានជំនិះទាំងឡាយណាដែលពុំមានបង្កាន់ដៃបង់ពន្ធឆ្នាំ២០១១ទេនោះ ម្ចាស់មធ្យោបាយដឹកជញ្ជូន និងយានជំនិះនោះ ត្រូវបង់ពន្ធសម្រាប់ឆ្នាំ២០១១ និងត្រូវបង់ប្រាក់ពិន័យដែលមានចំនួនស្មើនឹងប្រាក់ពន្ធ ទើបអនុញ្ញាតឱ្យបង់ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92 Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
www.mef.gov.kh
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798
mef_adm@yahoo.com

ប្រភេទសម្រាប់ឆ្នាំ២០១២ ។ លើកលែងតែទោចក្រយានយន្ត និងត្រីចក្រយានយន្តបំពាក់ដោយម៉ាស៊ីនម៉ូតូប៉ុណ្ណោះ ដែលពុំចាំបាច់ឱ្យម្ចាស់បង្ហាញបង្កាន់ដៃបង់ពន្ធឡើយ គឺគ្រាន់តែទិញបណ្ណបង់ពន្ធយកទៅបិទយានយន្ត របស់ខ្លួនជាការស្រេច ។ ក្នុងករណីទោចក្រយានយន្ត និងត្រីចក្រយានយន្តណាមួយគ្មានបិទបណ្ណបង់ពន្ធ ត្រូវចាត់ទុកថាមិនទាន់បានបង់ពន្ធនៅឡើយ ។

ក្រោយពេលបង់ពន្ធបានត្រឹមត្រូវរួចហើយ ម្ចាស់មធ្យោបាយដឹកជញ្ជូន និងយានជំនិះនីមួយៗ ត្រូវបានទទួលបង្កាន់ដៃបង់ពន្ធមួយសន្លឹក និងបណ្ណបង់ពន្ធមួយសន្លឹកសម្រាប់បិទភ្ជាប់មធ្យោបាយដឹកជញ្ជូន និងយានជំនិះនីមួយៗ នោះ ។ ម្ចាស់មធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ ត្រូវរក្សាទុកបង្កាន់ដៃបង់ពន្ធ និងត្រូវយកជាប់ជាមួយសម្រាប់ទុកបង្ហាញ មន្ត្រីត្រួតពិនិត្យដែលមានសមត្ថកិច្ច ។

ចំពោះមធ្យោបាយដឹកជញ្ជូនដែលជាទ្រព្យសកម្មរបស់សហគ្រាសជាប់ពន្ធតាមរបបស្វ័យប្រកាស ត្រូវមកបំពេញលិខិតប្រកាសតាមគំរូដោយឡែក និងបង់ពន្ធនៅអង្គភាពពន្ធដារដែលសហគ្រាសបានប្រកាសបង់ពន្ធ-អាករ ជារៀងរាល់ខែនោះ ។

ការត្រួតពិនិត្យការបង់ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទសម្រាប់ឆ្នាំ២០១២ ត្រូវអនុវត្ត ចាប់ពីថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១២ តទៅ ។

ចំពោះមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ ដែលទើបដាក់ឱ្យធ្វើចរាចរនៅក្រោយថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១២ ត្រូវមានវិក្កយបត្រ ឬឯកសារផ្សេងៗ ចេញដោយអ្នកលក់ អមដោយបង្កាន់ដៃបង់ពន្ធនាំចូល ឬបណ្ណសំគាល់យានយន្ត (ថតចម្លង) ភ្ជាប់ជាមួយលិខិតប្រកាសសុំបង់ពន្ធ និងត្រូវមកប្រកាសបង់ពន្ធនៅតាមទីស្នាក់ការពន្ធដារ ឬទីកន្លែងប្រមូលពន្ធដែលកំណត់ដោយសាខាពន្ធដារខេត្ត-ខណ្ឌ នៅរៀងរាល់ថ្ងៃធ្វើការ ។ បើពុំមកប្រកាសសុំបង់ពន្ធក្នុងរយៈពេល ១ខែ គិតពីថ្ងៃដែលដាក់ឱ្យធ្វើចរាចរ ត្រូវពិន័យចំនួនមួយដងស្មើប្រាក់ពន្ធបន្ថែមលើប្រាក់ពន្ធដែលត្រូវបង់សម្រាប់ ឆ្នាំ២០១២នេះ ។

សម្រាប់ឆ្នាំ២០១២នេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានផលិតបណ្ណ លតាបត្រពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ ដោយមានគុណភាព មានសញ្ញាចំណាំ និងលេខកូដ ដែលអាចផ្ទៀងផ្ទាត់ ឬប្រើប្រាស់ឧបករណ៍ស្វ័យប្រវត្តិ ដើម្បីត្រួតពិនិត្យលក្ខណៈពិតប្រាកដ និងក្លែងក្លាយរបស់លតាបត្រទាំងនោះ ។ ដូច្នេះដើម្បីជៀសវាង ការទិញបណ្ណបង់ពន្ធក្លែងក្លាយនោះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សូមអញ្ជើញ លោក-លោកស្រី ជាម្ចាស់យានយន្តទៅ ប្រកាសបង់ពន្ធដោយផ្ទាល់នៅតាមទីកន្លែងប្រមូលពន្ធដែលកំណត់ដោយសាខាពន្ធដារខេត្ត-ខណ្ឌ ដែលនៅជិតគេហដ្ឋាន លោក-លោកស្រី ។

អាស្រ័យហេតុនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សូមជូនដំណឹងដល់ម្ចាស់យានយន្តគ្រប់ប្រភេទ មេត្តារួសរាន់អញ្ជើញទៅបង់ពន្ធនេះឱ្យបានមុនថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១២ កុំបីខាន ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

គាត ឈន់

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ..................សហវ.....

**តារាងឧបសម្ព័ន្ធស្តីពីប្រាក់ពន្ធត្រូវកំណត់**
**ចំពោះមធ្យោបាយដឹកជញ្ជូន និង យានជំនិះគ្រប់ប្រភេទ**
**( តារាងឧបសម្ព័ន្ធទី । )**

ភ្ជាប់ជាមួយប្រកាសលេខ....០៤៧.......សហវ.ប្រក ចុះថ្ងៃទី..១០..ខែកុម្ភៈ....ឆ្នាំ២០១២ របស់ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

ឯកតា៖ រៀល

| **ប្រភេទមធ្យោបាយដឹកជញ្ជូន និង យានជំនិះ** | **អត្រាប្រាក់ពន្ធសម្រាប់១ឆ្នាំ ក្នុងមួយគ្រឿង** | |
|---|---|---|
| - រថយន្តដឹកទំនិញមានទម្ងន់សរុប [ទម្ងន់រថយន្តទទេនិងទម្ងន់ផ្ទុក (ទំនិញនិងមនុស្ស)]៖ | | |
| + ដល់ ៣ តោន | 150 000 | |
| + លើសពី ៣ តោន ដល់ ១០ តោន | 250 000 | |
| + លើសពី ១០ តោន ដល់ ២០ តោន | 450 000 | |
| + លើសពី ២០ តោន | 750 000 | |
| - រ៉ឺម៉កសណ្តោងដែលមានទម្ងន់សរុប (រ៉ឺម៉កនិងទំនិញ)៖ | | |
| + ដល់ ១០ តោន | 250 000 | |
| + លើសពី ១០ តោន ដល់ ២០ តោន | 450 000 | |
| + លើសពី ២០ តោន | 750 000 | |
| - រថយន្តដឹកអ្នកដំណើរមានកៅអីដល់ ១៥ កៅអី | 150 000 | |
| - រថយន្តដឹកអ្នកដំណើរធុនមធ្យម មានកៅអីពី ១៦ កៅអី ដល់ ២៥ កៅអី | 200 000 | |
| - រថយន្តដឹកអ្នកដំណើរធុនធំ មានកៅអីលើសពី ២៥ កៅអី | 250 000 | |
| - រថយន្តទេសចរណ៍ គ្រប់ប្រភេទ | **គិតពីឆ្នាំផលិត** | |
| | **ដល់ ៥ ឆ្នាំ** | **លើសពី ៥ ឆ្នាំ** |
| + ទំហំស៊ីឡាំងដល់ ១៥០០ ស.ម³ (ដល់ ១.៥ លីត្រ) | 100 000 | 80 000 |
| + ទំហំស៊ីឡាំងលើសពី១៥០០ស.ម³ដល់ ២០០០ស.ម³ (លើសពី ១.៥ ដល់២.០លីត្រ) | 150 000 | 100 000 |

| | | |
|---|---|---|
| + ទំហំស៊ីឡាំងលើសពី ២០០០ស.ម³ ដល់ ២៩០០ស.ម³(លើសពី ២.០ ដល់២.៩លីត្រ) | 500 000 | 360 000 |
| + ទំហំស៊ីឡាំងលើសពី ២៩០០ ស.ម³ ដល់ ៤០០០ ស.ម³(លើសពី ២.៩ ដល់៤.០លីត្រ) | 1 600 000 | 1 200 000 |
| + ទំហំស៊ីឡាំងលើសពី ៤០០០ ស.ម³ ឡើងទៅ (លើសពី ៤.០លីត្រ) | 2 000 000 | |
| - ត្រាក់ទ័រកម្លាំង ៣៥ សេះ និងគ្រឿងចក្រប្រហាក់ប្រហែល | 30 000 | |
| - ត្រាក់ទ័រកម្លាំង ៦៥ សេះ និងគ្រឿងចក្រប្រហាក់ប្រហែល | 40 000 | |
| - ត្រាក់ទ័រកម្លាំង ៨២ សេះ និងគ្រឿងចក្រប្រហាក់ប្រហែល | 50 000 | |
| - ទោចក្រយានយន្តទំហំពិសស្តុងដល់ ៧០ ស.ម³ | 3 000 | |
| - ទោចក្រយានយន្តទំហំពិសស្តុងលើសពី៧០ ស.ម³ ដល់១២៥ ស.ម³ | 4 500 | |
| - ទោចក្រយានយន្តទំហំពិសស្តុងលើសពី ១២៥ ស.ម³ ឡើងទៅ | 7 500 | |
| - ត្រីចក្រយានយន្តដឹកទំនិញ ឬ អ្នកដំណើរ | 15 000 | |
| <u>ជលយាន ឬជលយានយន្ត ផ្លូវទន្លេ</u> ៖ | | |
| - ជលយានដឹកទំនិញ ៖ | | |
| + ដល់ ៣ តោន | 50 000 | |
| + លើសពី ៣ តោន ដល់ ១០ តោន | 100 000 | |
| + លើសពី ១០ តោន ដល់ ២០ តោន | 200 000 | |
| + លើសពី ២០ តោន | 300 000 | |
| - កប៉ាល់ដឹកអ្នកដំណើរបណ្តោយដល់ ២០ ម៉ែត្រ | 100 000 | |
| - កប៉ាល់ដឹកអ្នកដំណើរបណ្តោយលើសពី ២០ ម៉ែត្រ ដល់ ៣០ ម៉ែត្រ | 200 000 | |
| - កប៉ាល់ដឹកអ្នកដំណើរបណ្តោយលើសពី ៣០ ម៉ែត្រ ឡើងទៅ | 300 000 | |
| - កប៉ាល់សណ្តោងមានកម្លាំងដល់ ៥០ សេះ | 20 000 | |
| - កប៉ាល់សណ្តោងមានកម្លាំងលើសពី ៥០ សេះ ដល់ ១០០ សេះ | 30 000 | |
| - កប៉ាល់សណ្តោងមានកម្លាំងលើសពី ១០០ សេះ ដល់ ១៥០ សេះ | 50 000 | |
| - កប៉ាល់សណ្តោងមានកម្លាំងលើសពី ១៥០ សេះ ដល់ ២០០ សេះ | 60 000 | |
| - កប៉ាល់សណ្តោងមានកម្លាំងលើសពី ២០០ សេះ ដល់ ២៥០ សេះ | 180 000 | |
| - កប៉ាល់សណ្តោងមានកម្លាំងលើសពី ២៥០ សេះ ឡើងទៅ | 300 000 | |
| - កាណូតនេសាទមានកម្លាំងដល់ ៥០ សេះ | 10 000 | |

